# ទស្សនាវដ្ដីភាសា និង សិលាចារឹកវិទ្យា

## វិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិត្យសភាកម្ពុជា

**Revue de Linguistique et d'épigraphie**

**Institut de la Langue Nationale Académic Royale du Cambodge**




ឆ្នាំទី ១ លេខ ១ ខែកញ្ញា

ព.ស ២៥៤៤ គ.ស ២០០០

Premiére année No. 1 Septembre. 2000

ភ្នំពេញ

ចាងហ្វាង : បណ្ឌិត សាស្ត្រាចារ្យ ឡុង សៀម
ចាងហ្វាងរង : បណ្ឌិត អ៊ីវ ច័ន

<u>ក្រុមអ្នកនិពន្ធ</u>

បណ្ឌិត ព្រុំ ម៉ល់

បណ្ឌិត ថែល ថោង

និង បុគ្គលិកវិទ្យាស្ថានភាសាជាតិ

**DIRECTOR** : Professor Doctor **Long Seam**
**VICE-DIRECTOR** : Doctor **Iv Chan**


**AUTHORS**

Dr. **Prum Moal**
Dr. **Thel Thong**
and
Staff of National Language Institute



ចេញផ្សាយដោយ : វិទ្យាស្ថានភាសាជាតិ
Publisher : National Language Institute of Camboia
អាស័យដ្ឋាន : ក្នុងបរិវេណសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មណ្ឌល២
ផ្លូវសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address : Royal University of Phnom Penh , Campus II
Boulevard Federation of Russia , Phnom Penh , Cambodia
Telephone : 023 89 02 84 , 023 89 01 80
E-mail : racademy@camnet.com.kh

**Vol. 1 , N° 1 , September 2000**

# មាតិការឿង


១ អារម្ភកថា ---------------------------------------- ១

២ អនុក្រឹត្យស្តីពីការបង្កើតវិទ្យាស្ថានភាសាជាតិ -------------------- ២

៣ សិក្សាកថាសិលាចារឹករកឃើញថ្មីរបស់ព្រះបាទសូរ្យវរ្ម័នទីមួយ ( នៅមន្ទីរអភិរក្សអង្គរ )

បណ្ឌិតសាស្ត្រាចារ្យ ឡុង សៀម -------------------- ១៩

៤ ការស្នើសញ្ញាព្យញ្ជនៈ ស្រៈ និង វណ្ណយុត្តិ ខ្មែរក្នុងយូនីកូដកុំព្យូទ័រ

បណ្ឌិត អ៊ីវ ច័ន -------------------------------- ៤៤

៥ ANALYSE SOMMAIRE DES STRUCTURES DU CAMBODGIEN

Dr. PRUM MOAL ---------------------------------------- ៤៨

៦ CAMBODIAN NAMING SYSTEM Dr. THEL THONG --- ៥៨

៧ ឯកភាពរូបនីយកម្មភាសាខ្មែរ បណ្ឌិត ឆយ ឃីហ៊ាង -------------- ៦៥

៨ ឯកភាវូបនីយកម្មអក្ខរាវិរុទ្ធ ពាក្យបច្ចេកទេស និង ពាក្យវិទ្យាសាស្ត្រ

សាស្ត្រាចារ្យ ឆាយ គីម -------------------------- ៧៣

៩ LOGICAL-SEMANTIC APPROACHES TO KHMER GRAMMAR THE CATEGORY OF NUMBER

Dr. POGIBENKO TAMARA --------------------------- ៧៧

១០ អត្ថបទដកស្រង់ពីនាទីសម្ភាសអក្សរសាស្ត្រសម្តេចសង្ឃរាជ ជួន ណាត

បណ្ឌិត ផែល ថោង ------------------------------ ៨៥

១១ កំណត់ហេតុប្រជុំស្តីពីមូលដ្ឋាននៃការអភិវឌ្ឍន៍ភាសាខ្មែរ

( ថ្ងៃទី ១២ សីហា ២០០០ ) ----------------------- ៩៤

១២ កំណត់ហេតុប្រជុំត្រៀមសន្និសីទជាតិ ថ្ងៃទី ២៥ សីហា ២០០០ ------- ១០១

# អារម្ភកថា

ស្របតាមអត្ថន័យ នៃអនុក្រឹត្យស្តីពីការបង្កើតវិទ្យាស្ថានភាសាជាតិអនុម័តដោយក្រុមប្រឹក្សារដ្ឋមន្ត្រីនៅឆ្នាំ១៩៩៨ ទស្សនាវដ្តីនៃវិទ្យាស្ថានភាសាជាតិ ដែលមានឈ្មោះថាទស្សនាវដ្តីភាសា និងសិលាចារឹកវិទ្យា ក៏បានកកើតឡើងដោយសារការប្រឹងប្រែងរបស់បុគ្គលិកទាំងអស់នៃវិទ្យាស្ថានភាសាជាតិ ។

មិនតែប៉ុណ្ណោះទស្សនាវដ្តីភាសា និងសិលាចារឹកវិទ្យាអាចចាត់ទុកថា ជាកិច្ចការស្រាវជ្រាវខាងភាសា សិលាចារឹក សាត្រា និងអក្សរសិល្ប៍ បន្តតំណែងពីព្រឹត្តិប័ត្រនៃវិទ្យាស្ថានខ្មែរ-មនទាឆ្នាំ ១៩៧០-១៩៧៥ផងដែរ ដោយហេតុថាទស្សនាវដ្តីភាសា និងសិលាចារឹកវិទ្យា ចាប់ផ្តើមបោះពុម្ពផ្សាយតាំងពីឆ្នាំ ២០០០ទៅ នឹងមាន ចុះផ្សាយអត្ថបទផ្សេងៗ និងការស្រាវជ្រាវទាំងឡាយដែលទាក់ទងទៅនឹងភាសា អក្សរសិល្ប៍ សិលាចារឹក សាត្រា ឯកសារបុរាណផ្សេងៗមានទាំងការ ស្រាវជ្រាវពីភាសា និងអក្សរសិល្ប៍នៃជនជាតិ មន-ខ្មែរដទៃ ដែលរស់នៅលើដែនឥណ្ឌូចិន និង នៅលើដែនដីប្រទេសចិន ប្រទេសឥណ្ឌា និងប្រទេសម៉ាឡេស៊ីទៀតផង ។

អធិបតីនៃទស្សនាវដ្តី នឹងបោះពុម្ពផ្សាយនូវអត្ថបទទាំងឡាយ ដែលសរសេរជាភាសាខ្មែរ ភាសាបារាំង និងជាភាសាអង់គ្លេស របស់អ្នកនិពន្ធជាតិ និងបរទេសទាំងអស់ ដែលមានខ្លឹមសារវិទ្យាសាស្ត្រជ្រាលជ្រៅ ឬជាអត្ថបទនៃការសិក្សាជាមូលដ្ឋាន គឺជានិក្ខេបបទថ្នាក់ក្រោយឧត្តមសិក្សា ។

ស្នាដៃទាំងឡាយដែលបោះពុម្ពនៅក្នុងទស្សនាវដ្តីនឹងត្រូវផ្ញើទៅគ្រប់មជ្ឈដ្ឋាន ខាងភាសាវិទ្យា ខាងអក្សរសិល្ប៍នៅក្នុងប្រទេសក៏ដូចជានៅក្រៅប្រទេស មិនតែប៉ុណ្ណោះនឹងមានការផ្សព្វផ្សាយតាមរយៈប្រព័ន្ធអ៊ិនធឺរណែតអន្តរជាតិទៀតផង ។

ភ្នំពេញថ្ងៃទី ៦ កញ្ញា ឆ្នាំ ២០០០
នាយកវិទ្យាស្ថានភាសាជាតិ

**បណ្ឌិតសាស្ត្រាចារ្យ ឡុង សៀម**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ....[illegible] អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតវិទ្យាស្ថានកាតាជាតិ
## ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយក - រដ្ឋមន្ត្រី ទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិ - បាលកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស- ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួល សមាសភាព រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០-៩៤-៩០ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ ជស-រកត -០៨-៩៧ -១៤៧ - ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ១៩៩៧ស្តីពីការកែសំរួលសមាសភាពនៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស-រកម-០១៩៦-០១ ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមព្រះរាជក្រឹត្យលេខ នស -រកត-១២៩៧-៩១-ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៩៧

ស្តីអំពីលក្ខន្តិក គតិយុត្តិ នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល

- យោងតាមអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី ២៣ ខែមិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានការអនុម័តរបស់គណៈរដ្ឋមន្ត្រី សម័យប្រជុំថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ១៩៩៨។

## សំរេច

## ជំពូក I

## បទបញ្ញត្តិទូទៅ

### មាត្រា១

វិទ្យាស្ថានភាសាជាតិ ហៅកាត់ថា ( វ . ភ . ជ .) ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ស្ថិតនៅក្រោមបទបញ្ញត្តិនៃអនុក្រឹត្យនេះ ព្រមទាំងបទបញ្ជាផ្ទៃក្នុងមួយ និងបទបញ្ញត្តិដែលពាក់ព័ន្ធដទៃទៀតនាថ្ងៃក្រោយ ។

### មាត្រា២

វិទ្យាស្ថានភាសាជាតិជានីតិបុគ្គលភាព ដែលមានស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុ ។

### មាត្រា ៣

វិទ្យាស្ថានភាសាជាតិមានបេសកកម្ម សិក្សាស្រាវជ្រាវ ផ្សព្វផ្សាយ និងអភិវឌ្ឍភាសាខ្មែរ ហើយមានមុខងារ និងភារកិច្ចសំខាន់ៗ ដូចតទៅ ៖

- សិក្សាស្រាវជ្រាវភាសាខ្មែរ និងភាសាមន-ខ្មែរ ព្រមទាំងភាសាទាំងអស់ ដែលពាក់ព័ន្ធតាមបែបបទភាសាវិទ្យាទូទៅ និងភាសាវិទ្យាអនុវត្ត ដើម្បីចងក្រងក្បួនខ្នាតពន្យល់ អំពីការវិវត្តនៃភាសានេះតាំងពីសម័យបុរាណ សម័យកណ្តាល រហូតមកដល់សម័យបច្ចុប្បន្ននេះ
- រៀបចំការអនុវត្តឯកភាវូបនីយកម្ម នៃការប្រើប្រាស់ភាសាសរសេរ និងភាសានិយាយ អក្ខរាវិរុទ្ធ និង ធ្វើឱ្យមានលក្ខណៈស្តង់ដា ក្នុងការប្រើពាក្យបច្ចេកទេសវិទ្យាសាស្ត្រ និងតួអក្សរខ្មែរក្នុងកុំព្យូទ័រ
- ស្រាវជ្រាវប្រមែប្រមូល សិក្សាបោះពុម្ពផ្សាយ និងរក្សាទុកនូវស្នាដៃទាំងឡាយ ខាងអក្សរសិល្ប៍ ប្រវត្តិសាស្ត្រខ្មែរ តាមឯកសារដើម មានជាអាទិ៍ សិលាចារឹកកម្ពុជា សាត្រាស្លឹករឹត ក្រាំង រាជពង្សាវតារ
- ប្រមែប្រមូលសិរិតសំរាំងបង្កើតបន្ថែម នូវភាក្យស័ព្ទបច្ចេកទេសវិទ្យាសាស្ត្រនៅលើមូលដ្ឋានភាក្យស័ព្ទបច្ចេកទេសវិទ្យាសាស្ត្រអន្តរជាតិ ដោយមានការចូលរួមពីសំណាក់អ្នកឯកទេស ខាងមុខវិជ្ជានីមួយៗ

- រៀបរៀងនិងបោះពុម្ពផ្សាយ សទ្ទានុក្រម វចនានុក្រម មានជាអាទិ៍ វចនានុក្រមភាសាខ្មែរ វចនានុក្រមអង់ស៊ីក្លូប៉េឌិក វចនានុក្រមពហុបច្ចេកទេសនិងវិទ្យាសាស្ត្រ វចនានុក្រម ខ្មែរ-បារាំង ខ្មែរ-អង់គ្លេស ។ល។

- បកប្រែ បោះពុម្ពសៀវភៅ ឯកសារវិទ្យាសាស្ត្រ វប្បធម៌ និងផ្សព្វផ្សាយពត៌មានវិទ្យាសាស្ត្រ

- សំរបសំរួលទំនាក់ទំនង រវាងក្រសួង ស្ថាប័នក្នុងប្រទេស និងក្រៅប្រទេសដើម្បីអភិវឌ្ឍន៍ និងត្រួតពិនិត្យការប្រើប្រាស់ភាសាខ្មែរ

- បណ្តុះបណ្តាលថ្នាក់សិក្សាស្រាវជ្រាវខាងភាសា និងអក្សរសាស្ត្រ ដោយសហការជាមួយនឹងស្ថាប័នជំនាញទាំងអស់ ក្នុងប្រទេស និងក្រៅប្រទេស។

## ជំពូក II

## ការដឹកនាំ និងការគ្រប់គ្រង

## ផ្នែកទី ១

## អង្គការសំរេចរបស់វិទ្យាស្ថានភាសាជាតិ

### មាត្រា៤

វិទ្យាស្ថានភាសាជាតិ ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ ដែលមានសិទ្ធិយ៉ាងធំទូលាយដើម្បីបំពេញបេសកកម្ម ក្នុងនាមវិទ្យាស្ថានភាសាជាតិ ក្នុងក្របខ័ណ្ឌនៃបទបញ្ញត្តិនៃអនុក្រឹត្យនេះ និងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

### មាត្រា៥

ក . ក្រុមប្រឹក្សាភិបាលមានសមាជិក ១១រូប ដែលមានសមាសភាពដូចតទៅ ៖

| | |
|---|---|
| - តំណាងក្រសួងអប់រំយុវជន និងកីឡា | ប្រធាន |
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| - តំណាងក្រសួងធម្មការ និងសាសនា | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - តំណាង សាកលវិទ្យាល័យ និងមហាវិទ្យាល័យនានា ពីររូប | សមាជិក |

- អ្នកស្រាវជ្រាវវិទ្យាសាស្ត្រ ពីររូប　　　　សមាជិក
- នាយកវិទ្យាស្ថាន　　　　សមាជិកស្វ័យប្រវត្តិ
- តំណាងបុគ្គលិកវិទ្យាស្ថាន　　　　សមាជិកស្វ័យប្រវត្តិ

ខ . ប្រធាននិងសមាជិកក្រុមប្រឹក្សាភិបាល ក្រៅពីសមាជិកស្វ័យប្រវត្តិ ត្រូវបានតែងតាំងឡើងដោយអនុក្រឹត្យសំរាប់រយៈពេល៣ឆ្នាំ ។ អាណត្តិនេះអាចបន្តជាថ្មីទៀតបាន ហើយអាចបញ្ចប់គ្រប់ពេលវេលាដោយអនុក្រឹត្យ តាមសំណើនៃក្រសួង ឬអាជ្ញាធរដែលខ្លួនតំណាងអោយ ។

មាត្រា៦

ក . ក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានភាសាជាតិ ត្រូវធ្វើការប្រជុំ នៅពេលណាដែលផលប្រយោជន៍របស់វិទ្យាស្ថានភាសាជាតិតំរូវ និងត្រូវធ្វើការប្រជុំយ៉ាងតិចមួយត្រីមាសម្តងតាមការអញ្ជើញរបស់ប្រធានឬតាមសំណើរបស់សមាជិកប្រាំពីរនាក់ ឬតាមសំណើស្នើសុំពីនាយកនៃវិទ្យាស្ថានភាសាជាតិ។ របៀបវារៈព្រមទាំងឯកសារទាំងឡាយ ត្រូវផ្ញើជូនគ្រប់សមាជិកនៃក្រុមប្រឹក្សាភិបាល និងគ្រប់ក្រសួងពាក់ព័ន្ធ ដែលមានចែងក្នុងអនុក្រឹត្យនេះ យ៉ាងតិចដប់ថ្ងៃមុនថ្ងៃប្រជុំ ។

- សមាជិកម្នាក់ៗ ពុំអនុញ្ញាតឱ្យមានតំណាងឡើយ ហើយក្នុងករណីដែលមានអវត្តមានបីដងដោយគ្មានមូលហេតុសមាជិកនោះ ត្រូវបានចាត់ទុកជាស្វ័យប្រវត្តិថា បានលាលែងពីតំណែងហើយ។

ខ. ការប្រជុំក្រុមប្រឹក្សាភិបាល អាចនឹងយកជាការបាន លុះត្រាតែមានសមាជិកវត្តមាន ចំនួនប្រាំមួយរូបយ៉ាងតិច នៃបណ្តាសមាជិកទាំងអស់ ។ ប្រសិនបើ វត្តមានចំនួនសមាជិកប្រជុំ មិនគ្រប់ចំនួនតាមការកំណត់ក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំម្តងទៀត យ៉ាងយូរប្រាំបីថ្ងៃក្រោយថ្ងៃកោះប្រជុំលើកទីមួយ ។ ការប្រជុំលើកក្រោយនេះមិនចាំបាច់តំរូវឱ្យមានគ្រប់កូរ៉ុមឡើយ ហើយត្រូវពិភាក្សាតែទៅលើរបៀបវារៈ នៃការកោះអញ្ជើញប្រជុំលើកទីមួយ ។ សមាជិកវត្តមានត្រូវចុះហត្ថលេខាលើបញ្ជីវត្តមាន ។ សេចក្តីសំរេចទាំងឡាយអាចយកជាការបាន លុះត្រាតែមានការអនុម័ត ដោយសំលេងភាគច្រើន នៃសមាជិកវត្តមាន។ ក្នុងករណីមានសំលេងស្មើគ្នា សំលេងប្រធានក្រុមប្រឹក្សាភិបាល ចាត់ទុកជា ឧត្តមានុភាព ។

គ . សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល និងនាយកវិទ្យាស្ថានភាសាជាតិ ដែលមានតួនាទីជាលេខានៃសម័យប្រជុំ ហើយត្រូវតំកល់ទុកនៅទីស្នាក់ការ របស់វិទ្យាស្ថាន ។ សេចក្តីសំរេចនិងកំណត់ហេតុ នៃអង្គប្រជុំក្រុមប្រឹក្សាភិបាល ត្រូវផ្ញើជូនគ្រប់សមាជិក និងក្រសួងពាក់ព័ន្ធទាំងឡាយ យ៉ាងយូរ១០ថ្ងៃ ក្រោយពេលប្រជុំ ។

ឃ. ក្រុមប្រឹក្សាភិបាលអាចអញ្ជើញ ឥស្សរជន នៅក្នុង ឬក្រៅវិទ្យាស្ថាន ឬអង្គការនានា មកចូលរួម ប្រជុំ ។ ឥស្សរជនទាំងនេះ មានសិទ្ធិផ្តល់មតិ តែពុំមានសិទ្ធិសំរេចឡើយ ។

មាត្រា៧

ក. តាមសំណើរបស់ក្រុមប្រឹក្សាភិបាល រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអ្នកសំរេច ជាគោលការណ៍ចំពោះលាភការ នៃមុខងាររបស់សមាជិកក្រុមប្រឹក្សាភិបាលវិទ្យាស្ថានភាសាជាតិ និងកំណត់ទឹកប្រាក់ដែលត្រូវផ្តល់ជូន ។

ខ. ការផ្តល់លាភការអាចត្រូវផ្អាក ដោយអាជ្ញាធរដែលជាអ្នកស្នើតែងតាំង ចំពោះគ្រប់សមាជិកក្រុម - ប្រឹក្សាភិបាល ដែលពុំគោរព នូវកាតព្វកិច្ចនៃអាណត្តិរបស់ខ្លួន :

១ - ការខស្បាហ៍ព្យាយាម

២ - គោរពបទបញ្ញត្តិនៃច្បាប់ បទបញ្ជារបស់វិទ្យាស្ថាន

៣ -មិនបានបំពេញភារកិច្ច តាមចំណាត់តាំងរបស់ខ្លួន

៤ -កាតព្វកិច្ចរាយការណ៍ពីសកម្មភាពការងាររបស់ខ្លួន

មាត្រា៨

ក្រុមប្រឹក្សាភិបាលត្រូវ :

- កំណត់ទិសដៅ គោលនយោបាយ ផែនការ និងសកម្មភាពដែលទាក់ទងទៅនឹងកិច្ចការ របស់វិទ្យាស្ថាន
- សំរេចលើចំណូល និងចំណាយប្រចាំឆ្នាំ និងលើថវិកាប្រចាំឆ្នាំ របស់វិទ្យាស្ថាន
- ពិនិត្យសំរេចលើរបាយការណ៍ គ្រប់គ្រង និងលើគណនី ហិរញ្ញវត្ថុ ប្រចាំឆ្នាំ
- កំណត់ការរៀបចំរចនាសម្ព័ន្ធ និងភារកិច្ចទូទៅរបស់វិទ្យាស្ថាន
- មានសិទ្ធិបង្កើតគណៈកម្មការ ប្រសិនបើមានការចាំបាច់
- កំណត់នូវបែបបទធ្វើការជ្រើសរើស ការតំឡើងឋានន្តរសក្តិ ឬការផ្តល់លាភការ ដោយពុំប៉ះ - ពាល់ ដល់បទបញ្ញត្តិនៃច្បាប់ ឬបទបញ្ជាពាក់ព័ន្ធ ដល់ប្រយោជន៍ បុគ្គលិក របស់វិទ្យាស្ថាន
- សំរេចលើក្របខ័ណ្ឌ ចំនួនបុគ្គលិក ដែលអនុញ្ញាតសំរាប់វិទ្យាស្ថាន
- ទទួលខុសត្រូវលើការទទួល វិភាគទាន ការខ្ចីបុលផ្សេងៗ និងលើកិច្ចសន្យាផ្សេងៗ
- ពិនិត្យសំរេចលើការទិញដូរអចលនទ្រព្យ និងចលនទ្រព្យគ្រប់ប្រភេទដែលចាំបាច់ សំរាប់ដំណើរការរបស់ខ្លួន ក្នុងក្របខ័ណ្ឌច្បាប់អនុញ្ញាត

- ពិនិត្យ និងអនុម័តបទបញ្ជាផ្ទៃក្នុងរបស់វិទ្យាស្ថាន
- ខិតខំធ្វើសហប្រតិបត្តិការលើគ្រប់ផ្នែក ក្នុងនិងក្រៅប្រទេស ដើម្បីអភិវឌ្ឍន៍វិទ្យាស្ថាន ។
-ធ្វើការវាយតំលៃ តាមចន្លោះពេលទៀងទាត់ នូវលទ្ធផលសំរេចបាន និងលើវិធានការកែតំរូវសំរាប់អនុវត្ត ។

## ផ្នែកទី២

## អង្គការប្រតិបត្តិរបស់វិទ្យាស្ថានភាសាជាតិ

### មាត្រា ៩

វិទ្យាស្ថានភាសាជាតិ ត្រូវគ្រប់គ្រងដោយនាយកមួយរូប ដែលតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ។ នាយកអាចត្រូវបានបញ្ឈប់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដោយផ្អែកលើសំណូមពររបស់ក្រុមប្រឹក្សាភិបាល។

### មាត្រា ១០

ក . នាយកមានសិទ្ធិពេញលេញ ដើម្បីគ្រប់គ្រងវិទ្យាស្ថាន លើកលែងតែសិទ្ធិ ដែលមានចែងក្នុងមាត្រា៨ ខាងលើ ដែលជាសមត្ថកិច្ចផ្ទាល់របស់ក្រុមប្រឹក្សាភិបាល ។

ខ . នាយកជាតំណាងវិទ្យាស្ថានចំពោះមុខតតិយជនទាំងឡាយ ។

គ . នាយកត្រូវ :

- រៀបចំសំណុំឯកសារទាំងឡាយ ដើម្បីដាក់ជូនអង្គប្រជុំ នៃក្រុមប្រឹក្សាភិបាល
- ទទួលបន្ទុកចាត់ចែង ការអនុវត្តនូវសេចក្តីសំរេច និងគោលនយោបាយ របស់ក្រុមប្រឹក្សាភិបាល ហើយត្រូវរាយការណ៍ពីការអនុវត្ត ខាងលើនេះ ជូនក្រុមប្រឹក្សាភិបាល
- រៀបចំគំរោងថវិកាប្រចាំឆ្នាំ របស់វិទ្យាស្ថានដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាល
- ធ្វើរបាយការណ៍លើការគ្រប់គ្រង ត្រួតពិនិត្យគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ដើម្បីបញ្ជូនទៅក្រុមប្រឹក្សាភិបាល
- គ្រប់គ្រងបុគ្គលិក ឈរលើចំនួនដែលកំណត់ ដោយក្រុមប្រឹក្សាភិបាល និងដោយគោរពតាមវិធាន នៃការគ្រប់គ្រងបុគ្គលិក

- ចុះអនុសញ្ញានិងកិច្ចសន្យា ស្របតាមការប្រគល់សិទ្ធិ ពីក្រុមប្រឹក្សាភិបាលស្របតាមបទបញ្ជាផ្ទៃក្នុង និងស្របតាមបទបញ្ញត្តិ ដែលពាក់ព័ន្ធក្នុងករណីនេះ

- អនុវត្តនូវគ្រប់ភារកិច្ច ដែលក្រុមប្រឹក្សាភិបាលប្រគល់ឱ្យ ឬមានចែងក្នុងបទបញ្ជាផ្ទៃក្នុង ។

ឃ . នាយកត្រូវស្នើទៅរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាសុំតែងតាំងនាយករងមួយរូប ឬច្រើនរូប ដើម្បីជួយការងាររបស់ខ្លួន ។

ង . នាយកទទួលបន្ទុកទាក់ទង ជាមួយនឹងអង្គការជាតិ និងអន្តរជាតិ ។

## ជំពូកទី៣

## បុគ្គលិករបស់វិទ្យាស្ថានភាសាជាតិ

### មាត្រា ១១

ក . បុគ្គលិកអចិន្ត្រៃយ៍របស់វិទ្យាស្ថាន រួមមានមន្ត្រីរាជការក្របខ័ណ្ឌ ដែលរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ឬអាជ្ញាធរមានសមត្ថកិច្ច ផ្ទេរមកធ្វើការនៅក្នុងវិទ្យាស្ថាន ដោយមានការយល់ព្រមពីនាយក ។ មន្ត្រីទាំងនេះ រក្សាទុកនូវប្រាក់បៀវត្សដើម ស្របតាមកាំប្រាក់បៀវត្សនៃមុខងារសាធារណៈ ព្រមទាំងទទួលលាភការ ពីស្ថាប័នដើមរបស់ខ្លួន ។

ខ . ក្រៅពីនេះវិទ្យាស្ថានអាចជ្រើសរើសបុគ្គលិក អ្នកជំនួយការ អ្នកឯកទេស និងអ្នកស្រាវជ្រាវជាតិ និងអន្តរជាតិដោយកិច្ចសន្យា ។ បុគ្គលិកទាំងនេះពុំអាចទទួលលក្ខណៈសម្បត្តិ ជាភ្នាក់ងាររាជការក្របខ័ណ្ឌឡើយ ។ ការគ្រប់គ្រងបុគ្គលិកទាំងអស់នេះ ស្ថិតនៅក្រោមបទបញ្ជាផ្ទៃក្នុង និងសេចក្តីសំរេចរបស់ ក្រុមប្រឹក្សាភិបាល ។

គ . លាភការលើកទឹកចិត្ត អាចផ្តល់ជូនដល់បុគ្គលិកសកម្ម ស្របតាមបទបញ្ជាផ្ទៃក្នុង និងការសំរេចរបស់ក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថានភាសាជាតិ ។

### មាត្រា ១២

បុគ្គលិកនៃវិទ្យាស្ថានភាសាជាតិ ត្រូវទទួលធ្វើការងារពិសេស ទាក់ទងនឹងតំរូវការ របស់វិទ្យាស្ថានក្នុងឋានៈជាអ្នកផ្តល់សេវាសាធារណៈ ។

### មាត្រា ១៣

បុគ្គលិករបស់វិទ្យាស្ថានភាសាជាតិ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រង នៃបទបញ្ជាស្តីពីបុគ្គលិក

ដែលសំរេចដោយក្រុមប្រឹក្សាភិបាល ។

ចំពោះមន្ត្រីរាជការនៃមុខងារសាធារណៈ បទបញ្ញាស្តីពីបុគ្គលិកនេះមិនត្រូវជំនួសពីបទបញ្ញត្តិទាំងឡាយនៃច្បាប់ និងអនុបទពាក់ព័ន្ធដទៃទៀត របស់មន្ត្រីរាជការឡើយ ។

## ផ្នែកទី ៤
## ទ្រព្យសម្បត្តិរបស់វិទ្យាស្ថានភាសាជាតិ

### មាត្រា ១៤

ក . វិទ្យាស្ថានភាសាជាតិ ត្រូវទទួលគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ តាមការប្រគល់ឱ្យពីក្រសួងអប់រំ យុវជន និង កីឡា និងតាមល័ក្ខខ័ណ្ឌកំណត់ ក្នុងបទបញ្ញត្តិទាំងឡាយស្តីពីបញ្ហានេះ ។

ខ . វិទ្យាស្ថានភាសាជាតិអាចមានថវិកា និងទ្រព្យសម្បត្តិផ្ទាល់ខ្លួន ហើយអាចទទួលយកនូវអំណោយ និងមរតកពីសប្បុរសជន ។

## ផ្នែកទី ៥
## ការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ និងគណនេយ្យនៃវិទ្យាស្ថានភាសាជាតិ

### មាត្រា ១៥

លើកលែងតែមានបទបញ្ញត្តិដោយឡែក ដែលមានចែងនៅក្នុងអនុក្រឹត្យ ស្តីពីការបង្កើតវិទ្យាស្ថានភាសាជាតិ ត្រូវស្ថិតនៅក្រោមគោលការណ៍ នៃគណនេយ្យសាធារណៈ លើការគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ និងគណនេយ្យដូចដែលមានកំណត់ក្នុងមាត្រា ១២២ នៃអនុក្រឹត្យលេខ ៨២ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅ នៃគណនេយ្យសាធារណៈ ។

### មាត្រា ១៦

ក . នាយកជាអាណាប័កដើមខ្សែរបស់វិទ្យាស្ថាន។ ក្នុងន័យនេះដើម្បីអនុលោមតាមបទបញ្ជាផ្ទៃក្នុង របស់វិទ្យាស្ថាន នាយកត្រូវមានភារកិច្ច :

- ពិនិត្យកត់ត្រា និងទូទាត់ចំណូល
- ចាត់ចែងធ្វើការទូទាត់ និងចេញបញ្ជាចំណាយ ។

ខ . ក្នុងការចំណាយរបស់វិទ្យាស្ថាន អាណាប័កដើមខ្សែ អាចផ្ដល់សិទ្ធិប្រទានឱ្យទៅ អាណាប័កផ្ទេរសិទ្ធិ ឬអាណាប័កដើមខ្សែ អាចបង្កើតផ្នែកគ្រប់គ្រងផ្ទេរថវិកាចំណូល ឬបុរេប្រទាន ដោយមានការយល់ព្រមពីគណនេយ្យកររបស់វិទ្យាស្ថាន ។

មាត្រា ១៧

ក. ប្រតិបត្តិការហិរញ្ញវត្ថុ និងការកាន់កាប់គណនេយ្យ ត្រូវអនុវត្តដោយអនុលោមតាមបទបញ្ជាផ្ទៃក្នុងរបស់វិទ្យាស្ថាន ក្រោមការទទួលខុសត្រូវផ្ទាល់ របស់គណនេយ្យករ ។

គណនេយ្យករនេះ ត្រូវតែងតាំងឡើងដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយ ត្រូវធ្វើសច្ចាប្រណិធានមុនចូលកាន់ការងារ ហើយត្រូវចូលរួមក្នុងការប្រជុំ របស់ក្រុមប្រឹក្សាភិបាល ក្នុងឋានៈ ជាអ្នកពិគ្រោះយោបល់ ។

គណនេយ្យករនេះ ជាអ្នកទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុរបស់វិទ្យាស្ថាន ហើយត្រូវស្ថិតនៅក្រោមឱវាទផ្ទាល់ របស់នាយកវិទ្យាស្ថាន ។

ខ . គណនេយ្យករមានភារកិច្ច ៖

- ប្រមូលចំណូល
- បើកប្រាក់ចំណាយ
- រក្សាទុក និងចាត់ចែងប្រើប្រាស់ នូវមូលនិធិ និងវត្ថុមានតំលៃ
- រក្សាទុកនូវលិខិតយុត្តិការ និងកាន់កាប់បញ្ជីគណនេយ្យ ។

គ . គណនេយ្យករ អាចផ្ទេរសិទ្ធិខ្លះឱ្យទៅមន្ត្រីក្នុងការិយាល័យ ។

មាត្រា ១៨

ក . ប្រភពធនធានរបស់វិទ្យាស្ថានភាសាជាតិរួមមាន ៖

- ធនធានដំបូងដែលរដ្ឋផ្ដល់ដល់វិទ្យាស្ថាន នៅពេលចាប់ផ្ដើមបង្កើតដំបូង
- ការផ្ទេរក្នុងលក្ខណៈជាអន្តរាគមន៍សាធារណៈ ដែលមានចែងនៅក្នុងថវិការដ្ឋ

ដូចជា ឧបត្ថម្ភធនធាន សំរាប់ដំណើរការ និងឧបត្ថម្ភធនធានជាមូលធន

- អំណោយ និងអច្ច័យទានដែលវិទ្យាស្ថានបានទទួល
- ផលនៃការងារ និងការផ្ដល់សេវាដោយវិទ្យាស្ថាន
- កំរៃនៃការជួល និងលក់ទ្រព្យសម្បត្តិ និងឧបករណ៍ដែលវិទ្យាស្ថានមាន ។

ខ . ចំណូល និងចំណាយជាប្រចាំ និងជាមូលធនរបស់វិទ្យាស្ថានភាសាជាតិ ត្រូវបានគ្រោងទុកក្នុងថវិកាប្រចាំឆ្នាំ របស់វិទ្យាស្ថាន ។ ក្រុមប្រឹក្សាភិបាលរបស់វិទ្យាស្ថាន ត្រូវចែងអំពីបែបបទនៃការរៀបចំ ការចាត់ចែង និងការអនុវត្តថវិកា។ សេចក្តីសំរេចទាំងឡាយ របស់ក្រុមប្រឹក្សាភិបាលទាក់ទង ដល់ទំរង់បែបបទនៃការរៀបចំ ការចាត់ចែង និងការអនុវត្តថវិកា ត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

គ . ថវិកាត្រូវរៀបចំដោយអាណាប័កដើមខ្សែ ហើយដាក់ជូនក្រុមប្រឹក្សាភិបាល ដែលត្រូវធ្វើការសំរេចយ៉ាងយូរ ត្រឹមថ្ងៃទី៣០ ខែកញ្ញា ក្នុងឆ្នាំនីមួយៗ ។ ថវិកាត្រូវតែធ្វើឱ្យមានលំនឹង រវាងចំណូល និងចំណាយ ។

## មាត្រា ១៩

ក . ការងារគណនេយ្យរបស់វិទ្យាស្ថានភាសាជាតិរួមមាន ៖

- គណនេយ្យទូទៅកាន់កាប់ ជាគណនេយ្យទ្វេភាគ ដែលចែងអំពីប្រតិបត្តិការថវិកា រតនាគារ និងប្រតិបត្តិការដែលអនុវត្តជាមួយតតិយជន
- គណនេយ្យអសង្ហារឹម រូបធាតុ និងគណនេយ្យតំលៃ
- គណនេយ្យវិភាគប្រសិនបើជាការចាំបាច់

គណនេយ្យរបស់វិទ្យាស្ថានត្រូវ :

១ . ស្របតាមវិធានដែលកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

២ . គោរពតាមប្លង់គណនេយ្យ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ខ . គណនីហិរញ្ញវត្ថុប្រចាំឆ្នាំរបស់វិទ្យាស្ថាន ត្រូវរៀបចំឡើងដោយគណនេយ្យករ ហើយត្រូវដាក់ជូន អាណាប័កដើមខ្សែ ភ្ជាប់ជាមួយរបាយការណ៍គ្រប់គ្រងជូន ក្រុមប្រឹក្សាភិបាលពិនិត្យ និងសំរេចលើឯកសារ ទាំងនោះ យ៉ាងយូរ៣ខែ ក្រោយការបិទការិយបរិច្ឆេទគណនេយ្យ ។

## មាត្រា ២០

មូលនិធិរបស់វិទ្យាស្ថានភាសាជាតិ គឺជាមូលនិធិសាធារណៈដែលត្រូវដាក់ចូលក្នុងគណនីមួយ នៅរតនាគារជាចាំបាច់ លើកលែងតែមានបដិប្បញ្ញត្តិ ដែលត្រូវមានការយល់ព្រមតាមប្រកាស របស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## មាត្រា ២១

ការប្រើប្រាស់នូវប្រាក់ដែលលើស របស់វិទ្យាស្ថានភាសាជាតិ ត្រូវសំរេចដោយក្រុមប្រឹក្សាភិបាល ។

ក្រោយពីមានការឯកភាព លើគណនីដោយក្រសួងអប់រំ យុវជន និងកីឡា ។ ធនធានដែលលើសនេះ អាចធ្វើបណ្តាក់ទុន ឬចងការ តែត្រូវមានការយល់ព្រមពីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា២២

- វិទ្យាស្ថានភាសាជាតិ មានបុព្វសិទ្ធិក្នុងការប្រមូលចំណូល ការសងបំណុល និងការការពារទ្រព្យសម្បត្តិរដ្ឋ ក្នុងក្របខ័ណ្ឌច្បាប់ ។

- វិទ្យាស្ថានភាសាជាតិ ត្រូវអនុញ្ញាតឱ្យមានគណនីនៅធនាគារណាមួយ ដើម្បីទទួលប្រាក់ចំណូលរបស់ខ្លួន ។

## ផ្នែកទី ៦

## របបសារពើពន្ធនៃវិទ្យាស្ថានភាសាជាតិ

មាត្រា ២៣

លើកលែងតែមានបទប្បញ្ញត្តិ ដែលចែងដោយច្បាប់ វិទ្យាស្ថានភាសាជាតិ ត្រូវស្ថិតនៅក្រោមនីតិរបបចំពោះរបបសារពើពន្ធ ដូចដែលត្រូវបានអនុវត្តលើអង្គភាពនានារបស់រដ្ឋ ។

## ផ្នែកទី៧

## លទ្ធកម្មរបស់វិទ្យាស្ថានភាសាជាតិ

មាត្រា ២៤

ការសំរេច ការអនុវត្តនិងការត្រួតពិនិត្យ លើលទ្ធកម្ម ក្នុងវិទ្យាស្ថានភាសាជាតិ ត្រូវគ្រប់គ្រងដោយបទបញ្ញត្តិ នៃអនុក្រឹត្យលេខ ៦០ អនក្រ ចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ១៩៩៥ ស្តីពី លទ្ធកម្មសាធារណៈ និងបទបញ្ជាដទៃទៀតពាក់ព័ន្ធ នឹងបញ្ហានេះ ។

## ជំពូក III

## អាណាព្យាបាលភាព

មាត្រា ២៥

វិទ្យាស្ថានភាសាជាតិត្រូវស្ថិតនៅក្រោម ៖

១ . អាណាព្យាបាលបច្ចេកទេស របស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដែលទទួលបន្ទុកផ្នែកសកម្មភាពនៃវិទ្យាស្ថាន ។

២ . អាណាព្យាបាលហិរញ្ញវត្ថុ របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ២៦

ក . វិទ្យាស្ថានភាសាជាតិ ត្រូវផ្តល់ជូនគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលមានចែងនៅក្នុងមាត្រា ៣៤ នូវឯកសារដូចតទៅ :

- កំណត់ហេតុ នៃការប្រជុំក្រុមប្រឹក្សាភិបាល
- ផែនការពង្រីកវិទ្យាស្ថាន
- ថវិកាប្រចាំឆ្នាំ
- របាយការណ៍ស្ដីពីការគ្រប់គ្រង និងគណនី ហិរញ្ញវត្ថុប្រចាំឆ្នាំ

ខ . ឯកសារទាំងនេះ ត្រូវបញ្ជូនទៅអ្នកដែលត្រូវទទួល ក្នុងរយះពេលមិនឱ្យហួសពី ១៥ថ្ងៃ ក្រោយថ្ងៃប្រជុំ និងថ្ងៃដែលបានទទួលការយល់ព្រម ។

## ផ្នែកទី ១

## អាណាព្យាបាលបច្ចេកទេស

មាត្រា ២៧

ក . ក្នុងរយះពេល ១៥ថ្ងៃ បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាល ប្រធាន ឬនាយក ត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវកម្មវិធីអភិវឌ្ឍន៍ និងគំរោងថវិកា ដើម្បីសុំការយល់ព្រម ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរយះពេលមួយខែ គិតចាប់ ពីថ្ងៃដែលបានទទួលឯកសារត្រូវរៀបចំយោបល់របស់ខ្លួនជូនរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ។ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា មានរយះពេលពីរខែ គិតចាប់តាំងពីថ្ងៃដែលបានទទួលឯកសារ ដែលបញ្ជូនដោយប្រធានឬនាយក ត្រូវផ្តល់ការយល់ព្រមលើឯកសារទាំងនោះ ។

ខ . លិខិតយល់ព្រម ត្រូវចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាឬអ្នកតំណាង ហើយត្រូវផ្ញើជូនប្រធានឬនាយក ដោយមានចំលងជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ប្រធានឬនាយកត្រូវជូនពត៌មាននេះ ទៅក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត ។

ក្នុងករណីរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា មិនបានឆ្លើយតប តាមរយៈពេលកំណត់ទេនោះ កម្មវិធីអភិវឌ្ឍន៍ ឬគំរោងថវិកា ត្រូវចាត់ទុកថា បានទទួលការឯកភាព ហើយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវចេញ លិខិតយល់ព្រមជូនជាស្វ័យប្រវត្តិ។

ប្រសិនបើរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការជំទាស់លើកម្មវិធីអភិវឌ្ឍន៍ឬគំរោងថវិកានេះ ក្នុងរយៈពេលកំណត់ដូចមានចែងក្នុងចំណុច ក ខាងលើនៃមាត្រានេះ ប្រធានក្រុមប្រឹក្សាភិបាលត្រូវរៀបចំការប្រជុំក្រុមប្រឹក្សាភិបាលជាបន្ទាន់ ដើម្បីពិភាក្សា និងរិះរកមធ្យោបាយសំរាប់ដោះស្រាយការជំទាស់ទាំងនេះ ។

កម្មវិធីអភិវឌ្ឍន៍ និងថវិកាចំណាយ ជាមូលធនមិនអាចដាក់ឱ្យអនុវត្តបានឡើយ ក្នុងករណី ដែលការជំទាស់លើកឡើងដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ពុំទាន់ត្រូវបានដោះស្រាយរួចនៅឡើយនោះ ។

ថវិកាចំណាយជាប្រចាំ អាចដាក់ឱ្យអនុវត្តត្រឹមលំនាំប្រព័ន្ធ បំបែកជា " ដប់ពីរ " ប៉ុណ្ណោះ នៅពេលដែលនៅមានការជំទាស់ ពីរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ២៨

ក. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក្នុងក្របខ័ណ្ឌនៃសិទ្ធិធ្វើការជំទាស់របស់ខ្លួន អាចលើកឡើងនូវការជំទាស់លើឯកសារ ដែលត្រូវបានបញ្ជូនមកខ្លួន ដូចមានចែងក្នុងមាត្រា២៦ខាងលើមាន :

កំណត់ហេតុ ប្រជុំរបស់ក្រុមប្រឹក្សាភិបាល របាយការណ៍លើការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ។

ខ .ប្រធានឬនាយកត្រូវជំរាបជូនដល់ក្រុមប្រឹក្សាភិបាល នូវខ្លឹមសារនៃការជំទាស់ ដែលបានលើកឡើងដោយ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ។

ក្រុមប្រឹក្សាភិបាល ត្រូវធ្វើការពិភាក្សាឱ្យបានឆាប់បំផុត លើការជំទាស់របស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងរិះរកមធ្យោបាយ សំរាប់ដោះស្រាយការជំទាស់ទាំងនោះ ។ ប្រសិនបើក្រុមប្រឹក្សាភិ - បាល សំរេចពុំឯកភាពតាមការជំទាស់នោះ សេចក្តីសំរេចនេះត្រូវបញ្ជាក់ពីមូលហេតុ ហើយត្រូវជំរាបជូនដំណឹងជាបន្ទាន់ភ្លាម ស្តីពីបញ្ហានេះជាលាយលក្ខណ៍អក្សរ ដល់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ។ រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងខាងលើនេះ ត្រូវធ្វើការប្រជុំ

ប្រធាន ក្រុមប្រឹក្សាភិបាល សមាជិកក្រុមប្រឹក្សាភិបាល ជាតំណាងទីស្ដីការគណៈរដ្ឋមន្ត្រី នាយកវិទ្យាស្ថាន និងតំណាង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីដោះស្រាយបញ្ហានេះក្នុងរយៈពេល១០ថ្ងៃយ៉ាងយូរ ។

មាត្រា ២៩

ក . រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អាចធ្វើការលុបឬផ្អាកទុក នូវសេចក្ដីសំរេចរបស់ក្រុមប្រឹក្សាភិបាល ប្រធាន ឬ នាយក ក្នុងករណីដែលសេចក្ដីសំរេចនោះ ៖

- ផ្ទុយនឹងគោលដៅ របស់វិទ្យាស្ថាន
- ផ្ទុយនឹងច្បាប់ និងបទបញ្ជា
- ធ្វើឡើងដោយអាជ្ញាធរមួយ ដែលមិនមានសិទ្ធិសំរេច ឬធ្វើឡើងដោយការប្រជុំពុំស្របច្បាប់របស់ក្រុមប្រឹក្សាភិបាល ។

ខ . ការលុបចោល ឬផ្អាកទុកនេះ ត្រូវសំរេចឡើងតាមប្រកាសរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដោយមានបញ្ជាក់ពីមូលហេតុ តាមគំនិតផ្ទាល់ខ្លួនរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ឬតាមបណ្ដឹងពីភាគីនានាដែលពាក់ព័ន្ធ ។ ការលុបចោល ឬផ្អាកទុក នូវសេចក្ដីសំរេចនេះត្រូវជូនដំណឹងដល់ប្រធានឬនាយក ហើយប្រធានឬនាយក ត្រូវជូនពត៌មានបន្តទៅក្រុមប្រឹក្សាភិបាល ក្នុងរយៈពេលដ៏ឆាប់បំផុត ។

មាត្រា ៣០

ក្នុងករណីដែលក្រុមប្រឹក្សាភិបាល ប្រធានឬនាយកពុំប្រតិបត្តិតាមបណ្ដាវិធាន ដែលមានចែងក្នុងអត្ថបទច្បាប់ឬបទបញ្ញត្តិ និងបទបញ្ជាផ្ទៃក្នុងរបស់វិទ្យាស្ថាន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បន្ទាប់ពីធ្វើការណែនាំ និងដាក់កំហិតជាលាយលក្ខណ៍អក្សរមក អាចចាត់ចែងការងារ និងចេញសេចក្ដីសំរេចខាងលើ ហើយអាចប្រើប្រាស់នូវវិធានការចាំបាច់ទាំងអស់ ។

មាត្រា ៣១

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាអាចចាត់ចែងឡើង នូវការធ្វើរង្វាត់អធិការកិច្ច ឬការត្រួតពិនិត្យការងារ ក្នុងវិទ្យាស្ថានភាសាជាតិ ក្នុងករណីដែលយល់ថា ជាការចាំបាច់ស្របតាមល័ក្ខខ័ណ្ឌ និងបែបបទ ដែលមានចែងក្នុងច្បាប់ និងបទបញ្ញត្តិដែលមានជាធរមាន ។

## ផ្នែកទី២
## ការគ្រប់គ្រងហិរញ្ញវត្ថុ

មាត្រា ៣២

ក . ក្នុងរយៈពេល១៥ថ្ងៃបន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាល ប្រធានឬនាយកត្រូវធ្វើរបាយការណ៍ ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ។ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាមានរយៈពេលមួយខែ គិតចាប់ពីថ្ងៃទទួលឯកសារ ដើម្បីផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានរយៈពេលពីរខែ គិតចាប់ពីថ្ងៃទទួលឯកសារដែលបញ្ជូនមកដោយប្រធានឬនាយក ដើម្បីផ្តល់ការយល់ព្រមលើឯកសារទាំងនោះ ។

ខ . លិខិតយល់ព្រមដែលចុះហត្ថលេខាត្រឹមត្រូវ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអ្នកតំណាង ត្រូវផ្ញើជូន ប្រធានឬនាយក ដោយមានចំលងជូនរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ។ ប្រធានឬនាយក ត្រូវជំរាបដំណឹងនេះ ជូនក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត ។ ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមិនបានឆ្លើយតាមរយៈពេលកំណត់ របាយការណ៍លើការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវចាត់ទុកថាបានទទួលការឯកភាព ហើយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចេញលិខិតយល់ព្រម ជូនជាស្វ័យប្រវត្តិ។

ប្រសិនបើរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានធ្វើការជំទាស់លើរបាយការណ៍ ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ ប្រធានក្រុមប្រឹក្សាភិបាល ត្រូវរៀបចំធ្វើការប្រជុំក្រុមប្រឹក្សាភិបាល ឱ្យបានឆាប់បំផុត ដើម្បីពិភាក្សានិងរិះរកមធ្យោបាយ សំរាប់ដោះស្រាយការជំទាស់ទាំងនេះ ។ របាយការណ៍ស្តីពីការគ្រប់គ្រង និងគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ មិនអាចសំរេចយល់ព្រមបានឡើយ ក្នុងករណីដែលមានការជំទាស់ដែលលើកឡើង ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពុំទាន់ត្រូវបានដោះស្រាយរួចនៅឡើយនោះ ។

មាត្រា ៣៣

សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាល ប្រធានឬនាយកត្រូវដាក់សុំការអនុញ្ញាតជាមុន ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមការផ្តល់យោបល់ ពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុរួមមាន ៖

- សេចក្តីសំរេច ស្តីពីការលក់ ឬផ្ទេរសិទ្ធិអចលនៈទ្រព្យ
- សេចក្តីសំរេចស្តីពីការលើកលែងផលទេយ្យ ដែលមានទឹកប្រាក់លើសពីការកំណត់របស់ប្រកាសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- សេចក្តីសំរេចស្តីពីកិច្ចព្រមព្រៀងខ្ចីប្រាក់ និងកិច្ចព្រមព្រៀងសំរាប់ការធានាឬលិខិតស្រដៀងគ្នានេះ ។

**មាត្រា ៣៤**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុធ្វើការតែងតាំងប្រចាំវិទ្យាស្ថានភាសាជាតិ នូវមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុមួយរូប ដែលត្រូវមានភារកិច្ចធ្វើការត្រួតពិនិត្យជាមុន និងជាក្រោយលើវិទ្យាស្ថានដូចមានចែងក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតឡើងនូវការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិកាតាមក្រសួង អង្គភាពមូលដ្ឋានតាមបណ្តាខេត្ត-ក្រុង និងតាមអង្គភាពសាធារណៈដែលមានលក្ខណៈរដ្ឋបាល ។

**មាត្រា ៣៥**

ក . ការគ្រប់គ្រងរបស់អាណាប័កដើមខ្សែ លើវិទ្យាស្ថានភាសាជាតិ ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់អធិការដ្ឋានហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ខ . ការគ្រប់គ្រងរបស់គណនេយ្យករ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ របស់គណនេយ្យករកណ្តាលនៃរតនាគារជាតិ និងក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុ ។

គ . រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចាត់ចែងធ្វើការជ្រៀងជ្រាត់អធិការកិច្ច ឬការត្រួតពិនិត្យលើវិទ្យាស្ថានភាសាជាតិ នៅពេលដែលយល់ថាចាំបាច់ស្របតាមល័ក្ខខ័ណ្ឌ និងបែបបទដែលមានចែងក្នុងច្បាប់ និងបទបញ្ញត្តិដែលមានជាធរមាន ។

## ជំពូកទី IV
## អវសានបញ្ញត្តិ

**មាត្រា៣៦**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣៧**

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

មាត្រា ៣៨

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡានិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តឱ្យបានសំរេចនូវអនុក្រឹត្យនេះ ។

រាជធានី ភ្នំពេញ ថ្ងៃទី ១៩ [illegible] ឆ្នាំ ១៩៩៨

នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២

អ៊ឹង ហួត | ហ៊ុន សែន

រាជធានីភ្នំពេញ ថ្ងៃទី២៥ខែមិថុនាឆ្នាំ ១៩៩៨

បានជំរាបជូន

ឯកឧត្តមនាយករដ្ឋមន្ត្រីទី១ និងសម្តេច នាយករដ្ឋមន្ត្រីទី ២

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
រដ្ឋលេខាធិការ,

គាត ឈន់ | គា សាមេន

**កន្លែងទទួល**

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋាន ព្រះបរមរាជវាំង
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រីទី ១
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រីទី ២
- ដូចមាត្រា ៣៨
- ឯកសារ-កាលប្បវត្តិ

# សិលាចារឹកដែលរកឃើញថ្មីរបស់ព្រះបាទសូរ្យវរ្ម័នទីមួយ

(នៅសារមន្ទីរអភិរក្សអង្គរ)

សាស្ត្រាចារ្យបណ្ឌិត ឡុង សៀម

សិលាចារឹករកឃើញថ្មីមួយនាឆ្នាំ ១០១៤ នៃគ.សបានត្រូវសរសេរឡើងនៅលើសិលាស្ដម្ភ ដែលមានកំពស់១.៥១ម ទទឹង ០.៨៥ ម កំរាស់ ១៣ ស.ម ។

សព្វថ្ងៃសិលាចារឹកនេះបានត្រូវគេចុះក្នុងបញ្ជីក្រោមលេខថ្មី៦២៦ហើយបានត្រូវរក្សាទុកនៅ ក្នុងសារមន្ទីរអភិរក្សអង្គរទីក្រុងសៀមរាប ។ បន្ទាប់មកទៀតក្រសួងវប្បធម៌ប្រទេសកម្ពុជាបានចុះបញ្ជីសិលាចារឹកនេះសារជាថ្មីក្នុងលេខ Ka 17 ជាលេខនៅក្នុងបញ្ជី ដែលបានត្រូវរៀបចំឡើងដោយបណ្ឌិតខាងបុរាណវិទ្យា *មីសែល.ត្រាណេ* ។

តាមសេចក្ដីអោយការណ៍របស់អ្នកទទួលខុសត្រូវមួយរូប នៅសារមន្ទីរអភិរក្សអង្គរ គឺលោក *អ៊ុន.ផល្លី* សិលាចារឹក ឆ្នាំ ១០១៤ នៃគ.ស នេះ ដែលគេពុំទាន់ដឹងច្បាស់អំពីប្រភពដើមរបស់វា បានទទួលភ័ព្វវាសនាប្រកបដោយនាដ្យកម្ម មួយដ៏អាណោចអធ័ម ដោយហេតុថា សិលាចារឹកបានត្រូវពួកចោរប្លន់លួចហើយដាក់ក្នុងរថយន្តបរតំរង់ទៅប្រទេសជិតខាងជាមួយចំលាក់ក្លោងទ្វារមួយ (linteau) ព្រមទាំងរូបបដិមាទ្វារបាល(drarapala) ។ជាសំណាងល្អគ្រឿងបេតិកភ័ណ្ឌ ដ៏មានតំលៃបំផុតបានត្រូវទីបញ្ជាការយោធាសៀមរាបចាប់បាន ហើយបានប្រគល់ដ៏ត្រឹមត្រូវដល់សារមន្ទីរអភិរក្សអង្គរ នាឆ្នាំ ១៩៩៤ ។

សិលាចារឹកនេះបានត្រូវចារឡើងនៅសិលាស្ដម្ភទាំងសងខាង ។ នៅលើចំហៀងទី១មួយ រឺ (ផ្នែកA ) មានអក្សរ ៥៧ បន្ទាត់សរសេរឡើងដោយអក្សរក្រមសម័យអង្គរដ៏ល្អឆើតឆាយ ហើយទាំងអស់នេះគឺសរសេរជាភាសាខ្មែរ ទាំងមូល។ នៅលើចំហៀង ទីពីរ នៃសិលាស្ដម្ភ (ផ្នែកB) មាន ៥៩បន្ទាត់ (៣០បន្ទាត់សរសេរជាភាសាខ្មែរ ហើយ២៩ បន្ទាត់សរសេរជាភាសា សំស្ក្រឹត ) ។ អក្សរនៅផ្នែកទីពីរនេះ ពុំសូវល្អដូចជាអក្សរនៅផ្នែកទីមួយទេ ហើយនៅទីនេះអក្សរក្នុងមួយបន្ទាត់នៅលើសិលាស្ដម្ភមានបរិមាណប្រហាក់ប្រហែលគ្នានិងអក្សរបីបន្ទាត់នៅលើបន្ទាត់ក្រដាស់សធម្មតា ។

សិលាចារឹកឆ្នាំ ១០១៤ នៃ គ.ស (រឺ Ka 17) បានត្រូវអាន និង ផតម្លងជាពីរដងដោយអ្នកនិពន្ធនៃនិក្ខេបបទនេះ (បណ្ឌិត ឡុង.សៀម ) ។ ក្រុមនិស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញបានទៅថ្ដាមនៅឆ្នាំ ១៩៩៥ ហើយនៅឆ្នាំ ១៩៩៧ សិលាចារឹកនេះក៏ត្រូវបានថ្ដាមសារជាថ្មីទៀតដោយក្រុមអ្នកស្រាវជ្រាវដឹកនាំដោយបណ្ឌិត *ឡុង.សៀម* និងបណ្ឌិត *មីសែល.ត្រាណេ* នៅពេលជាមួយគ្នានេះក៏សូមបញ្ជាក់ផងដែរថា ក្រោមការដឹកនាំរបស់អ្នកស្រាវជ្រាវទាំងពីររូបនេះ នៅក្នុងក្របខ័ណ្ឌនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងក្រសួងវប្បធម៌ សិលាចារឹកមួយចំនួនធំ បានត្រូវថ្ដាបឡើងជាពិសេសដោយក្រុមនិស្សិត ហើយនៅក្នុងចំនួននេះនៅមានសិលាចារឹកថ្មីៗមួយចំនួនទៀតផង ។ គួរកត់សំគាល់ថា សិលាចារឹកប្រទេសកម្ពុជាចំនួនប្រហែល១២០០ បានត្រូវតំកល់ទុកនៅបណ្ណាល័យ នៃសាលាចុងបូព៌ាបារាំងនៅទីក្រុងប៉ារីស ។

ការសិក្សាតាមសិលាចារឹក Ka 17 បានត្រូវគិតតែត្រឹមអត្ថបទផ្នែកA ហើយអត្ថបទនៅផ្នែកB និងទុកសំរាប់ធ្វើជា ការសិក្សាបន្តនៅពេលក្រោយដ៏ខ្លី ។

អត្ថបទនៅលើផ្នែក A បានត្រូវសរសេរជាភាសាខ្មែរសុទ្ធសាធ ប្រកបដោយឃ្លាប្រយោគ ដែលច្បាស់ល្អខុសប្រក្រតី គឺជាអត្ថបទដែលបានរៀបរាប់អំពី ការទិញ លក់ ដីភូមិមែនហើយ ក៏ប៉ុន្តែគេអាចសន្មត់បានថា សិលាចារឹកនេះជាអត្ថបទអក្សរសិល្ប៍ ដែលស្ថិតនៅលើតថភាពក្នុងជីវភាពជាក់ស្ដែងរបស់មហាមន្ត្រីមួយរូបនៅក្នុងរជ្ជកាលព្រះបាទ *សូរ្យវរ្ម័នទី១* (១០០២- ១០៥០) ។ នៅក្នុងក្របខ័ណ្ឌនៃខេមរនីយកម្ម ឬ ការអភិវឌ្ឍន៍ភាសាខ្មែរ អោយទៅជាភាសាជាតិ យើងអាចឃើញបានថាសិលាចារឹកសំខាន់ៗ ទាំងឡាយនៃរជ្ជកាលព្រះបាទ *សូរ្យវរ្ម័នទី១* ដូចជាសិលាចារឹកស្ដីអំពី សម្បថតំរួតពល ជាដើម(K 292 គ.ស ១០១១ ) បានត្រូវសរសេរឡើងជាភាសាខ្មែរហើយមិនមែនជាភាសាសំស្ក្រឹតទេ ។

ភាគទី១ នៃសិលាចារឹក Ka 17 បានពណ៌នាអំពីពិធីដ៏ឱឡារិកនៅក្នុងសវនាការ នៃព្រះបាទ *ស្រីសូរ្យវរ្ម័នទេវ* សូរ្យវរ្ម័នទី១) នៅប្រាសាទនៃចតុទ្វារនៃទីក្រុង *ជេយេន្ទ្រនគរី* នៅចំពោះមុខ មហាមន្ត្រីនៃព្រះបរមរាជវាំង នៅថ្ងៃ ពុធ ទី ៥ កើត ខែ មិគសិរ ឆ្នាំ៩៣៦ នៃ មហាសករាជ ។ នៅក្នុងពិធីសវនាការ ព្រះមហាក្សត្របានមានព្រះបន្ទូលបង្គាប់ដល់ មន្ត្រីជាន់ខ្ពស់ទាំងឡាយដែលជាមហាបណ្ឌិតអោយចេញទៅធ្វើចំណារនៃអាជ្ញារបស់ព្រះអង្គ នៅព្រះវិហារសីវលិង្គ នៅស្រុក មធ្យទេស ដើម្បីផ្សព្វផ្សាយអំពីព្រំប្រទល់ ដីទាំងឡាយដែលជាកម្មសិទ្ធិខាងដីធ្លីរបស់មហាមន្ត្រីជាន់ខ្ពស់មួយរូបគឺ ព្រះកំស្ដែង អញ *លក្សី បតិវរ្ម័ន* ជាបន្តបន្ទាប់តាំងពីឆ្នាំ ៩៣២ ដល់ ឆ្នាំ ៩៣៦ នៃមហាសករាជ ដើម្បីជាគុណប្រយោជន៍ ដល់ព្រះវិហារសីវលិង្គ គឺមានជាអាទិ៍ ភូមិនានា ភូមិគ្រឹះទាំងឡាយ ព្រៃព្រឹក្សា ព្រមទាំងស្រែទាំងឡាយ ។ល។

សិលាចារឹក Ka 17 បានពណ៌នា អំពីពិធីសាសនាព្រាហ្មណ៍ ដែលបានប្រព្រឹត្តិនៅព្រះវិហារសិវលិង្គ មានជាអាទិ៍ គឺពិធីបូជាយញ្ញដល់ព្រះព្រហ្មណ៍ ពិធីបូជាយញ្ញដល់ព្រះមាតា ( ឬពិធីបូជាយញ្ញរំលឹកដល់គុណមាតា) និងពិធីអភិសេកដល់ ព្រះសុវណ្ណលិង្គ ។ ពិធីអស់ទាំងនេះបានត្រូវប្រារព្វឡើងដើម្បីធ្វើសច្ចានុម័ត លើច្បាប់កាន់កាប់កម្មសិទ្ធិ លើទ្រព្យសម្បត្តិ ដែលជាភូមិករថ្មី១ ដែលជារបស់វត្តអារាម ។

មែនពិតតាមអត្ថន័យនៃសិលាចារឹក Ka 17 ច្បាប់ប្រើប្រាស់កម្មសិទ្ធិនៃវត្តអារាមគឺវត្តសិវលិង្គបានមានដល់មហា មន្ត្រីដែលជាសេដ្ឋីនាម *លក្សីបតិវ៉ែន* ដែលជាមេក្មោងនៃមហាគ្រួសារកាន់សាសនាធំមួយ ។ កថាខ័ណ្ឌនៃអត្ថបទ( បន្ទាត់ ៤៦ . ៤៧ . ៥៦ ) បានបញ្ជាក់ច្បាស់ថា ញាតិសារលោហិត ឬ កូនចៅទាំងឡាយរបស់មហាមន្ត្រី *លក្សីបតិវ៉ែន* តទៅ អនាគតគឺមានសិទ្ធិពេញលេញ ក្នុងការកាន់កាប់ទ្រព្យសម្បត្តិជាភូមិករ របស់វត្តអារាមសិវលិង្គ នៅមធ្យទេស ។

អត្ថបទសិលាចារឹក Ka 17 តាំងពីបន្ទាត់ទី៤ រហូតដល់ចប់បានពណ៌នារៀបរាប់ដ៏ល្អិតល្អន់អំពីការ ប្រឹងប្រែងឥតឈប់ឈរ របស់មហាមន្ត្រី *លក្សីបតិវ៉ែន* ដើម្បីអាចកាន់កាប់ ទ្រព្យសម្បត្តិដែលជាដីធ្លីរបស់ជនានុជន ( ជាពិសេសគឺដីធ្លីរបស់វណ្ណៈអនុជនដែលប្រកបដោយឋានន្តរនាម វាប Vap សំរាប់ជាគុណប្រយោជន៍ដល់វត្តអារាម សិវនិយម ។ សកម្មភាពក្នុងការកាន់កាប់ដីធ្លីទាំងនេះ បានលេចចេញជារូបរាងដោយការទិញដូរ និងដោយមធ្យោបាយផ្សេង១ ដែលយើងនឹងធ្វើអត្ថាធិប្បាយតទៅនេះអំពី ព្រឹត្តិការណ៍សង្គមប្រវត្តិសាស្ត្រខ្លះ ១ ដូចតទៅ :

១- សកម្មភាពខាងលក់ដូរ និង ទិញដីធ្លីបានប្រព្រឹត្តិទៅ តាមការបង់តំលៃដោយថ្នូរ ។ ជំនួសដោយរូបិយវត្ថុ គឺមានការប្រើប្រាស់លោហធាតុមានតំលៃ ចាន ឆ្នាំង ក្រឡោត់ សំពត់ សត្វពាហនៈ (គឺមានទាំង ក្របី សេះ ដំរី គោ ) ។ នៅក្នុងអត្ថបទសិលាចារឹក Ka 17 ពុំមានបញ្ជាក់អំពីករណីកិច្ចនៃការយកខ្ញុំបំរើទៅប្រើប្រាស់សំរាប់ធ្វើជារូបិយប័ណ្ណក្នុង ការទិញដូរដីធ្លីឡើយ ទោះបីករណីបែបនេះគឺជាព្រឹត្តិការណ៍ដែលមាននៅក្នុងសម័យអង្គរក៏ដោយ ។

២- របៀបរបបចងការប្រាក់ ឬ មាស បានប្រព្រឹត្តិទៅដោយយកការខ្ពស់បំផុត គឺយកការ ១០០% ហើយដែលមានបញ្ជាក់ដោយពាក្យខ្មែរថា "បុល" ដូចជាបុលមាសជាដើម ។ ជាឧទាហរណ៍អត្ថបទសិលាចារឹក Ka 17 បាន សរសេរថា នៅឆ្នាំ ៩៣៤ នៃមហាសករាជ មហាមន្ត្រី *លក្សីបតិវ៉ែន* បានអោយបុគ្គល *វាប លេ* បុលមាសសុទ្ធចំនួន ២លិង ដើម្បីបង់ពន្ធដារជូនរាជការ ដោយបានយកការ ១០០% គឺគុណនឹង ២ ហើយ *វាប លេ* ត្រូវតែសងមាស៤តម្លឹង ដល់មហាមន្ត្រី *លក្សីបតិវ៉ែន* ។ ក៏ប៉ុន្តែនៅពេលនេះ *វាប លេ* គ្មានមាសសងហើយគាត់ត្រូវតែប្រគល់ដីមួយកន្លែង របស់គាត់ដល់ទៅមហាមន្ត្រី *លក្សីបតិវ៉ែន* ។ នៅក្នុងអត្ថបទសិលាចារឹកដ៏ទៃទៀតនៅក្នុងសម័យអង្គរមានករណីនៃរបៀបរបប

ចងការប្រាក់ដោយយកការប្រាក់១០០% ហើយរបៀបរបបចងការប្រាក់អាចធ្វើឡើងដោយវិធីយកការ ហើយ វិធីចងការនេះបានធ្វើឡើងមិនមែនចំពោះតែប្រាក់ប៉ុណ្ណោះទេគឺចំពោះមាស ចំពោះវត្ថុមានតំលៃ ចំពោះសត្វពាហនៈ និង ចំពោះដីធ្លីជាដើម ។ល។

៣- ទ្រព្យសម្បត្តិជាដីធ្លី និងភូមិកររបស់ជនានុជនដែលត្រូវអង្គការតុលាការតុលាការមានមន្ទិលសង្ស័យ ហើយចោទប្រកាន់ថា ជាខ្មាំង ឬ ជាជនដែលខ្ចីខ្មាំងប្រឆាំងព្រះរាជា បានត្រូវរឹបអូស និងពិន័យបញ្ចូលមកជាទ្រព្យសម្បត្តិសាធារណៈ ។ តាមសិលាចារឹក Ka 17 នាឆ្នាំ ៩៣៣ នៃមហាសករាជគ្រួសារមួយមាននាមត្រកូលជា *វោ* (Vo) បានត្រូវផ្តន្ទាទោស និង ពិន័យដោយហេតុថា សមាជិកនៃគ្រួសារនេះបានមានសញ្ចេតនាខ្ចីខ្មាំង ប្រឆាំងនឹងព្រះបាទ *សូរ្យវរ្ម័នទី១* ម្លោះហើយដីធ្លីទាំងឡាយ ព្រមទាំងព្រះវិហារ ខាងព្រះពុទ្ធសាសនា ឈ្មោះ *សុខាវ៉ាស* កសាងដោយត្រកូល *វោ* បានត្រូវរឹបអូសហើយ ប្រគល់អោយទៅមហាមន្ត្រីជាសេដ្ឋីនាម *លក្សិបតិវរ្ម័ន* ហើយតមកព្រះមហាក្សត្របានបញ្ជាដល់មហាមន្ត្រីនេះអោយ ស្ថាបនារូបសិវលិង្គមកដាក់ជំនួសនៅទីអាសនៈដែលតំកល់រូបបដិមារបស់ព្រះសម្មាសម្ពុទ្ធ នៅទីនោះវិញ ។

តាមរយៈនៃព្រឹត្តិការណ៍រៀបរាប់ដោយសិលាចារឹក Ka 17 ខាងលើនេះគេអាចសន្និដ្ឋានបានថា ព្រះបាទ*សូរ្យវរ្ម័ន ទី១* មានហឫទ័យទោរទន់ទៅខាងសាសនាព្រាហ្មណ៍ជាងពុទ្ធសាសនា ហើយទោះបីជាព្រះអង្គប្រកបដោយមរណៈនាមថា ព្រះបាទ *បរមនិព្វានបទ* (Paramanivarnapada) បានសេចក្តីថា ព្រះមហាក្សត្រដែលចូលព្រះបរិនិព្វានហើយពាក្យនេះគេ ច្រើននិយមថាជាបច្ចេកពាក្យខាងពុទ្ធសាសនាក៏ប៉ុន្តែពាក្យនិព្វាន (និវាន) ក៏មានប្រើនៅក្នុងព្រហ្មញ្ញសាសនាផងដែរ ។ តាមឯកសារសិលាចារឹក ព្រះបាទ *សូរ្យវរ្ម័នទី១* ជាព្រះមហាក្សត្រដែលធ្វើពិធីសក្ការបូជា ព្រះសិវ ។ ព្រះអង្គបានប្រកាន់តាមសិវនិយមយ៉ាងខ្ជាប់ខ្ជួន ។ មិនតែប៉ុណ្ណោះព្រះអង្គបានយកលទ្ធិសិវនិយមមកធ្វើជាគ្រឹះនៃរបបគ្រប់គ្រងរបស់ព្រះអង្គ ដែលបានធ្វើអោយប្រទេសកម្ពុជាប្រកបដោយ វិសាលភាព ដ៏ធំធេងជាងក្នុងរជ្ជកាលព្រះមហាក្សត្រ ដ៏ទៃដែលបានឡើងសោយរាជមុនព្រះអង្គ មិនតែប៉ុណ្ណោះព្រះអង្គបានទទួល កេរដំណែលដែនដី លីហ្គ័រនៅម៉ាឡាយូ ពីព្រះបិតា ព្រះអង្គទៀតផង ។

តាមសិលាចារឹកព្រះវិហារ K 380 ព្រះបាទ*សូរ្យវរ្ម័នទី១* ដោយការធ្វើសមាធិ និងពិធីបូជាយញ្ញព្រះអង្គបានធ្វើអោយព្រះអាទិទេពនៅ*លិង្គបុរៈ* (Lingapura)គឺ*វត្តភូ* យាងមកសណ្ឋិតនៅឯព្រះវិហារ *សិខរីស្វរៈ* ( Çikhariçvara ) គឺនៅឯប្រាសាទព្រះវិហារលើភ្នំដងរែកវិញ ។

* * *

[illegible]

(១). ១៦០៣ គតបញ្ចាប់គោតមាគ៌ាក៏ទុកជាការស្ដាប់ព្រះបាទព្រះស្ដេចកនអញ្ជាស្រីសុរិយោពណ៌ឧបរាជព្រះឧទ្ទរាជព្រះ
ធិលាធាធាព្រះស្រីជេយ ស្រីសុរិយ  ស្ដេចកំស្ដេចជ  (២).  ភាគ្នាពុលាដើមដកប្រជុំឲ្យបន្តព្រះអង្គស្ដេចគឺចាន
សអាបគឺភាគណាស់ព្រះអង្គស្ដេចកន្ធដែលសាបតំណាងកំស្រួសរាជ   ព្រះពលាដកក្នុងពុលាដើមដកជាថ្មី ស្រុកភា
(៣). សត្រូណាំបំប្រែ - - ស្ដាប់ណាប្រកស្ដេចអាយស្ទ្រពេកស្ដេចព្រះប្អូនស្នាក្សយស្ទ្របណ្ដេញស្ទណ្ណណស្ដេចមានបុណ្យស្ទ
ក្សត្រស្ដស្រមហាបន្តិតជំនប្រព្រះកម្រតេងអញ្ជាចំ  (៤).   ធាគិបន្តិតព្រះកម្រតេងអញ្ជាខ្លាកកធានបណ្ឌ
ដែស្ដេចធាលិគកាលស្ដែក * ១៦០ គកកន្ធមានបុឹមាសជេកដាយបគ្មីមាបុនបាស្រុកធាស្នស្ដុលតម្កោតអំចំស្ដេចខែត្រ
(៥). ស្មោះស្ដេចដោយដាក់ស្លាកស្លាក្រុបចេញបុត្តកបក្រាពត្តាស្ដេចដោយកក្រាបស្ដេចដែលគឹម្រតប្រាស្នាភាស្រី
បន្ទំបកណ្ដាស្រុកធាសណ្ដស្ដនគំស្ដេនអនចោម សភា  (៦).  តន្ទះខាន់មានខាបស្របគខានសម្ដធំនក
៩ យក្សតព្រះអង្គស្ដេចអញ្ជាក្រឡត្បូបតំខ្ពស់ព្រះអង្គស្ដេចអញ្ជាជុំកុស្សឧយ  ប្រស្រតខាប  ប្រប្អូនខានមាសខាប
ខ្ពស់តក  (៧). សម្រតាប៉ាន្នាព្រឹនបម្រាបកសកម្ទោកស្ប្រស្រធំមនិឧយខាសម្រកប្រស្រ  ៧ ដនិទ្រនិគោ
បិយាក្សបយាស្ន្រធាយយាមក្ខះអំខសក៏បជាក្សខាគ្នោះខែជាឡ ( ៨).  ខានចៅនិបជិកៈ * ភ្នងតាពប៉ា
ខស  ០ -- ខែប  - - - - - - - - - - - - - - - - - - - - - កំស្ដេចអញ្ជាក្រឡត្បូបតំខ្ពស់ធាតាខាបិនខំក្រខាប
បិតសតកនិត ស្រុក  (៩). - - - - ៦៧  - - - - - - ២  - - - - - - - ស្រុកស្ដោយស្រុកតាម្ប្រត្នោស
ចោបយាសលាប  ប្រកាឧយជាយ  - - - - - - ស្រុព្រះអង្គស្ដេចអញ្ជាក្រឡត្បូបតិខ្ពស់  (១០).  ខានកសស្ដេច
ខាបិស្រុកខាបិចេបិធា ព្រះ  ក្រលាញណាភាន្យាខាបិកម្ពខាបិអាចំក្រាស្ដធំតោយកក្សនភាបតោសភាតែអំចិល.
គោលយបុត្តកបស្ដេចស  និបក្រលា   (១១).   ធុធាម្ន  តោយនក្ខាប្រសបស្រក្រប.តោយនក្សតកបស្ដស.
ប្រាន្យស្ដធានាល  ប្រកមនសំធ្យនសនទមាសលិនស្ដយា  មអំខសក គិឧយត ខាបគក្សវភាខស្ដមាបភា
(១២).  ភាសប្រតម ក្រសានតោ ស្ដ នសធ្យនលិន មាសលិនតោយក្ខះព្រះភានិយាបំះដំកធ្លះគិឧយតខាប
ក្សកខាបឆេប.១៦០០គកន្ទ ព្រះអង្គស្ដេចអញ្ជាក្រឡត្បូបតំខ្ពស់   (១៣).   ស្ដាភ្នតិកនិស្ដតាត្យ ខាបក្រយោះ
ស្ដាបតាម្បល  ស្រុកសស្ដកបំតក  ព្រះកម្រតេងអញ្ជាកិខលំកធាកំស. អាធាយ្យកស្នាប  ម្រតាប៉ាន្នាប្រា  ព្រះ  ប្រប្ទាសកាលប្រស្យ
ធំឧយត   (១៤).   ខាបិក្រយោះស្ដខាបខ្ពស់បាលស្ដត ស្ដកុលេដោះចេនចៅនិប   និគៈ ស្សកសក្សតាកំខលះ
ប្រភានគំធ្លះ.មិនក្រកំស្ដេចអញ្ជាកន្ធះស្ដកំភាបិប្រភានស្ដកសស្ដតឃើនិបិនបិ  (១៥ )  អនចោមស្ដអ្នកសស្ដកបិ
ឧយភ្នមិធះតព្រះអង្គស្ដេចអញ្ជាក្រឡត្បូបតំខ្ពស់.អំឧយប្រស្រតព្រះកំស្ដេចកន្ធះស្ដចេតំប្រស្រក្សល តម្ប្រយាម្ប្របា
តំឧយតម្រតាប៉ាន្នា  (១៦).  កំស្ដតិនិកតន្នាយាព្រះអង្គស្ដេចអញ្ជាកន្ធះ ស្ដស្រម្រតាប៉ាន្នាក្រលតក
លេព្រះអង្គស្ដេចអញ្ជាកន្ធះស្ដតិឧយប្រអប កនស្សកយាន.កំចិតន្នោភាខាប៉ានិកភាព្រះ  (១៧). កំស្ដេចអញ្ជា

គន្លះខ្ញុំតិឱយជ្រង់ ៚ សិលាបិ ក្រាំងឱយបាយព្រះកំស្តេង៏អញ កន្លះខ្ញុំនុកិ ម្រតាញខ្លោញ នុខ្លោញវល សញ្ជាក់ផៅង៏ តបក្សា ព្រះកំស្តេង៏អញ កន្លះខ្ញុំតផោ (១៨). កម្ទាប់ថ្ងៃយ៏នោះ ឧក្តិតិឱយ ឆ្នាំ ស័ក ស័ក ខ្យាក់ ឧចង៏ ឈ្មោះ ខតិ ៧៤៦ កក តកិ ខ្មែរ ម៉ាត់ តិរ ៃបិ ព្រះកំស្តេង៏អញ ក្រិលក្ស្ញុំ បតិចម្ម ថ្ងៃ ព្រះម្រាយ ទ្នា មាត្យ យ ទ្នក តកិ ភូមិនោះនុ (១៩). បរិល្យ ស្មោង ល្ហ លិង្គ ត ព្រះ កុរេបិ ព្រះកំស្តេង៏អញ កន្លះខ្ញុំ មោក ស ឋយ ទ្នក ស្នេ និ បិង៏ នុ ម ឆាប ស្តិ ក្ត ម៉េង៏ត ង៏ ស ម្រ ព្រះកំម្រតេង៏អញ ព្រះ ខិ ន្ទ្រាធិបត្តិ តិតាក្សុ (២០). ត ព្រះម្រាយ ទ្នា ព្រះកម្រតេង៏អញ តិ ម ផុក ថ្ងៃ ងាគ្ន យ ទ្នា ព្រះកំម្រតេង៏អញ ទ្លាត់ ត បន្សុង៏ ស្មោង ល្ហ លិង្គ នុ ព្រះកំស្តេង៏អញ សភាប តិនា ត្រិលោ ព្រះកំស្តេង៏អញ សភាបតិនា ឧត្វារ (២១). ឥ ផោគ ស្លាប នា ម្រក ស្ត នេះ នុ ម្រ តាញ ខ្លោញ ង៏ លា ង្កេ ទ្វា កុណ ង៏ម ម្រតាញ ខ្លោញ ឧគ ជិ ស ភា ស ត៏ យុគបតិ ឝ្ស ម ឆា បន្តិ ត ត អំ បាល្ល ផេះ ឋោ ដេប ព្រះកំស្តេង៏អញ កន្លះខ្ញុំ (២២). ធោល់ នុ សត្យ ថ្លេត ព្រះបន្ទូល បិ ឱយ ឝស្ស ភូមិ ល័ស្ត ត់ ជើត ព្រះកំម្រតេង៏អញ កិ ឧលិង្គ អាយ៏ មទ្រង ដេគ នុ ព្រះកំម្រតេង៏អញ កិ ឧលិង្គ អាយ៏ ថ្ងៃ តិ ឱយ ស៊ំ ង ន្ត្រ ល ផោយ៏ បុគ្ន តតិ ង៏ (២៣). ជ៏ខ្ញុំ កំ ខ ង៏ ថ្មី ផោយ៏ អក្ខេយ៏ ម្រ ស ប៏ ភូមិ ត្រ ផោ ប៏ ៚ ៧ ៤ ៤ កក ម ង៏ ត្រ ភ្វ ល៏ ថោ ស៊ំ នុ តាំ បាង៏ បិ ខ្ញុំ ខ្ញុំ កំ ម្រតេង៏ កំ ត្វ ង៏អញ ប្រ ន ល្ហួ យ ឈោក ភូមិ នុ ព្រះ ស្មា ត ស ង៏ ត ញ ត្រិ តតិ (២៤). ត្រ ភ្វ ល៏ ខោង ហៅ ម្ដ ឱយ ប្រសាទ ត ព្រះកំស្តេង៏អញ ក្រិលក្ស្ញុំ បតិ ចម្ម ព្រះ ប្រេ ព្រះកំស្តេង៏អញ ស្លាប នា កិ ឧលិង្គ ខ ក្តុ កិ ប្រាសាទ នោះ នា គេ ល៏ ព្រះ ពុទ្ធ អា ចា ល្ង ត ផោ (២៥). ក៏ ស្លាប នា កិ ឧលិង្គ ព្រះកំម្រតេង៏អញ ខិ ន្ទ្រា ធិ បត ក ល្ស ង៏ ព្រះ សភាគ មោក៏ ស ង្គ្រ លិ កំស្តេង៏ យ ន ប៏ កុណ ផោ ប នា ត្រិ និ នុ ព្វា ង៏ នា ត្រិ ង៏ ទ្វា តិ ត ភូមិ ផោយ បត្វិ ម ម្រ ស ប៏ ចាល (២៦). យ ធោ ឧក្ស្ញា ណា ម្រ ស ប៏ ស្តុ ក៏ ន្ល្ល ក្រាំង បុរ ត្រ ទ៏ ផោយ៏ បុគ្ន ម្រ ស ប៏ ខ ក្តុ រ ស៊ំ រ ង៏ សា ខេ្ម ផោយ៏ ឧក្តុ រ ត ក ប៏ ឆ្នា ម្រ ង៏ ម្រ ស ប៏ រ ខ ង៏ ប្ញុ រ ត ក ប៏ ឆ្ន ង៏ ចំ ង៏ ជើ ប ត្វិ ឧ តិ ព្រះកំស្តេង៏អ (២៧). ញា ត្រិ ល ក្ស្ញុំ បតិ ចម្ម ឱយ ត ភូ រ អាយ៏ ស្តុ ក៏ អ ក្ត ស៊ំ ត ង៏ ត ង៏ ស ង៏ ក្រា ន្ត ព្រះកំម្រតេង៏អញ កិ ឧលិង្គ អាយ៏ មទ្រង ដេក ៚ ៧ ៤ ៤ កក ម ង៏ ហា ប៏ ល ង៏ ត ក្រាម ស្តុ ក៏ ព្រះ ខ ស ង៏ ម្រ ត្រ ក្រា (២៨). ត បុ ល៏ ម ស៏ ឝ្ស រ លិ ង៏ ៚ ត ព្រះកំស្តេង៏អញ ក្រិលក្ស្ញុំ បតិ ចម្ម បិ ឱយ ក ង៏ កា ល្យ ម ង៏ កុណ ម ស៏ លិ ង៏ ៤ បិ ញ្ញា អា ម ស៏ បិ ឱយ ឱយ ភូមិ អា យ៏ ក្រា ទ៏ ឧទ្វា ត្ត ភូមិ នោះ ផោយ៏ បុ (២៩). ថ្ងៃ ម្រ ស ប៏ ភូមិ ទ្វ ង៏ បន្លា ផោយ៏ ង៏ ក្ស្ញា ណា តា ប៏ ស្ម រ ង៏ ផោយ៏ ប ត្វិ ម ឝ ល្ប ត្រ ត ស៊ំ ង៏ ផោយ៏ ឧក្តុ រ ម្រ ស ប៏ រ លេ ង៏ ព្រះ ភា គ មោ ត ស ង្កោ ល៏ ត ភូមិ នោះ ម្រ តាញ ខ្លោញ ទិរ (៣០). ក្រាម ស ភា ស ត៏ ម្រ តាញ ខ្លោញ ឡូ ល៏ ត ខ្លោញ ព្រះ ខ ន ង៏ ៚ ៧ ៤ ៤ កក នុ ព្រះកំស្តេង៏អញ ក្រិល ក្ស្ញុំ បតិ ចម្ម ទ្ធ ញា ភូមិ មា ត ទ្វា ឝ ចា ប៏ ទ្វ ប្រ លា យ៏ ម្ម ត ក ឝ ង៏ ថ្ងៃ (៣១). នុ នុ ញា ខា ល៏ ម្រ ក៏ ៤ ង៏ ឝ្ស ង៏ ត្វា រ ង៏ ៤ ង៏ ង៏ លិ ង៏ ៤ ថៅ ទិ ៃប ង៏ ក ៗ ឝ្ស្យា ក ទ្វា ត្ត ភូមិ នោះ ផោយ បត្វិ ម ឝ ស្ស ង៏ ឝ ត ឝ ទ្វា ម្រ ស ប៏ ភូមិ ទំ កា ន់ ផោយ ឧក្ស្ញា ណា តា ប ផោ (៣២). ក ង៏ ក្តុ រ ម្រ ស ប៏ ភូមិ ព្រះកំស្តេង៏អញ ង៏ ផោ យ៏ អា រ ផោយ៏ បុគ្ន ឝ ស ទ្វ ក៏ ល៏ ស្លា ម្រ ស ប៏ ស្ល់ ថៅ ផោយ៏ ឧក្តុ រ ទ្វ ល ង៏ ម្រ ស ប៏ នុ ភូមិ កំស្តេង៏ ង៏ ល ទ ន្ល ម ង៏ ឈ្មោះ ត ៧ ៤ ៤ កក (៣៣). បិ កំស្តេង៏ ម ល្វ យ៏ ត្រិ ទ្ធ នុ

ព្រះកំស្តេចអញ្ញា ត្រៃលក្ស្មីបតិវង្ស ក្រចាមង៍ហេតុ ព្រះកំស្តេចអញ្ញា ខ្ញាញកុសិបំយោកក៍ ភ្ជុំព្រះខ្លួនអំណាចកំស្តេច

មល្វយប្រម្យក៏ព្រះខ្ពង់ (៣៤). តាស្រពោះ ចេរៀ. ព្រះកំស្តេចអញ្ញា ត្រៃលក្ស្មីបតិវង្ស ម្ដាយសំនូតកេះហបុទ្ធិបរសេហ

ព្រះកំស្តេចអញ្ញាមានភ្ជុំនោះហ. ព្រះពេមណាតកំស្តេចមលាយ៉ាប្រស្តប័ញ្ញច (៣៥). ហារកំស្តេចមល្វយ៉ខ

យ៉ខាប័ទុប្រហាយតមាន៍ភ្ជុំនុញ្ញាច្បប្រការទេញ្ញាខាប័ទុត ព្រះកំស្តេចអញ្ញា ត្រៃលក្ស្មីបតិវង្សព្រះសភាប្រស្នាកខាប័ទុ

បិន្ទុនិណ្តូយឋនខាប័ទុថ្វា (៣៦). យ៉ព្រឡាកំបំពាសសិទ្ធិភ្ជុំនោះតាព្រះកំស្តេចអញ្ញា ត្រៃលក្ស្មីបតិវង្ស. តនាព ព្រះ

កំស្តេចអញ្ញាកិចបាងសភាប ទំនាត្រុំនំ ព្រះកំស្តេចអញ្ញាកំរំបែនះភាបតំណាងកំស្តេចក៏ (៣៧). ភ្នំង៍កុនជោបឆជោ.

ម្រតាញ្ញាខ្លោញ្ញាងលាចេក្ខវាក្យាណោបរាត្រុំនំព្រះឧយ៉ ព្រះត្រៃឈប្រសាងភ្ជុំនោះត ព្រះកំម្រតេចអញ្ញាកិចលិង្គ

ន្ធីហាស្ដអាយមាឡុជេគ (៣៨). ព្រះប្រស្តេចអញ្ញាកិចនានិច្ចនភានុស្ថាប្ញាត្រុំនំជើហៅ ក្រមខ្វន្ធិបុរម ប្រធាន

ឫនតោយបំសមឡុបំសម្ដោល៍ មន៍ព្រះកំស្តេចអញ្ញាន្ធំបំសាត្យុ ស្រុកត៍ចេកសោ (៣៩). តម្លាយ៉ខ្សា ឝាជន

ប្រត៌ាជនច្បុង៍ចតញ្ញាប៍ហាន៍ចេនច្បុង៍ព្នកំស្តេចចលខន្ធតមាន៍ ស្រុកស មំបនុភ្ជុំនោះតជើសក្តាស៍នុស្ដេចអញ្ញា

ភជនាន៍ព្យព្រះប្រជើ (៤០). សក្ដោសតកំខ្វាត៌ តកេះបានេះហនយ្ដ ព្រះកំ ម្រតេចអញ្ញាកិចលំក្ដកោះហ

ព្រះត្រៃណា ✻ លបភគកនុតាបិចោកន្យុង៍បរ ស្រុកតំខ្វង៍ឧយ៉ភ្ជុំតំខ្វង៍ត (៤១). ព្រះកំស្តេចអញ្ញា ត្រៃលក្ស្មីប

តិវង្ស ខម្មាត្តភ្ជុំនោះ តោយ៉ឃុទ្ធិប្រនម៍នុភ្ជុំកំម្រតេចង៍តត៌កិចបាងតោយនក្សិណាឆសកុលមាត្រុកោយបក្វិម

តាប័ឌ្ឍុរ៍ត្វលតោ (៤២). យនត្ថុរតាប៍តឈ្លោត៍កពាំឲ្យស៍ ស្រុក.ច្រឡាត៍ ព្រះកំស្តេចអញ្ញានយ្ដខាយចេវិត៍ទ្វង៍

ចេវិកំជេន៍ច្បុច បន៍កា.ជេន៍ច្បុង ✻ លបភគកម្មាយ៉កេត៍មហាឯសុក្រ (៤៣). ខាន្ទុ ព្រះបាទកំ ម្រតេច

កំពូនអញ្ញា ត្រុំម្ដុយ្យុខម្ទុះជខស្ត៍ ព្រះខត្តុំខ ព្រះអិលាតតាកម្រះ ត្រុំងយេន្ទនកិរំបន្ទល៍ត ព្រះកំម្រតេចអញ្ញា

ត្រៃចិញ្ញាន៍បន្តិត្ត (៤៤). ប្រែបន្ទល៍ត ម្រតាញ្ញាខ្លោញ្ញា ត្រុំឲ្យបេឡោបកញ្ញុ ស្រុកខាន៍ ម្ពុនជិតយុក៍តំនុកុលតន្ទះខាន៍

ជេន៍មាប៍ ប្រប្បាគំចចំនត់.ខាបចេ ស្រុកតំខ្វង៍ភន្យុង៍បំរេតំ.ខាប៍ម្យុត (៤៥). ស្រុកស្តុំខ្ញុំ ព្រះក្រឡាហ្វុំតោ.

ខាន៍តក្វាអាចខាប៍ជាកយ ស្រុកស្តុនចំក្រាន្តតាំប្រមុត្តកោះ មានេះហាឡុជ្ជជើតាន្ទុក៍ ព្រះក្រឡាអំខណាប្រសំម្ទ

លនុព្រះកំ (៤៦). ស្តេចអញ្ញា ត្រៃលក្ស្មីបតិវង្សម្ដាយ៉កេះសាយ្យនុកុលាព្រះកំស្តេចអ ញ្ញាប្រខ្វាន.ជើងមន៍កុ

លេព្រះកំស្តេចអញ្ញាបរំ បាលខម្ម ព្រះកំស្តេចអញ្ញា ម្ដក្តកេះហ (៤៧). នេះហាបរំបាលខ ម្ម ព្រះកំស្តេច

អញ្ញានុកុសេ ព្រះកំស្តេចអញ្ញាជត.សំបោតុមន៍ម្ដក្តកេះហនេះហាឡុជ្ជឧយភ្ជុំសម្តេចស្លាបជាចេខម្មចេង៍ខត្តនុ

ព្រះកំស្តេច (៤៨). អញ្ញា ត្រៃលក្ស្មីបតិវង្ស ✻ លបភគកខតុបំពេញប្បុស៊ើរការស្តុញ្ញាចលស្នាស៍អាយ៉កំខ្វត៌ជើ

ឈ៍នុតង៍ត្វនភយាខ្លោញ្ញាចលតម្រុល អាយកំខ្វតចេស៍នុខ្លោ (៤៩). ញ្ញាចលតន្ទះសោញ្ញាកំខាចំខ្វសមយុតនុ

ក្រាមខ្វន្ធិតបុហ៍ខាបស្សាត្តនុខ្លោញ្ញាម្ពុក្តច្បុរតន្ទូរ៉ាជសាបភ្សោ៎ខោកត្បោន៍បំឧយភ្ជុំកំខ្វតចេស៍តព្រះកំស្តេចអ

(៥០). ទាក្រឹលក្សីរបតិចម្ភ័លបំផ្រុក ត់ចេរស្រុកបោយបរាខនគចេនក្ខុមិមនិឌយកក ចរូនឥរមេ•កល្យុនា ព្រះកំ ស្តេចអញា ក្រឹលក្សីរបតិចម្ភ័ត ព្រះកំ ម្រតេចអញ (៥១). កំបលិក្ក អាយ៉កំខ្ទត់ឆេល័ខ្លុំពានគាសិ ព្រះចោរច្ចា លិះរសបិស្ត្រាគ្គតតិបញាឌោតិសខរេច្ចាលិម អាក្រមនោះតិ ព្រះកំស្តេចអញាកល្យុនាតាកបិខ (៥២). ស្រ្តគាល នាសាគុខនរ្ទលិរោគ្ហា កំដើម្ភុក្គញាដបរិបាលឌម្មុំនោះនហាកុលេលហិនហាម្ភុក្គដេឃ្វិលហ័ស្សក្គមានិនម្ម័ន ព្រះកំ ស្តេចអញាខ•ដើម្ភុក្គតបំបាត់ឌម្ម (៥៣). នោះដើស្មេយ័នវក្កតកាយ ព្រះខគ្រានិត្យមានិលេយ ⁂ លាបខគគ នុម្រតាញា ខ្លោញាក្រឹខលរ ស្រ្តចល្ខកខ្មុំតខ្លោញ្ញាំអាយចិក វកំឌយ័ខំនតិតុរ្យុមកា.. (៥៤). ដើឡ្យ៎អាយ៉ ថ្វាគឬតេ ព្រះកំម្រតេ ចិអញាតិចលិក្ខមង្ស្លេគកល្យុនាស្រុកឆ្លាស៍ ម្រតិខបយ៉្យៃចិអន្ទូចិទកល្យ៍តុលិរាឌយ ប្រតិ សាំចខ្លា•កិច្ចហាច់នតិនោះខ (៥៥). នគ្គញាឌិត ម្រោត៍យោកច់ខេីនយាកន្លានិយោកំបហ យោកញ្ញុចតិត បិត់ខំនតិខ្ទលិតេតម្រុខយោហ្យុន យ កិចកុលេនោះអ្នុក្សិម•នេះម្រតាញា ក្រឹខិ (៥៦). ចរស្រ្តចល្ខកកេ ត្ថសក្តាន ព្រះកំស្តេចអញាក្រឹលក្សីរបតិចម្ភ័ ⁂ កល្យុនា ព្រះកំស្តេចអញាក្រឹលក្សីរបតិចម្ភ័ត ព្រះកំម្រតេចអញាមង្ស្លេគកំបុជា ប្រតិនិនរច្ចាច្ចនិរចោស្ត្រា (៥៧). នគ្គុនិយាយ ព្រះចេលិះ ទយញា ត្លួចខ្ទនិមេហិត្សាចខ្ទន៎ ។ .

# INCRIPTION Ka 17 DE SURYAVARMAN I

( CONSERVATOIN D'ANGKOR, SIEMREAP, 935 çaka)

(1) )0( 936 çaka pañcami ket margaṣira vudhavāra nu dhūli vraḥ pāda kaṃmraten kaṃtvan añ çrī suryyavarmmadeva stac vraḥ caturmmukkha vraḥ çilātatāka vraḥ çrī jayendra nu gi pi pandul ta kaṃsteṅ [ma]

(2) hātma guṇadoṣadarçi pre cuñ pandūl ta vraḥ kaṃsteṅ çivapāda sabhāpati nā triṇi nu vraḥ kaṃsteṅ kuti ruṅ sabhāpati na catvāri nu mratāñ khloñ jalāṇgeçvara guṇadoṣadarçi nā trini nu prati hā . .

(3) la trini pi pre - - sthāpaṇā praçasta neḥ āy madhyadeça nu thve vrahmayajña mātṛyajña panlyaṅ suvarṇṇaliṅga mās purṇna saṃvatsara purṇna syaṅ mahāpandita ta juṃ daṃnepra vraḥ kamrateṅ añ vi

(4) dyādhipandita vraḥ kamrateṅ añ vlok ta mok panlyaṅ suvarṇnaliṅga ta kāla noḥ uk )0( 931 çaka nu mān bhūmi mādhyadeça toy paççima prasap sruk cās sme nu thnal ta mok aṃvi sjuṅ dau utta-

The question, "What is your name?" is understood by Cambodians as "what is your given name?". It should be followed by the question "what is your family name?". A Cambodian married woman will reply by giving her own name while an Australian welfare officer expects her full name which is her given name plus her husband's family name. To get the answer wanted, a series of questions should be asked in the case of the married woman, for example: what is your own name and family name?, and what is your husband's family name?

Different cultures provide different answers to the same question. The Cambodian naming system has a long history and evolution which is an indication that Khmer culture is rich and well entrenched. Khmer culture has survived although there were civil wars, and many unrests after the period of Angkor. The French occupation of Cambodia for ninety years could have changed the Khmer culture but it did not happen. The French colonial rule was successful in colonizing Khmer territory but not the heart of Khmers.

## Reference


Huot, T. (1958) ហួត, ត. (១៩៥៨) *សិលាចារឹកនគរវត្ត* ភ្នំពេញ : វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ។

Long, S. (1997a) ឡុង, ស. (១៩៩៧) *ស្ថាននាមវិទ្យាខ្មែរ* ភ្នំពេញ : វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ។

Long, S. (1997b) ឡុង, ស. (១៩៩៧) ឋានន្តរនាមសម័យអង្គរ *កម្ពុជសុរិយា* ឆ្នាំ៥១ លេខ១ ១៩៩៧ ទំ. ៤១-៧៥។

Long, S. (1997c) ឡុង, ស. (១៩៩៧) ទំរង់ខាងវេយ្យាករណ៍នៃនាម *កម្ពុជសុរិយា* ឆ្នាំ៥១ លេខ២ ១៩៩៧ ទំ. ១៦-៣៤។

Long, S. (1997d) ឡុង, ស. (១៩៩៧) ឋានន្តរនាមសម័យអង្គរ *កម្ពុជសុរិយា* ឆ្នាំ៥០ លេខ៤ ១៩៩៧ ទំ. ៤២-៦៤។

Long, S. (2000) ឡុង, ស. (១៩៩៧) វចនានុក្រមខ្មែរបុរាណ (តាមសិលាចារឹកបុរេអង្គរ សតវត្ស ទី៦-៨) ភ្នំពេញ : មូលនិធិតូយ៉ូតានៃប្រទេសជប៉ុន។

Troeng, Ng. (1973) ត្រឹង, ង. (១៩៧៣) ប្រវត្តិសាស្ត្រខ្មែរ ភាគ ១, ២ ភ្នំពេញ : ការផ្សាយរបស់អ្នកនិពន្ធ។

Coedès, G. (1942). *Inscription du Cambodge*, 7 volumes. Hanoi : Ecole Française d'Extrême Orient.

Coedès, G. (1942). Inscription de Dvaravati de Crivijaya et de Lavo in *Recueil des inscriptions du Siam*, deuzième partie, Bangkok.

Commission des Moeurs et Coutumes du Cambodge (1985). *Cérémonies Privées des*

*Cambodgiens*. Phnom Penh : Institut Bouddhique

Doeuk, K. (n.d.). Inscription of Trapeang Ron. In *Culture, Civilization et Littérature Khmères*, 6. Phnom Penh : Institut Bouddhique.

Doeuk, K. (1967). *Essai d'étude sur les inscriptions Khmères*. Phnom Penh.

Fabricius, P. (1967). Les noms posthumes des souverains Khmers In *Annales 1*. Phnom Penh : Université Royale des Beaux Arts.

Long, S. (1978) *Les anthroponymes sur les inscriptions du Cambodge du VIème au XIIIème siècle*, materiel présenté au XXIXème Congrès International des Orientalistes à la Sorbonne, France.

Monod, G. H. (1931) *Le Cambodgien*. Paris : Edition Larose.

Pou, S. Inscription modernes d'Angkor In *Bulletin de l'Ecole Française d'Extrême Orient*, vols. 57-61.

Pou, S. (1972) Les inscriptions modernes d'Angkor Vat, Extrait du *Journal Asiatique*.

SaveasCambodianNamingSystem

# ឯកភាវូបនីយកម្មភាសាខ្មែរ

Unification of Khmer language

បណ្ឌិត ឧយ យីហ៊ាង
រាជបណ្ឌិត្យសភាកម្ពុជា

ទំនាស់នៅក្នុងភាសាខ្មែរកាន់តែមានទំហំធំឡើងៗ ទាំងខាងការនិយាយ ទាំងខាងការសរសេរ ដោយគិតតាំងពីការប្រើប្រាស់លិខិតបទដ្ឋាននៅក្នុងស្ថាប័នធំៗ រហូតដល់ស្ថាប័នតូចៗ។ សូម្បីតែនៅក្នុងក្រសួងអប់រំ យុវជន និងកីឡា ក៏ការសរសេរមានលក្ខណៈខុសគ្នាដែរ។ ជួនកាល នៅក្នុងការិយាល័យតែមួយ ឬនៅក្នុងផ្ទះតែមួយ សំនេរនៃពាក្យមួយមានលក្ខណៈខុសគ្នា ដោយយោលទៅតាមការចូលចិត្តរៀងៗខ្លួន។

ក្នុងករណីដែលបណ្ដោយឱ្យទំនាស់នេះអូសបន្លាយតទៅទៀត បញ្ហាបាក់បែកខាងស្មារតី ស្ដីពីភាសាខ្មែរអាចឈានទៅដល់ការបាក់បែកខាងអត្តសញ្ញាណជាតិ។ ហេតុនេះ វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជាមានភារកិច្ចប្រមូលយកមតិល្អៗពីអ្នកសិក្សាស្រាវជ្រាវទាំងឡាយ ទាំងនៅក្នុងប្រទេស ទាំងនៅក្រៅប្រទេស ដែលយល់ដឹងអំពីភាសាខ្មែរ ដើម្បីរកដំណោះស្រាយរួម និងជំរុញឱ្យភាសាខ្មែរឈានឡើងតាមមាគ៌ាឯកភាពមួយ។

## I. និន្នាការខ្ពស់នៅ និងដំណើរវិវត្តនៃភាសាខ្មែរ

បើតាមសិលាចារឹកមួយចំនួន ខ្មែរមានភាសារបស់ខ្លួនតាំងពីបុរាណសម័យ។ នៅសម័យហ្វូណន (សម័យនគរភ្នំ) ព្រះមហាថេរ **សង្ឃឃោស** មិនគ្រាន់តែចេះភាសាខ្មែរទេ ព្រះអង្គចេះទាំងភាសាសំស្ក្រឹត បាលី និងចិនទៀតផង។ នៅសម័យចេនឡា លោក **សិទ្ធវីរៈ** ជាឪពុក និងលោក **សិទ្ធឧត្ត** ជាកូន សុទ្ធសឹងជាអ្នកប្រាជ្ញគួរឱ្យកោតសរសើរ។ នៅសម័យមហានគរ ព្រះនាង **ឥន្ទ្រទេវី** លោក **កិត្តិបណ្ឌិត** លោក **សុរិយកុមារ** និងលោក **សិវៈសោម** ... ជាអ្នកវិទ្យាសាស្ត្រដ៏ឆ្នើម ដែលបានរួមចំណែកធ្វើឱ្យវប្បធម៌ និងភាសាជាតិរុងរឿង។

ប៉ុន្តែ លុះមកដល់ក្រោយសម័យមហានគរ វិស័យវប្បធម៌ វិស័យអប់រំ និងភាសាខ្មែរបានចុះទ្រុឌទ្រោមទទឹមនឹងការចុះទ្រុឌទ្រោមនៃគ្រប់វិស័យដទៃទៀត ជាពិសេសវិស័យសេដ្ឋកិច្ច និងវិស័យនយោបាយ។ កត្តាទាំងនេះកើតឡើងដោយសារចលាចលនៅក្នុងសង្គមរាប់រយឆ្នាំ។

មកដល់សម័យអាណានិគមនិយមបារាំង ភាសាខ្មែរក៏មិនសូវរីកចំរើនដែរ ព្រោះពេលនោះ ភាសាបារាំងត្រូវបានប្រើប្រាស់ជាភាសាផ្លូវការ។ នៅពេលដែលខ្មែរបានទទួលឯករាជ្យពេញបរិបូណ៌ គ្រប់វិស័យបានរីកចំរើនឡើងវិញ។ ភាសាខ្មែរត្រូវបានលើកតំកើង ដោយមានគណៈកម្មការជាតិជាអ្នកត្រួសត្រាយ។ ពេលនោះ បញ្ញាជនខ្មែរ ទាំងគ្រហស្ថ ទាំងបព្វជិតបានខិតខំធ្វើឱ្យអក្សរសាស្ត្រ និងភាសាជាតិរីកចំរើនគួរឱ្យកត់សំគាល់ និងកោតសរសើរ។

នៅចុងសម័យសាធារណរដ្ឋខ្មែរ និងសម័យកម្ពុជាប្រជាធិបតេយ្យ ភាសាខ្មែរត្រូវបានស្រុតចុះយ៉ាងខ្លាំងម្ដងទៀត ព្រោះគ្មានសាលារៀន គ្មានសិស្ស និស្សិត គ្រូបង្រៀន សាស្ត្រាចារ្យ ។ បញ្ញាជនត្រូវកាប់សំលាប់ ដូចមូលធនិក និងកងកំលាំងប្រដាប់អាវុធនៃរបបចាស់ដែរ ។ *"អង្គការអ្នបឹមួយ"* បានចាប់កំណើតឡើងដើម្បីបំរើឱ្យវប្បធម៌ថ្មី ដែលមិនផ្អែកលើមូលដ្ឋាននៃវប្បធម៌ចាស់ ដែលមានបំណងលុបបំបាត់ទាំងស្រុងនូវកេរមតិករបស់ដូនតាខ្មែរ ។

ចាប់តាំងពីថ្ងៃរំដោះ ៧ មករា ១៩៧៩មក រដ្ឋាភិបាលកម្ពុជាបានខិតខំអំពាវនាវដល់បណ្ដាប្រទេសនៅលើពិភពលោកដើម្បីជួយស្ដារ និងកសាងឡើងវិញ គ្រប់វិស័យ ដែលក្នុងនោះក៏មានភាសាខ្មែរផងដែរ ។ ប៉ុន្តែ ការរីកចំរើនយ៉ាងលឿននៃភាសាខ្មែរចាប់ពីពេលនោះមក បានផ្ទុកនូវទំនាស់ផ្ទៃក្នុង ដោយមានចលនាធំ១បីគឺ :

- ចលនាដែលមានបំណងថែរក្សាខ្ជាប់ខ្ជួនអ្វីដែលមានមកហើយ ;
- ចលនាដែលមានបំណងឈានទៅរកអ្វីដែលថ្មីដោយផ្អែកលើមូលដ្ឋាននៃអ្វីដែលចាស់ ;
- ចលនាដែលធ្វើសំយោគរវាងចលនាទាំងពីរខាងលើ ។

ចលនាទាំងបីខាងលើនេះ បង្កើតបានជាទំនាស់ដែលកាន់តែមានទំហំធំឡើង១ជារៀងរាល់ថ្ងៃ ហើយជួនកាលមានការរិះគន់ទៅវិញទៅមកដោយមិនផ្អែកលើមូលដ្ឋានវិទ្យាសាស្ត្រច្បាស់លាស់ ។

## II. បញ្ញត្តិ សំព្ទ និងពាក្យ និងកង្វះឯកភាពក្នុងការប្រើប្រាស់ភាសាខ្មែរ

### ក. បញ្ញត្តិ និងប្រសិទ្ធភាពរបស់វា

**១. បញ្ញត្តិ** (Concept) : បញ្ញត្តិជាឧបករណ៍ចិត្តគំនិត ដែលអនុញ្ញាតឱ្យយើងគិតដល់សំណុំលក្ខណៈពិសេសនានា (ដែលបានបង្កើតការយល់របស់វា) ដែលធ្វើឱ្យបានសំរេចនៅក្នុងសំណុំវត្ថុនានា (ដែលបានបង្កើតការលាតសន្ធឹងរបស់វា) [(Un concept est un instrument mental par lequel nous pensons un ensemble de propriétés (formant sa compréhension) comme réalisées dans un ensemble d'objets (constituant son extension)] ។

ឧទាហរណ៍ : បញ្ញត្តិ "មនុស្ស"



មនុស្សជាក់ស្ដែង

ការយល់ :
- មនុស្សជាសត្វឆ្អឹងកង .
- មនុស្សជាសត្វមានដៃពីរ .
- មនុស្សជាសត្វចេះធ្វើនយោបាយ ...

ការលាតសន្ធឹង : សុខ ម៉ុក ជនជាតិខ្មែរ បារាំង វៀតណាម ថៃ ជនជាតិស្បែកស ស្បែកខ្មៅ ...

បញ្ញត្តិមានឈ្មោះថា ជាសញ្ញាណ (Notion) ឬជាគំនិត (Idée) ដែលស្ថិតនៅក្នុងស្មារតី ឬក្នុងខួរក្បាលរបស់មនុស្ស ។

២. ស័ព្ទ (Terme) : ស័ព្ទជាការសំដែងចេញជាសំដីនៃបញ្ញត្តិមួយ ។ ការសំដែងចេញនេះ អាចមានពាក្យមួយ ឬពាក្យច្រើន ។

ឧទាហរណ៍ :
- គុ ជាពាក្យមួយ
- កៅអី ជាពាក្យពីរ
- ត្រីកោណកែង ជាពាក្យបី
- ចតុកោណកែង ជាពាក្យបួន ។

៣. ពាក្យ (Mot) : ពាក្យ ជាការសំដែងចេញ ជាសំនេរនៃបញ្ញត្តិមួយដែលក្នុងនោះមានស័ព្ទមួយ ឬស័ព្ទច្រើន ។

**៤. ប្រភពនៃបញ្ញត្តិ** (Origine du concept) : បញ្ញត្តិកើតឡើង និងរីកចំរើនទៅលើមូលដ្ឋាននៃការប្រតិបត្តិសង្គម ។ បញ្ញត្តិជាលទ្ធផលនៃដំណើរពុទ្ធិ និងដំណើរបូកសរុបពិសោធន៍នៅក្នុងការប្រតិបត្តិនោះ ។ ហេតុនេះ នៅក្នុងសង្គមណាដែលមានសមត្ថភាពខ្ពស់ ដែលមានការប្រតិបត្តិច្រើន ដែលមានការស្រាវជ្រាវច្រើន សង្គមនោះក៏បានបញ្ញត្តិ ស័ព្ទ ឬពាក្យច្រើនដែរ ។ សង្គមណាដែលខ្វះការស្រាវជ្រាវ ឬមានការស្រាវជ្រាវតិចតួច សង្គមនោះមិនមានបញ្ញត្តិ ស័ព្ទ និងពាក្យច្រើនទេ ។

**៥. លក្ខណៈទំបទនៃបញ្ញត្តិ** (Caractères fondamentaux du concept) :

- *លក្ខណៈអត្តនោម័ត* (Caractère subjectif) : និយាយថា បញ្ញត្តិមានលក្ខណៈអត្តនោម័ត ព្រោះមនុស្សជាអ្នកបង្កើតវាឡើង មនុស្សជាអ្នកដាក់ឈ្មោះឱ្យវត្ថុ ឬបាតុភូតណាមួយ ទោះបីវាមានលក្ខណៈរូបីក្តី ឬមានលក្ខណៈអរូបីក្តី ។
- *លក្ខណៈបរានុម័ត* (Caractère objectif) : និយាយថា បញ្ញត្តិមានលក្ខណៈបរានុម័ត ព្រោះវាឆ្លុះបញ្ចាំងឱ្យឃើញខ្លឹមសារនៃវត្ថុ និងបាតុភូត ដោយឥតចំណុះឆន្ទៈអត្តនោម័តរបស់មនុស្សឡើយ ។

  ឧទាហរណ៍ : ខ្លឹមសារបរានុម័តនៃបញ្ញត្តិ ឬពាក្យ *"កៅអី"* គឺទាក់ទងនឹងតំលៃប្រើប្រាស់នៃកៅអីនោះ ។
- *លក្ខណៈបដិសំយោគ* (Caractère dialectique) : សារជាតិនៃវត្ថុ និងបាតុភូតមានលក្ខណៈបដិសំយោគ ព្រោះវាធ្វើចលនា ប្រែប្រួល និងរីកចំរើនឥតឈប់ឈរនៅក្នុងទំនាក់ទំនងសាកល ។ ហេតុនេះ បញ្ញត្តិដែលឆ្លុះបញ្ចាំងវត្ថុ និងបាតុភូតនោះក៏មានលក្ខណៈបដិសំយោគដែរ ពោលគឺបញ្ញត្តិតែងធ្វើចលនាប្រែប្រួល និងរីកចំរើន

នៅក្នុងទំនាក់ទំនងសាកល ។  ហេតុនេះ  យើងត្រូវចេះប្រើប្រាស់បញ្ញត្តិតាមវិធីទន់ភ្លន់ រស់រវើក និងយល់អំពីទំនាក់ទំនង និងបំរែបំរួលរបស់វា ។

ឧទាហរណ៍ : កែវមួយអាចក្លាយជាកែវទឹក   ជាថូផ្កា   ជាប្រដាប់សង្កត់ក្រដាស ជាប្រដាប់ដាក់ប៊ិច ... យោលទៅតាមការប្រើប្រាស់ ។



**៦. ប្រសិទ្ធភាពនៃបញ្ញត្តិ** ( Efficacité du concept) : បញ្ញត្តិ ស័ព្ទ និងពាក្យ ជាផលិតផលនៃដំណើរពុទ្ធិដែលស្ថិតនៅលើសកម្មភាពប្រតិបត្តិជាមូលដ្ឋាន ។ ប៉ុន្តែ នៅពេលដែលវាបានចាប់កំណើតឡើងហើយ វាបែរជាជះឥទ្ធិពលយ៉ាងខ្លាំងទៅលើពុទ្ធិវិញ ។ តក្កវិទូអះអាងថា បញ្ញត្តិជាមធ្យោបាយ ជាឧបករណ៍ និងជាកាំជណ្ដើរនៃពុទ្ធិ ។ គឺជាលទ្ធផលនៃពុទ្ធិដែលឆ្លុះបញ្ចាំងវត្ថុ និងបាតុភូត ដើម្បីបង្កើតបញ្ញត្តិ ស័ព្ទ និងពាក្យថ្មីៗទៀត ។ ឯបញ្ញត្តិថ្មីដែលបានចាប់កំណើតឡើង ក៏ក្លាយជាបង្អែកសំរាប់ពុទ្ធិថ្មីតទៅទៀតដែរ ។

## ខ. កង្វះឯកភាពក្នុងការប្រើប្រាស់ភាសាខ្មែរ

បើតាមការណែនាំពីក្រសួងសិក្សាធិការជាតិនៅសម័យសង្គមរាស្ត្រនិយម ក៏ដូចជាការណែនាំពីក្រសួងអប់រំ យុវជន និងកីឡាសព្វថ្ងៃដែរ ការប្រើប្រាស់ត្រូវផ្អែកលើវចនានុក្រមរបស់សម្ដេចសង្ឃរាជ ជួន ណាត និងផ្អែកលើសទ្ទានុក្រមខេមរយានកម្ម ។  ប៉ុន្តែ  ពាក្យទាំងឡាយនៅក្នុងវចនានុក្រម  និងសទ្ទានុក្រមខាងលើពុំមានចំនួនគ្រប់គ្រាន់សមស្របតាមតំរូវការនៃការស្រាវជ្រាវវិទ្យាសាស្ត្រឡើយ ។  ហេតុនេះ  អ្នកសិក្សា  និងអ្នកស្រាវជ្រាវទាំងឡាយត្រូវផ្អែកលើវចនានុក្រម និងសទ្ទានុក្រមផ្សេងៗទៀតដូចជា :

- វចនានុក្រមបារាំង ខ្មែរ របស់លោក សម ថាំង ;
- វចនានុក្រមបារាំង ខ្មែរ របស់លោក ទេព យក់ ថាវ គណ និង លី វួអុង ;
- វចនានុក្រមអង់គ្លេស ខ្មែរ របស់លោក ព្រាប សុខ
- វចនានុក្រមអង់គ្លេស ខ្មែរ របស់លោក សុខ សាខុន
- វចនានុក្រមខ្មែរ អង់គ្លេស  របស់លោក ទឹម ចិត្រា
- ...ល...។

ក្នុងការបកប្រែពាក្យមួយចំនួនធំ  ជាពិសេសពាក្យបច្ចេកទេសពីភាសាបារាំង  ឬពីភាសាអង់គ្លេស  មកជាភាសាខ្មែរ  អ្នកបកប្រែពុំបានប្រើពាក្យដូចគ្នាទេ ។ រីឯអ្នកស្រាវជ្រាវដែលផ្អែកលើវចនានុក្រមទាំងនោះ  ក៏បានប្រើពាក្យខុសៗគ្នាដែរ ។ ម្យ៉ាងវិញទៀត នៅមានពាក្យជាច្រើន ដែលពុំមាននៅក្នុងវចនានុក្រមដែលមានស្រាប់ ។ អ្នក

ស្រាវជ្រាវបង្ខំចិត្តបង្កើតពាក្យខ្មែរ បាលី-ខ្មែរ ឬសំស្ក្រឹត-ខ្មែរ ដោយខ្លួនឯង ឬរក្សាទុកពាក្យនោះតាមពាក្យបារាំង ឬអង់គ្លេស។

នៅទីនេះ យើងនឹងលើកឧទាហរណ៍មួយចំនួនមកបញ្ជាក់ដូចតទៅ –

- ការបកប្រែ :

| | |
|---|---|
| → Dialectique (ពាក្យបារាំង)<br>→ Dialectic (ពាក្យអង់គ្លេស) | • បដិសំយោគ<br>• បដិច្ចសមុប្បាទ<br>• វិចារវិទ្យា |
| → Processus (ពាក្យបារាំង)<br>→ Process (ពាក្យអង់គ្លេស) | • ដំណើរ<br>• អភិក្រម<br>• លំនាំ |
| → Représentation (ពាក្យបារាំង)<br>→ Representation (ពាក្យអង់គ្លេស) | • រូបារម្មណ៍<br>• លំនឹកគិត<br>• តំណាង |

- ការសរសេរ :
  - → សំនើ ឬ សំណើ
  - → ដំលៃ ឬ តំលៃ ឬ តម្លៃ
  - → ឯកភាវូបនីយកម្ម ឬ ឯកភាពនីយកម្ម ឬ ឯកភាពកម្ម
  - → អន្តរបញ្ញត្តិ ឬ អន្តរប្បញ្ញត្តិ
  - → អវសានប្បញ្ញត្តិ ឬ អវសានបញ្ញត្តិ ឬ អវសានបញ្ញត្តិ
  - → អារក ឬ អារ.ក
  - → ទូកង ឬ ទូក.ង
  - → ប្រសិទ្ធភាព ឬ ប្រសិទ្ធិភាព
- ការអាន :

| | |
|---|---|
| → នាយកដ្ឋាន ត្រូវអានថា | នា-យក់-កាក់-ថាន<br>នា-យាក់-កាត់-ថាន |
| → បទដ្ឋាន ត្រូវបានអានថា | បត់-ថាន<br>បាក់-ទាត់-ថាន |

→ វិទ្យា ត្រូវបានអានថា { វិត-ទ្យា / វិត-ត្យា }

- ការយកនាមធ្វើជាកិរិយាស័ព្ទ :

  → ខ្ញុំសំណូមពរថា ...

  → ខ្ញុំទំនាក់ទំនងជាមួយលោក ...

  → ខ្ញុំជំនួយលោក ...

- ក្នុងករណីមួយចំនួនដែលគួរកត់សំគាល់

  → សាហាយៈ(ភាសាបាលី) ត្រូវបានយកមកប្រើប្រាស់ក្នុងន័យមិនល្អនៅក្នុងប្រទេសកម្ពុជា តែត្រូវបានយកទៅប្រើប្រាស់ក្នុងន័យល្អនៅប្រទេសលាវ ។

  → ប្រឹង : នៅក្នុងខេត្តជាច្រើននៅប្រទេសកម្ពុជា ពាក្យ "ប្រឹង" មានន័យថាខំឡើង ។ ឧទាហរណ៍ : ចូរអ្នកប្រឹងរត់អោយឆាប់ដល់គោលដៅ ។ ប៉ុន្តែ នៅក្នុងស្រុកខ្លះនៃខេត្តស្វាយរៀង ពាក្យ "ប្រឹង" មានន័យថា ឈប់ស្ងៀម ឬសម្ងំទៅវិញ ។ ឧទាហរណ៍ : ចូរអ្នកប្រឹង ! (ចូរអ្នកនៅស្ងៀម ! ឬចូរអ្នកសម្ងំ !) ។

## គ. ហេតុសំខាន់ៗដែលបណ្តាលឱ្យខ្វះឯកភាពក្នុងការប្រើប្រាស់ភាសាខ្មែរ

ភាសាខ្មែរបាត់បង់ឯកភាពតាំងពីយូរយាមកហើយ ។ យើងអាចធ្វើការប៉ាន់ស្មានថា នៅពេលដែលយើងជាប់ដៃនឹងសង្គ្រាមកាន់តែខ្លាំង ការបាត់បង់ឯកភាពនោះក៏កាន់តែមានកំរិតខ្ពស់ដែរ ។ សូម្បីតែនៅក្នុងសម័យសង្គមរាស្ត្រនិយម ដែលជាសម័យមួយធ្វើឱ្យកម្ពុជាស្ថិតនៅក្នុងសន្តិភាព ភាសាខ្មែរក៏មានទំនាស់ដែរ ។ នោះជាទំនាស់រវាងចលនាដែលដើរតាមមាគ៌ារបស់សម្តេចសង្ឃរាជ ជួន ណាត និងចលនាដែលដើរតាមមាគ៌ារបស់លោក កេង វ៉ាន់សាក់ ។ ដើម្បីសំរបសំរួលបញ្ហានេះ គណៈកម្មការជាតិមួយបានកើតឡើង ។ ប៉ុន្តែ គណៈកម្មកាជាតិនោះត្រូវបានរលាយបាត់បង់ទៅវិញទន្ទឹមនឹងការផ្ទុះឡើងជាបន្តបន្ទាប់នៃសង្គ្រាមស៊ីវិល ។

យើងអាចសរុប ហេតុសំខាន់ៗដែលបណ្តាលឱ្យខ្វះឯកភាពក្នុងការប្រើភាសាខ្មែរដូចខាងក្រោម ÷

- ការបាត់បង់គណៈកម្មការភាសាជាតិដើម្បីសំរបសំរួល
- ការផ្អែកលើវចនានុក្រមណាមួយ
- កង្វះឯកភាពរវាងវចនាក្រមនានា
- ការបង្កើតពាក្យថ្មីដែលគ្មាននៅក្នុងវចនានុក្រមណាមួយ
- ការប្រើពាក្យតាមទំនើងចិត្ត មិនផ្អែកលើវេយ្យាករណ៍
- អសមត្ថភាពក្នុងការប្រើពាក្យតាមមុខវិជ្ជាឯកទេស ។

ហេតុសំខាន់ទាំង៦យ៉ាងខាងលើនេះបង្កឱ្យមានភាពអនាធិបតេយ្យក្នុងភាសាខ្មែរ ។ ប៉ុន្តែ ការណ៍នេះពុំមែនកើតឡើងដោយបំណងអាក្រក់ណាមួយទេ ។ ព្រោះអ្វី ? ព្រោះអ្នកស្រាវជ្រាវគ្រប់ស្ថាប័នត្រូវការប្រើប្រាស់ពាក្យតាមតំរូវការជាចាំបាច់ឱ្យទាន់ពេលវេលា ។ ហេតុនេះ មិនគួរយើងទំលាក់កំហុសទៅលើក្រុមណាមួយ ឬបុគ្គលណាម្នាក់ទេ ។ ការចោទប្រកាន់គ្នាទៅវិញទៅមកគ្មានបានផលចំណេញអ្វីឡើយ ។ រីឯអ្នកដែលធ្លាប់ប្រើពាក្យណាមួយដោយផ្អែកលើមូលដ្ឋានណាមួយ ក៏គួរតែបន្ទន់ឥរិយាបថ ហើយព្រមកែតំរូវវិញ ប្រសិនបើគណៈកម្មការជាតិយល់ថា គួរកែលំអ ។ បញ្ហាសំខាន់បំផុតនោះ គឺការប្រញាប់ប្រញាល់រួបរួមគ្នារកដំណោះស្រាយរួមមួយដែលមានលក្ខណៈសមស្រប និងមានហេតុផលច្បាស់លាស់ ។

## III. ការរួមចំណែកផ្តល់យោបល់ក្នុងការដោះស្រាយបញ្ហា

ក្នុងការដោះស្រាយបញ្ហារួម យើងគួរប្រើវិធីមួយចំនួនដូចខាងក្រោម :

១- គួរវិទ្យាស្ថានភាសាជាតិប្រមូលបញ្ញវន្តខ្មែរ ទាំងនៅក្នុងប្រទេស ទាំងនៅក្រៅប្រទេសដែលមានបំណងជួយពង្រឹងពង្រីកភាសាខ្មែរ ឱ្យអ្នកនោះក្លាយជាសមាជិក សមាជិកានៃគណៈកម្មការភាសាជាតិ ដោយបំពេញការងារជាអចិន្ត្រៃយ៍ ឬបំពេញការងារតាមរយៈការឆ្លើយឆ្លង ។

២- គួរគ្រប់និន្នាការទាំងអស់ឯកភាពគ្នាខាងផ្នែកស្មារតីជាមុនសិន ដោយមានការអត់ឱន យោគយល់គ្នាទៅវិញទៅមក ។ ក្នុងករណីដែលខ្វះការយោគយល់គ្នា ការងារនេះមិនអាចបានសំរេចផលល្អឡើយ ។

៣- គួរបែងចែកជាក្រុមតាមមុខវិជ្ជាឯកទេស ព្រោះមុខវិជ្ជានីមួយ១មានភាសាដោយឡែករបស់វា ។ មានតែអ្នកឯកទេសតាមមុខវិជ្ជានីមួយ១ទេ ដែលយល់ន័យពិតរបស់ពាក្យនីមួយ១ ។ ក្នុងករណីនេះ ក្រុមអ្នកឯកទេសត្រូវមានឯកភាពជាមួយគ្នាជាចាំបាច់ ។

៤- ក្នុងការប្រើពាក្យឯកទេស គួរមានគណៈកម្មការកណ្តាលមួយសំរាប់ពិនិត្យទូទៅ ។ បន្ទាប់មក គួរផ្សព្វផ្សាយសទ្ទានុក្រមទាំងឡាយដល់គ្រប់មជ្ឈដ្ឋាន ដើម្បីទទួលការរិះគន់មុននឹងចាត់ទុកថា ជាបានការ ។

៥- ពាក្យបច្ចេកទេស ឬពាក្យដែលមានលក្ខណៈចំរូងចំរាស់ដែលបានសាកល្បងយកមកប្រើ ត្រូវតែផ្សព្វផ្សាយដល់សាធារណៈជន ដើម្បីឱ្យសាធារណៈជនគាំទ្រផងដែរ ។

៦- វចនានុក្រមថ្មី ឬសទ្ទានុក្រមថ្មី គួរត្រូវបានកែលំអ និងបោះពុម្ពសាថ្មីក្នុងរយៈពេល៥ឆ្នាំម្តង ។ ការងារនេះត្រូវតែប្រព្រឹត្តទៅយ៉ាងទៀងទាត់ ។

៧- គួររក្សាទុកវចនានុក្រមចាស់ និងសទ្ទានុក្រមចាស់ ដើម្បីធ្វើជាមូលដ្ឋានបង្អែកសំរាប់ការពិចារណា។ ការកែប្រែវចនានុក្រម និងសទ្ទានុក្រមទាំងនេះ មិនអាចប្រព្រឹត្តទៅបានទេ ប្រសិនបើគ្មានការអនុញ្ញាតពីរដ្ឋាភិបាល និងរដ្ឋសភា។

ជាសេចក្តីសន្និដ្ឋាន ទំនាស់ក្នុងភាសាជាតិកាន់តែមានលក្ខណៈធ្ងន់ធ្ងរឡើងៗ ដែលជាហេតុមួយបណ្តាលឱ្យមានការបែកបាក់សាមគ្គីភាពរវាងខ្មែរ និងខ្មែរផង និងបណ្តាលឱ្យអ្នកប្រើប្រាស់ភាសាខ្មែរមានការវង្វេងច្រឡំបល់ផង។ ដើម្បីរួមចំណែកដោះស្រាយទំនាស់នេះ យើងគួរប្រើវិធីវិទ្យាសាស្ត្រប្រកបដោយហេតុផលច្បាស់លាស់។ ការលុបបំបាត់អនាធិបតេយ្យដូចបានពោលខាងលើ ពិតជាធ្វើឱ្យអក្សរសាស្ត្រខ្មែរឈានទៅរកសេចក្តីរីកចំរើន។ ក្នុងករណីដែលស្ថិតនៅក្នុងសភាពអល់ឯក ស្ទាក់ស្ទើរ មិនហ៊ានអារកាត់បញ្ហា យើងពិតជាមិនអាចរកឃើញឯកភាពក្នុងភាសាបានឡើយ។

សេចក្តីក្លាហានក្នុងការជំនះរាល់ឧបសគ្គនានាដើម្បីឯកភាវូបនីយកម្មភាសាខ្មែរ មានន័យថា រួមចំណែកធ្វើឱ្យភាសាខ្មែររីកលូតលាស់តាមមាគ៌ាសមស្របមួយ។ នេះជាស្នាដៃមួយដ៏ថ្លៃថ្លាសំរាប់បន្តឱ្យកូនចៅយើងជំនាន់ក្រោយ។

* * *

# ឯកភាវូបនីយកម្មអក្ខរាវិរុទ្ធ ពាក្យបច្ចេកទេស និងពាក្យវិទ្យាសាស្ត្រ

( ដោយអោយ គីម សមាជិក គ.ជ.ប )

ពាក្យបច្ចេកទេស ពាក្យវិទ្យាសាស្ត្រ និងបញ្ហាអក្ខរាវិរុទ្ធ គឺជាបញ្ហារបស់ប្រទេសតតិយលោក ដែលតែងជួបប្រទះ ក្រោយពីរួចផុតពីនឹមត្រួតត្រារបស់បរទេស ។ ដោយឡែកប្រទេសកម្ពុជា មាន លក្ខណៈផ្សេងមួយទៀត គឺក្រោយពីឯករាជ្យឆ្នាំ ១៩៥៣ហើយ ប្រទេសជាតិបានសុខសន្តិភាព តែជាង ១០ឆ្នាំ បន្ទាប់មកមានសង្គ្រាមធ្ងន់ធ្ងរ និងធ្លាក់ចុះក្នុងរបបនរករបស់ប៉ុលពត ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ភាសាខ្មែរ ដែលត្រូវបានប្រកាសអោយប្រើជាផ្លូវការ ជាទូទៅតាមសំណូមពររបស់សមាជជាតិលើកទី ២៣នាឆ្នាំ ១៩៦៧ បានលូត លាស់យ៉ាងល្អ ទទួលលទ្ធផលដ៏ប្រសើរ មានការឯកភាពគ្នា យ៉ាងខ្ពស់ ក្នុងសង្គមជាតិទាំងមូល ទោះបីភាសា បារាំងនៅបន្តការប្រើប្រាស់ក្នុងរដ្ឋបាលរហូតដល់ឆ្នាំ ១៩៧៥ក៏ដោយ ។ ខេមរយានកម្មនៅ បឋមសិក្សា និង មធ្យមសិក្សា ចាប់អនុវត្តជំនួសភាសាបារាំងតាំងពីឆ្នាំ ១៩៦៧-៦៨ ហើយតាមគំរោងផែនការ ត្រូវចាប់ ផ្តើមអនុវត្តនៅឧត្តមសិក្សាចាប់ពីឆ្នាំ ១៩៧៤-១៩៧៥ តែអកុសលដោយសង្គ្រាមចាប់ពីឆ្នាំ ១៩៧០មកធ្វើ អោយភារកិច្ចរបស់អង្គការខេមរយានកម្មត្រូវជួបប្រទះការលំបាក រអាក់រអួល មិនតែប៉ុណ្ណោះវិស័យអប់រំ រួមទាំងវិស័យផ្សេងៗទៀតរបស់ប្រទេសជាតិទាំងមូលត្រូវបានកំទេចទាំងស្រុងក្រោម របបវិនាសកម្ម ប៉ុលពត នាឆ្នាំ ១៩៧៥ ។

បញ្ហាមិនចុះសំរុងទាំងការបង្កើតពាក្យបច្ចេកទេស ទាំងអក្ខរាវិរុទ្ធនាពេលបច្ចុប្បន្នក៏មិនខុសនឹងបញ្ហាចំរូងចំរាស់ មុនការបង្កើតអោយមានគណៈកម្មាធិការជាតិអចិន្ត្រៃយ៍ខេមរយានកម្មដូច្នោះដែរ ។ ក្រុមនីមួយៗ សុទ្ធតែសំអាងហេតុផលរៀងៗខ្លួនក្នុងការប្រកាន់ទស្សនៈរបស់ខ្លួន ។

ក្រុមដែលមាននិន្នាការទៅរកបាលី-សំស្ក្រឹតតែងចង់អោយបង្កើតពាក្យបច្ចេក ទេសវិទ្យាសាស្ត្រចេញពីប្រភពបាលី-សំស្ក្រឹត ដោយហេតុថាភាសាយើងមានប្រើពាក្យបាលី-សំស្ក្រឹតរហូតដល់ ៦០%-៧០%...

ក្រុមអ្នកចេះភាសាបរទេសដទៃទៀត ដូចភាសាបារាំង អង់គ្លេស... យល់ថាត្រូវបកប្រែឬកែច្នៃ ឬយកពាក្យបច្ចេកទេស ពីពាក្យបច្ចេកទេស ពីភាសាបរទេសជឿនលឿនទាំងនោះមកប្រើ ព្រោះចំណេញដល់ការសិក្សា ការយល់ដឹង នឹងការស្រាវជ្រាវបន្ត...

ក្រុមខ្លះទៀតយល់ថាទង្វើទាំងពីរខាងលើនេះ ពុំសមស្របល្អទេ គួរស្រាវជ្រាវក្នុងភាសាខ្មែរជាមុនសិន ព្រោះខ្មែរយើងក៏មានវប្បធម៌ អរិយធម៌រុងរឿងរបស់ខ្លួន មុនភាសាបាលី-សំស្ក្រឹត និងភាសាដទៃៗទៀតចូលមកដែរ ។ ខ្មែរមានមូលដ្ឋានភាសា មានក្បួនច្បាប់ច្បាស់លាស់ អាចទំនាក់ទំនងគ្នា និយាយស្តាប់

គ្នាបានទៅវិញទៅមក និងមានសិលាចារឹកជាភាសាខ្មែរសុទ្ធសាធផង ។ បើគេពុំបានទើបត្រូវមើលក្នុង បាលី-សំស្ក្រឹតឬបរទេស តែត្រូវកែច្នៃពាក្យនោះអោយមកជាលំនាំខ្មែរ ព្រោះខ្មែរក៏ដូចជាជនជាតិដទៃ ដែរ ពុំចូលចិត្តយកពាក្យគេមកប្រើទាំងស្រុងទេ ពិសេសទៅទៀតលក្ខណៈភាសាខ្មែរច្រើនជាពាក្យ ឯកព្យាង្គ ហើយបិត ក្នុងអំបូរមន-ខ្មែរ មិនដូចភាសាបាលី-សំស្ក្រឹតដែលបិតក្នុងអំបូរ ឥណ្ឌូ-អឺរ៉ុប ទេ ។ ទស្សនៈទាំងអស់ខាងលើនេះពិតមែនតែមានហេតុផលរៀងៗខ្លួនតែមានចំណុចខ្លាំងចំណុចខ្សោយរៀងៗខ្លួន ។

ឈានមកដល់សព្វថ្ងៃយើងឃើញបញ្ហាថ្មីមួយចំនួនទៀត ដែលជាបញ្ហាមួយគួរអោយអស់សំណើច ។ ពាក្យខ្លះយើងធ្លាប់មាន ធ្លាប់ប្រើរួចមកហើយ តែបែរជាអោយអ្នកផ្សារ ដែលមិនសូវចេះភាសាខ្មែរ យកមក ប្រើ រហូតដល់ខ្មែរមួយចំនួនធំ ដែលចេះភាសាខ្លួនហើយ ទទួលយកដោយឥតទើសទាស់ ហើយបានប្រើ ក្នុងលិខិតស្នាម និង ក្នុងលិខិតផ្លូវការ ក្នុងរដ្ឋបាល តាមវិទ្យុ ទូរទស្សន៍ ថែមទៀត ។

| | | | |
|---|---|---|---|
| ឧ. ទិញកង់ឡាន | ៣៤ គ្រាប់ | ប្រៀបធៀប : | ពោតបីស្ទីក |
| ទិញអាគុយ | ២០ គ្រាប់ | | ចានមួយ |
| ខេត្តកំពតមាន | ៨ វិទ្យាល័យ | | មួយចាន |
| ក្រុងកំពង់សោមមាន | ៤០ សាលារៀន | | |
| ខ្យល់ព្យុះធ្វើអោយខូច | ១៤ ផ្ទះ ។ល។ | | |

ដូចគ្នានិងបញ្ហាបង្កើតពាក្យថ្មីដែរ បញ្ហាអក្ខរាវិរុទ្ធ ក៏មានភាពមិនចុះសំរុងគ្នាដែរ រហូតពេលខ្លះ ក៏មានការចោទប្រកាន់គ្នាជាពាក្យសំដីចូរទ់ចូរដាក់គ្នាទៅវិញទៅមកផង ។ ហេតុផលទាំងនោះ គឺសំអាងលើ ទស្សនៈ សរសេរ :

- ផ្អែកទៅតាមទំលាប់ ទៅតាមការចេះដឹងកន្លងមក (តាមពិតទំលាប់ឬការចេះដឹងក្នុងសម័យកាលមួយជាកំណត់ព្រោះ អាចខុសគ្នាពីសម័យកាលមួយទៅសម័យកាលមួយ)

  ឧ. ក្នុងសម័យអាប់ឌិនក្រោមអាណានិគមនិយមបារាំង ក្នុងសាស្ត្រាស្លឹករឹតសរសេរ ស្វាយ បញ្ចូលអោយខ្ចី : ហ្សៀ វភ្សៀ ឱ្យ មារ្យ

- ផ្អែកទៅតាមប្រភពដើម និង អក្ខរាវិរុទ្ធនៃពាក្យបរទេស ឧ.ម៉ែត្រ កុងរ៉ូយ៍

  axe=អ័ក្ស

- ផ្អែកទៅតាមលក្ខណខ្មែរដោយរក្សាអោយស្គាល់ប្រភព និង អក្ខរាវិរុទ្ធដើមនៃពាក្យ :

  ប្រយោជន៍ < សំ.ប្រយោជន.បា.បយោជន

  នារាយណ៍ < បា.សំ នារាយណ

  ពេចន៍ < បា.សំ វចន (ពាក្យពេចន៍)

- ផ្អែកតាមពាក្យបរទេសតែធ្វើអោយខ្លី តាមលក្ខណៈខ្មែរសុទសាធ

  amplificateur អំព្លី

  fluorescent ភ្លុយអរ

  accumulateur អាគុយ

- ផ្អែកទៅតាមសំនូរ ( ឮដូចម្តេចសរសេរយ៉ាងនោះ )

| | | |
|---|---|---|
| test | តេស | ព្រោះតាមភាសាវិទ្យាគេអាចសរសេរតាមលំនាំអក្ខរាវិរុទ្ធដើមនៃពាក្យក៏បាន ឬតាមសំនូរក៏បាន ។ |
| Marseille | ម៉ាកសី | |
| antenne | អង់តែន | |
| fréquence | ប្រេកង់ | |

- ទៅតាមឫសគល់នៃពាក្យ :

  កើត ⟶ ខ្មើត ( ជើងន ) ⟶ កំនើត

  ស្មើ ( ជើងន ) ⟶ សំនើ

  ល្បង ⟶ ប្រលង ។ល។

យើងនៅចាំបានថា ទស្សនៈនានានិងទំនាស់ទាំងការបង្កើតពាក្យថ្មី ទាំងអក្ខរាវិរុទ្ធ ទាំងអស់ខាងលើ ត្រូវបានបញ្ចប់នៅពេលកើតគណៈកម្មាធិការជាតិអចិន្ត្រៃយ៍ខេមរយានកម្ម ដែលទទួលភារៈពីរាជរដ្ឋាភិបាល ប្រមូលផ្តុំបញ្ញាជនគ្រប់និន្នាការទាំងអស់មកចូលរួមជាគណៈកម្មការស្រាវជ្រាវ បង្កើត អនុម័តពាក្យថ្មី ក្រោមព្រះអធិបតីភាពកំពូល( ពាក្យតាមសេចក្តីសំរេចរបស់ក្រសួងអប់រំ ) របស់សម្តេចព្រះសង្ឃរាជជូនណាត និង សម្តេចព្រះពោធិវង្ស ហួត តាត ដោយមានការគាំទ្រយ៉ាងពេញទំហឹង ពីព្រះករុណាសម្តេចព្រះនរោត្តមសីហនុ និង ពីរាជរដ្ឋាភិបាលទាំងមូល ។ សៀវភៅសិក្សាគ្រប់មុខវិជ្ជា រហូតដល់ថ្នាក់ទី១ទំនើបជាតិ និង សទ្ទានុក្រម ខេមរយានកម្ម ត្រូវបានបោះពុម្ព និងដាក់អោយប្រើប្រាស់ជាផ្លូវការ ទទួលបានការឯកភាពក្នុងការសិក្សា ការប្រើប្រាស់ និងការទទួលស្គាល់ពីគ្រប់មជ្ឈដ្ឋាន ។

ដូចនេះបច្ចុប្បន្ន តើយើងត្រូវធ្វើបែបណា ?

គ្មានផ្លូវណាត្រូវដើរផ្សេងពីផ្លូវគណៈកម្មាធិការជាតិអចិន្ត្រៃយ៍ខេមរយានកម្មបានធ្វើនោះទេ គឺត្រូវប្រមូលក្បួនខ្នាតទាំងអស់របស់ គណៈកម្មាធិការជាតិអចិន្ត្រៃយ៍ខេមរយានកម្មមកអនុវត្តបន្តដោយឥតកែប្រែ ទាំងវិធី បង្កើតបច្ចេកសព្ទថ្មី ទាំងអក្ខរាវិរុទ្ធ និយាយអោយខ្លី គឺត្រូវបន្តស្នាដៃខេមរយានកម្មរហូត ដល់ចប់ឧត្តមសិក្សា ពុំនោះទេ :

១-នឹងកើតមានបញ្ហាចំរូងចំរះសាជាថ្មី ( ព្រោះក្បួនខ្នាតទាំងនេះរួមទាំងគោលការណ៍អនុម័តពាក្យត្រូវបានទទួលការឯកភាពខ្ពង់ខ្ពស់និងទូលំទូលាយពីគ្រប់មជ្ឈដ្ឋាន ពិសេសពីសម្តេចសង្ឃរាជ ជួន ណាត និង

សម្តេចព្រះពោធិវង្ស ហួត តាត ហើយបានប្រកាសអោយប្រើជាផ្លូវការដោយក្រសួងអប់រំតំណាងអោយរាជរដ្ឋាភិបាលហើយ ) ។

២-នឹងធ្វើអោយសង្គមទាំងមូល ពិសេសមជ្ឈដ្ឋានសិក្សាស្រាវជ្រាវវង្វេង ច្របូកច្របល់ និងឡប់ទាំងអស់គ្នា ព្រោះ :

- សៀវភៅសិក្សាបានចងក្រងតាមបែបខេមរៈយានកម្មនៃគណៈកម្មាធិការជាតិអចិន្ត្រៃយ៍ខេមរយានកម្មទៅហើយ ។
- គ្រូបង្រៀន សាស្ត្រាចារ្យទាំងអស់បានទទួលការបណ្តុះបណ្តាលតាមខេមរៈយានកម្មនេះ ទៅហើយ ។
- សិក្សានុសិស្សជាច្រើនជំនាន់មកហើយបានទទួលការបណ្តុះបណ្តាលតាមសៀវភៅទាំងនេះរួចមកហើយ ។
- ឯកសារ សទ្ទានុក្រមខេមរៈយានកម្មត្រូវបានបោះពុម្ព ហើយត្រូវបានប្រកាសអោយប្រើ ជាផ្លូវការ គ្រាន់តែវចនានុក្រមពុំទាន់បានកែសំរួល ពុំទាន់បានបញ្ចូល និងបោះពុម្ពជាថ្មីតាមគណកម្មការ អនុម័តពាក្យប៉ុណ្ណោះ ដោយហេតុសង្គ្រាម និងរបបអន្ធការនិយមប៉ុល ពត ។

៣ -នឹងជួបវិបត្តិ ទទួលបរាជ័យ ខាតពេល ពុំអាចដើរទៅមុខបាន ព្រោះធនធានបញ្ញាវន្ត ការងារ និងបញ្ហាសេដ្ឋកិច្ចសព្វថ្ងៃពុំអាចអនុគ្រោះអោយយើងស្រាវជ្រាវ ធ្វើខេមរយានកម្មថ្មីមួយទៀតបានទេ( ខេមរយានកម្មលើកមុនធ្វើប៉ុន្មានឆ្នាំ ? មនុស្សប៉ុន្មាន? ថវិកាប៉ុន្មាន ? )

ដូចនេះត្រូវឯកភាពគ្នាបន្តស្នាដៃខេមរយានកម្មបន្តទៅទៀត ។

ចំពោះវិធីអនុវត្ត គប្បីស្នើសុំសេចក្តីសំរេចយល់ព្រមលើគោលការណ៍ចាំបាច់ ដែលត្រូវបន្តមូលដ្ឋានក្បួនខ្នាត ស្នាដៃខេមរយានកម្មមុនតទៅទៀត ពីរាជរដ្ឋាភិបាល ឬបើអាចធ្វើបានពីរដ្ឋសភាទៀត ដើម្បីប្រមូលបានទូវការឯកភាព ទាំងខាងយល់ដឹង វិទ្យាសាស្ត្រទំនើប១ទាំងការសាមគ្គីភាពផ្ទៃក្នុង ដូចជំនាន់គណៈកម្មាធិការជាតិអចិន្ត្រៃយ៍ខេមរយានកម្ម ។

ឆាយ គីម សមាជិក គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
អតីតសាស្ត្រាចារ្យមធ្យមសិក្សាទុតិយភូមិ
អតីតប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា

Pogibenko Tamara
Institute of Oriental Studies
Russian Academy of Science
Moscow

## Logical-semantic approaches to Khmer grammar: the category of number

Logical-semantic analysis has contributed a lot to our better understanding of language categories and function. In fact, many of the categories it reveals as pertaining to the logical-semantic level of representation of utterences in discourse can be found as surface phenomena in South-East languages. Although they are often referred to as languages lacking many of the grammatical categories found outside the so-called isolating type, they still possess a grammar which is no less rich in categories but they are often of a logical-semantic nature.

In Khmer unlike in many languages outside the isolating type not all NPs with a common noun in head position are marked for number in sentences in discourse. That is generally accepted to be a good reason to consider that there is no such grammatical category in Khmer. The non-obligatory character of marking for number in languages like Khmer has always been explained in terms of redundancy, that is whenever number is expressed otherwise or is understood from the situation. number markers become non-obligatory. So that there are no strict rules to follow, just common sense. That is one of the reasons why languages like Khmer are often called «exotic» in handbooks in linguistics and linguistic typology (see for instance [Croft 1993: xi]), which implies that in «normal» languages all NPs should be marked for number. But if we come to look upon the grammar of a language as a means of organizing cognitive and communicative content [Hopper, Traugott 1994: 17] we often find that grammars of the traditionally studied languages are no less if not even more «peculier» and «exotic» in the way they organize the content, and their grammatical categories are often misleading when we come to analize the logical structure of utterences.

A «does not exist» verdict in respect to the grammatical category of number in languages like Khmer says little or noting about the real complexity and sophisticated nature of the grammar fragment in question; even worse, it leaves unnoticed some universal aspects which might have contributed to our better understanding of how a language functions.

The examination of number expressions in Khmer, i.e. the expressions *muəy [CLF]* - used for singular, *muəy cɒmnuən*, *tĕəŋ laay* etc. - used for plural, shows that the rules of their usage / non-usage are no less obligatory than the rules of using number markers in traditional languages where number is grammaticalized. though they are formulated in different terms. In Khmer it is the logical-semantic and functional type of the description (the notion introduced by B.Russel in respect to a common noun or an NP with a common noun in head position) that determines the rules of marking for number.

The number expressions are obligatory in **introductory descriptions** - referential NPs, introducing a specific object or objects into the discourse. So the

grammatical function of number expressions is more like that of a determiner, and in fact in introductory NPs number expressions are co-functional with other types of determiners or determining expressoins: when the latter are present, the number expressions are not used. Consider the following examples where introductory NPs are marked for number, in (1) and (3) plurality is marked by reduplication of the modifier:

(1)

| | | | | | | |
|---|---|---|---|---|---|---|
| *muəy* | *srɒbɒk* | *sou* | *siəŋ* | *cɒmriəŋ* | *lɔvəəy* | *lɔvəəy* |
| one | moment | sound | sound | singing | faint | faint |
| *rɔsaat* | *mɔɔk* | *pah* | *saot* | *bɒsaat* | *yuvẽə?cɔn* | |
| float | come | collide | ear | sense | young man | |

'For a single moment faint sounds of singing reached his ears'

(2)

| | | | | | | |
|---|---|---|---|---|---|---|
| *yuvẽə?cɔn* | *chɔɔ* | *aep* | *nɯŋ* | *phtẽəŋ* | *thmɒɒ* | *muəy* |
| young man | stand | touch | COMIT | CLF | stone | SG |
| *sɒmlɯŋ* | *rɔɔk* | | *mə̀əl* | *mcah* | *cɒmriəŋ* | |
| peer | look for; DIR | | look | owner | song | |

'The young man stood touching a stone, trying to see who was the person singing'

(3)

| | | | | | |
|---|---|---|---|---|---|
| *yuvẽə?cɔn* | *bɒntɒɒ* | | *dɒmnaə* | *taam* | *ksae* | *tɯk* |
| young man | continue | | movingalong | rope | water | |
| *kraom* | *mlup* | *rukkha* | *thom* | *thom* | | |
| under | shade | tree | big | big | | |

'The young man continued his way along the river under the shade of big trees'

In **co-referential identifying descriptions** - that is NPs which are the second and the following nominations of the same object or objects in the discourse and which are co-referential with the corresponding introductory NPs, number expressions become zero anaphoric. The rule ordering this type of anaphora is motivated by the function of identifying NPs: their purpose is not to repeat all the meaningful components of the preceding nomination but to provide reference to the same object or objects by means of co-reference, this way the task of discourse binding is being fulfilled. The mechanism of semantic anaphora becomes very important in establishing co-reference, actually, that is the reason why identifying NPs are often a sort of semantic reduction of the preceding nomination, and pronouns used anaphorically is not the only means of that semantic reduction.

Number expressions can be used but are not obligatory with another functional type of identifying descriptions: **relational identifying descriptions** - that is NPs which are the first nomination of object or objects whose identification is possible because they stand in some sort of specific relation to the object already introduced into the discourse. Consider the following example where the

introductory $NP_2$ is marked for number, while the identifying $NP_4$ (co-referential with $NP_1$) and $NP_5$ (co-referential with $NP_2$) are left unmarked. the identifying $NP_1$ is the first nomination of objects standing in the «part - whole» relation to an object already introduced into the discourse and therefore it is non-obligatory marked for number:

(4) *viə thmec phnɛɛk tĕəŋ sɒɒŋ khaaŋ srap tae*
3SG close eye MDF both sides suddenly
*rumpic nuh viə khə̀əɲ mŏən khvay muəy*
moment that 3SG see chicken roast SG
*nuw khnoŋ caan viə kɒɒ baek phnɛɛk yaaŋ*
be; at in plate 3SG LNK open eye MDF
*rɔhah mŏən khvay kɒɒ viniəh baat*
quick chicken roast LNK disappear disappear; REZ
*tuw*
go; away
'He closed his eyes ($NP_1$) and suddenly saw a roast chicken ($NP_2$) on a plate ($NP_3$). He opened his eyes ($NP_4$) - the chicken ($NP_5$) dissapeared'

**Predicative descriptions** - that is NPs with a common noun in head position used predicatively, and **non-referential descriptions** - NPs that do not introduce a specific object or objects, are generally not marked for number in Khmer. Consider the following examples: in (5) the introductory $NP_1$ is marked for number, the non-referential $NP_2$ and $NP_4$ are not marked for number, $NP_3$ is a «part-whole» identifying description and therefore is not obligatory marked for number; in (6) the predicative $NP_1$ is not marked for number:

(5) *viə khə̀əɲ sat l?ɯt muəy dael prɒhak prɒhael*
3SG see creature little SG REL alike
*nuŋ sat kɒnlaat bɒntəc pɒntae viə*
with creature cockroach a little but 3SG
*miən kbaal douc kɒndoop*
have head like grasshopper
'He saw a creature ($NP_1$) a little bit like a cockroach ($NP_2$), but with a head ($NP_3$) like that of a grasshopper ($NP_4$)'

(6) *mə̀əl pii cɒmŋaay khə̀əɲ hak dooc ciə*
look from distance see like COP
*mɔhaa kɒmpaeŋ khɯəw*
huge wall blue
'From a distance (it) looked like a huge blue wall ($NP_1$)'

Logical-semantic factors are not the only ones which can determine the functional type of an NP. There are pragmatic factors which must be taken into account: the speaker's attitude and the purpose of communication can influence «participant / non-participant» attribution of a particular NP. Pragmatic factors are often important with instrument and locative NPs. In (4) the locative $NP_3$ is non-participant (cicumstantial), therefore non-referential and not marked for number. In (7), (8) and (9) the instrument NPs which are first nominations of a specific object are supposed to be referential introductory descriptions and therefore be marked for number. In fact in (7) such instrument NP is marked for number, while in (8) and (9) are not (note that in (8) the NPs *dεεk chuuh rɔbɔh kŏət* and *dεεk chuuh* are not first nominations in the discourse, so they are not introductory but identifying). The explanation is that in (7) the speaker is being a little bit didactic and playing instructors with his unimaginative friend and the instrument is part of his instruction, that is why the NP is labelled «participant», gets a referential status and therefore is marked for number:

(7) *khɲom niyiəy kaa puɯt nih dɒl kaaloo aəŋ*
1SG speak NOM true this ADR K. 2SG
*yɔɔk kɒmbɯt muəy chlaak ciə ruup*
take knife SG carve COP form: CLF
*tɒkətɒɒ nuw lɔ̀ə ɒŋkɒt chɔ̀ə nih*
doll LOC on log tree, wood this
'[~What use to take this log home if I have no stove there?] ~I am talking sense to you: take a knife and carve a doll of it'

(8) *kŏət kɒɒ cap yɔɔk dεεk chuuh rɔbɔh kŏət*
3SG LNK begin take plane POSS 3SG
*haəy yɔɔk ɲɔɔɲuə dɒm tuw lɔ̀ə dεεk chuuh*
and take hammer hit go on plane
'He took his plane and hit it with a hammer'

(9) *kŏət cap bɒŋvəl ɒŋkɒt oh nih bɒŋvəl haəy bɒŋvəl*
3SG begin turn log wood this turn REZ turn
*tiət haəy riəp kat viə nuɯŋ puuthaw*
more and get ready cut 3SG INSTR axe
'He began to turn the log this way and that way and was about to cut it with an axe...'

There are situations when logical, semantic and pragmatic factors come to conflict, then conflict of the strategies of marking arises. One of such situations is when a predicative NP normally not marked for number includes a modifier which opens a semantic valency which actually requires a referential NP to fill it. In

Khmer such predicative NPs are obligatory marked for number. Consider the following examples:

(10) *phnum* *kuulen* *ciə* *rĕəmĕəniyĕəʔthaan teesaacɒɒ muəy*
mountain K. COP place of interest tourist SG
*sthɯt nɯw iisaan ney tii kroŋ siəmriəp*
located in north-east POSS place; CLF town S.
'The mountain Kuulen is a tourist place of interest situated north-east from Siemriep'

(11) *kèe* *baan* *khə̀əɲ* *miətoʔphuum* *ciə tii* *sneihaa [...]*
3SG/PL PRF see native land ATR love
*prae klaay ciə tii liən muəy prɒkɒɒp tɯw daoy*
change become COP place SG ATR
*kaa thvɯɯ tuk tòo mnèɲ [...]*
NOM cause sorrow be miserable
'They saw the beloved native land become a place of sorrow and grieve [...]'

We find a similar situation with determiners in English when a non-referential NP changes its determiner when a modifier is added, compare: *She never goes to **the cinema**, Once she went to **the cinema*** and *Once she went to **a large local cinema***; *He was taken to **hospital*** and *He was taken to **a general hospital**; Her children go to **school*** and *Her children go to **an elementary school**.* In both Khmer and English the conflict of the strategies of marking in non-referential NPs means that on the surface level a non-referential NP is marked as a referential one.

Identifying NPs become also marked for number when they include certain types of modifiers, for example:

(12) *haet ɒvey baan ciə psaa cɒmnah muəy nih trəw*
why market old SG this PASS
*baan cŏən bɒɒrɒteeh niyum cool cet*
PASS people foreign like like
'Why do foreigners then like this old market?'

Another situation when logical semantic and pragmatic factors come to conflict is when an introductory NP is repeated where we would normally expect an identifying NP. This happens for a variety of reasons and has often to do with the emotive aspect of utterences in discourse. Full or partial repetition of an introductory NP in the second (and the following) nominations of the same object in a discourse is a device found in many languages. But in Khmer of all the

descriptive components of the introductory NP it is often precisely the number expression that is repeated, while the other descriptive components may be omitted. The emotions involved may be different: surprise, irony, anger etc. When the speaker applies the introductory strategy instead of the identifying one to refer to object or objects already introduced into the discourse, his intention is to hold this referent in focus. Consider the following example where the number expression is repeated in the second nomination of the same object of reference:

(13) *viə miən mut phĕək snət snaal mnĕək mun*
3SG have friend close SG+CLF NEG
*mɛɛn cŏən ciət iitaalii tèe tuw daə lèeŋ yup*
NEG NOM nation Italian NEG go walk play evening
*ciə muəy khniə mɔ̀əl kon ciə muəy khniə haəy*
together look film together and
*aa mnĕək nuh kɒɒ pum khcey duŋ*
PEJOR SG+CLF that LNK quickly know
*thaa əwpuk mdaay rɔbɔh koon khɲom ciə nɔɔnaa daə*
CONJ father mother POSS child 1SG COP who PRT
'She had a close friend, non-Italian, they used to go out in the evenings together, go to the cinema together, then soon this bastard learned who her parents were'

Consider also the following example where the identifying description is not only marked for number, but is marked for number twice - with *tɛ̆əŋ* and with the help of reduplication of the last modifyer in the chain. No doubt it is done because the emotional envolvement of the speaker is very strong and it is expressed otherwise: by way of the many formal or semantic reduplications (and even triplications) throughout the whole sentence, almost in every syntactic position:

(14) *kuə aoy saok sɒŋreeŋ pɔn pèek nah kèe*
ATR grieve grieve very very very 3SG/PL
*khɔ̀əɲ prɒciəcɔn tɛ̆əŋ nuh miən phiəp sleek*
see people all; PL that MDF withered, faded
*slaŋ skɔɔm skaŋ heew hɒt haem*
withered, faded thin weary tired swell up
*sɒmprou sɒmprou*
swollen swollen; PL
'What grieve it was to see all those people, withered, thin, weary, tired swollen'

To conclude, the examination of the usage of number expressions in Khmer takes us back to the initial stages of grammaticalization of number, when number expressions have more to do with reference rather than with the

expression of quantity as such. The universal character of grammaticalization of number in languages is connected with the most fascinating as well as mysterious phenomenon of a natural language, that is the dualistic nature of the common noun, which is used both to refer to specific objects and general notions. This dualism is structurally blurred in languages with a fully grammaticalized number and is clear and transparent in languages like Khmer. In the former, NPs are marked for number even in statements like *What is **a rose**? **Roses** are beautiful, **A rose** needs a lot of sunshine,* where grammatical number has nothing to do with the expression of quantity, and the rules of choosing the right number form are very intricate, sometimes illogical, always language specific and often purely idiomatic (cf. *go on **foot**, make by **hand**, All women were in **evening dress**, People recognized him in **the street**, Look me in **the eye** and say you love me,* etc.). In languages like Khmer, which lack the fully grammaticalized category of number, the rules of marking for number though no less intricate are more in accordance with the logical structure of a statement. The common noun is not supposed to refer to objects: it has an extention, that is the multitude of all potentially possible referents, which is an abstract multitude, it exists due to the abstraction of actual infinity [Paducheva 1985: 84]. As it seems, grammaticalization of the category of number is motivated by the fact, that number makes it possible to single out specific objects of reference and make an NP referential.

In the northern dialect of Khmer we can find a still earlier stage of grammaticalization of number. There are two structural types of introductory NPs: in one of them the number expression is introduced by a classifier as in standard Khmer, in the other it is introduced by a copula [Poopatwiboon Samkiet 1983], for example:

(15) *miiən kmom koon <u>kmom muuy</u>*
have girl child CLF SG
'There lived <u>a daughter</u>'

(16) *miiən mɛɛ cah <u>nəə muəy</u>*
have mother old COP SG
'There lived <u>an old mother</u>'

The second type suggests that number expressions once used to be a separate dependent predication which underwent syntactic compression. In standard Khmer we find the element *ciə* which can be used both as a copula and as one of the markers of dependent predication, in the second function it is used with modifiers of quantity.

So, the specific character of the grammaticalization of number expressions in Khmer suggests that the category of number is connected with reference and with functional type of descriptions in discourse. As a matter of fact, the authors of Por-Royal Grammar have pointed out to the fact that the category of number has to do with reference, they explained it the following way: «The indefinite

meaning of common nouns... forces us to use nouns in two numbers - singular and plural, so that to limit this meaning. There is another way to define the vague meaning of common nouns. Almost in all languages particles were introduced called articles, which define this vague meaning in a different way both in singular and plural»[Grammatica...1998: 115].

## References


*Arutunova N.D.* 1998. Yazyk i mir cheloveka. Moscow. (The Language and World of Man). (in Russian).

*Croft W. 1993.* Typology and Universals. Cambridge: Cambridge University Press.

*Grammatica obshaya i ratsionalnaya Por-Royala.* 1998. Moscow. (The General and Rational Grammar of Por-Royal). (in Russian).

*Hopper P.J., Traugott E.C.* 1994. Grammaticalization. Cambridge: Cambridge University Press.

*Paducheva E.V.* 1985. Vyskazyvaniye i yego sootnesyonnost' s deystvitelnostyu. Moscow. (The Utterance and its Correlations with the Reality). (in Russian).

*Poopatwiboon Somkiet.* 1983. Participant Reference in Northern Khmer. // Mon-Khmer Studies XI. Honolulu.

# អត្ថបទដកស្រង់ពីនាទីសម្ភាសអក្សរសាស្ត្រ

សម្តេចសង្ឃរាជ ជួន ណាត

តទៅនេះ គឺជាអត្ថបទដកស្រង់ពីនាទីសម្ភាសអក្សរសាស្ត្រ របស់សម្តេចសង្ឃរាជជួនណាត។ ខ្ញុំបានស្តាប់ខ្សែអាត់ទាំងអស់ ដែលព្រះតេជគុណ ស្រី សុវណ្ណ បាននាំមកដំកល់ទុកនៅវត្តពុទ្ធរង្សី នាទីក្រុងម៉ែលបួន ប្រទេសអូស្ត្រាលី។ ខាងក្រោមនេះ ជាអត្ថបទដកស្រង់ពីខ្សែអាត់ និងការសិក្សាលើអត្ថបទជាត្រួសៗ ដើម្បីស្វែងយល់អំពីបញ្ហាភាសាខ្មែរ។ អត្ថបទខាងក្រោមនេះ គឺជាសំនួររបស់លោក អ៊ូ ផាន់។

**សំនួរទី១** ពាក្យថា "សារព័ត៌មាន" ពាក្យនេះតើគេច្រើន សរសេរនៅក្នុងកាសែតទាំងឡាយ ហើយគេ មើលថា "សារ-ព័រ-ដ-មាន"។ ទូលបង្គំជាខ្ញុំឆ្ងល់ថា : អក្សរ "ព" ហើយនិង "ត" ពីមុខមាន "រ" លើ "ត" នេះ តើប្រកបដូចម្តេច បានជាគេមើលថា "ព័រ-ដ-មាន"។ បើគេសរសេរអក្សរ សារព័ត៌មាន វាផ្ទាស់យ៉ាងណា។ បើតាមទូលបង្គំ ធ្លាប់យល់វិញ គួរសរសេរយ៉ាងនេះ សារព័ណ៌ដ៏មាន គឺសរសេរ ព័ណ៌ ហើយ "ដ" ដោយខ្លួនដាក់លេខ ៨ ពីលើថា ព័រ-ណៈ-ដ៏-មាន ឬសារប្រវត្តិបានសេចក្តីថា ដំណឹង ពិតប្រាកដ។ លោកយល់នឹង ដោយយោបល់លោកក៏ម្យ៉ាងហើយ លោក **អ៊ូ ផាន់** ក៏តាមពិតហ្នឹង វាអញ្ចេះទេ សូមជ្រាបថា ពាក្យនេះចង់ហៅជាបាលីក៏បាន ជាសំស្ក្រឹតក៏បាន។ ឥឡូវយើងត្រូវ ថា សំស្ក្រឹតមុនចុះកុំអាលនិយាយពីសារៈ និយាយតែពី "ព័ត៌មាន"។ សំស្ក្រឹតហៅថា "វត៌មាន" "វត៌" គឺអក្សរ "វ" ហើយ "ត" នៅពីរជាប់ "វ" បាន "រ" នៅពីលើ "ត" ដែលយើងហៅជើង "រ" នេះថា "របាទ"។ សំស្ក្រឹតគេហៅថា "រេផៈ" "រេផៈ" គឺ "រ" ដែលសំរាប់ឆក់សំឡេង គឺនៅពីលើតួបន្ទាប់ នេះហ្នឹង គេសរសេរ វ ត រពីលើ "ត" ហើយ "មា" និង "ន" អានថា "វ៉ារៈ-តៈ-ម៉ាន" បើបាលីវិញ អានថា "វាត់-តៈ-ម៉ាន"។ វ ត្ត តម្រួតពីរ"មា"និង"ន" គឺពាក្យដែលថា "វត៌មាន" នេះហើយដែលបុរាណខ្មែរយើងយក "វ" ធ្វើជា "ព" គេមិនអាច ទាញស្រះ "ា" យារមកទៀតទេ គឺនៅជា "ព" អញ្ចឹង "វ" និង "ព" វាមកពី "វ"។ គេថា ពត៌ ពរ-តៈ សំស្ក្រឹតគេថា វ៉ារៈ-តៈ រួច មាន (ម៉ា-នៈ) "មាន" នោះជាតួ Suffixe តួបច្ច័យ គឺមានបច្ច័យ នឹង "វត៌" ទៅជា "វត៌មាន"។ ខ្មែរយើងយក "វ" ជា "ព" យកមកប្រើថា "ព័ត៌មាន"។ ពត៌មានជាពាក្យសំរួលតាមបាស់ទុំមកដូចជា : "បិតា" (ប៉ិ-តា) ទៅ ជា (បី-ដា) មាតា អក្សរ "ត"

គេអានថា "ដា" ដូចជា អធិបតិ (អៈ-ធិ-ប៉ៈ-តិ) ទៅ ជា (អៈ-ធិ-ប៉ៈ-ដី) សេនាបតិ ទៅជា"សេនា-បៈ-ដី" ព្រោះសំដីនឹង ខ្មែរយើងពេញចិត្តនឹង "ត" ទៅជា "ដ" ព្រោះហេតុហ្នឹងឯង ទាំងបាលីក៏ដោយ គេឲ្យផ្លាស់អក្សរពីរហ្នឹងបាន គេហៅយក "ទន្តជៈ" និង "មុទ្ធជៈ" ឬ "ទន្តជៈ" និង "មុទ្ធជៈ"។ ឯ "ទន្តជៈ" នោះគឺអក្សរ "ត" ចុះ "មុទ្ធជៈ" នោះគឺអក្សរ "ដ" ព្រោះហេតុនេះឯង យើងចង់ ផ្លាស់ "ដ" ទៅ ជា "ត" ក៏បាន ផ្លាស់ "ដ" ទៅជា "ត" ក៏បាន តាមការស្រួល។ បើនិយាយពីបាលីវិញ ឧបមាថា "ទុក្កតំ" ទុក្កតំ ប្រែទៅថា អ្វីដែលគេពិបាកធ្វើ ដែលធ្វើបាន ដោយក្រ ដោយពិបាក អាហ្នឹងគេថា "ទុក្កតំ កម្មំ" ការហ្នឹងវាពិបាកធ្វើណាស់ ប៉ុន្តែគេចង់ឲ្យសំឡេង នោះវាខុសគ្នា មិនដឹងជាពីកាលណាមកហ្នឹងទេ គេឲ្យយក "ត" ជា "ដ" ទៅជា "ទុក-កៈ-ដាំង" ដល់អានវាឮតាំងៗដូចគ្នា ប៉ុន្តែតាំងមួយសំឡេងចេញពីគល់ប្រទល់ធ្មេញ គឺ "ត ថ ទ ធ ន" នោះ តាំងមួយអក្សរ "ដ" នោះ យើងខ្មែរអានថា "ដ" ជាតិ ដទៃអានថា "ត" ដែរ ប៉ុន្តែហ្នឹងសំឡេងថា "តៈ" ហើយបើបាលីគេថា "តៈ" ចុះជាមួយ "ត" "ថ" នោះគេអានថា "ទៈ" អាត្មាវាចាស់ អស់ធ្មេញ គ្រាន់តែពន្យល់ឲ្យយល់ ឲ្យចេញពីធ្មេញ ឮពីធ្មេញ "ទៈ" មួយថា "ត" ហ្នឹង ខ្មែរមិន សូវរួចទេ ព្រោះហេតុនោះ បានជាគេរាប់ ទៅថា ជា "ដ"។ ឯតាមពិតសំឡេងនោះវាជិតគ្នាទេ ប៉ុន្តែខ្មែរយើងវាទៅជា "ដ" ទៅជា "ព័រ-ដ-មាន" ដល់ឥឡូវគេបង្កើតពាក្យ ឈ្មោះ កាសែតគេហៅ "សារៈ-ព័រ-ដ-មាន" បានជា ពត៌មានហ្នឹង។ លោក... ប្រែថាម៉េចព័ត៌មានហ្នឹង វត៌មានហ្នឹងប្រែថាអ្វីដែល កំពុងតែ បើប្រែឲ្យច្បាស់មកថា "បច្ចុប្បន្ន" បើនិយាយពីរឿង ថារឿងបច្ចុប្បន្ន។ រឿងអ្វី ដែលកំពុង តែឥឡូវនោះ អាហ្នឹងហៅថាវត៌មាន គឺវត៌មានហ្នឹង ដំណឹងដែលថ្មីៗហ្នឹង ដំណឹង ដែលទើបនឹងកើតមានហ្នឹង ហៅថា"ព័ត៌មាន"។ ប្រហែលជាលោក **ផាន់**យល់ ហើយក៏ មិនដឹង។ អាត្មាប្រែម្តងទៀតថា វត៌ម៉ាន សំស្ក្រឹត បាលី វត្តម៉ាន បើតាមហ្នឹង ដែលក្លាយ មកជា ពត៌មាននេះគួរអាន "ព័រ-តៈ-ម៉ាន" ត្បិត "ត" វានៅពីលើ "ម" ជិតគ្នា "ម" ជាអក្សរចុះក្នុងវង់សម្លាប់។ នេះនិយាយ តាមខ្មែរទៅ "ម-ា" ហ្នឹងទៅជា "មា" "មា" ទៅជា "ម៉ា"។ ហេតុអ្វីបានទៅជា "ម៉ា" ពីព្រោះ "ត" វានៅពីលើ វាភ្ជាប់ទៅជារូប ស័ព្ទមួយ ហើយគេអានថា "វាត់-តៈ-ម៉ាន" "ព័រ-តៈ-ម៉ាន"។ ប៉ុន្តែឥឡូវ យើងថាមិនកើត ពីព្រោះចាស់ទុំយើងហៅ "ព័រ-ដ-មាន"ទៅហើយ។ យើងនិយាយថា "ព័រ-ដ-ម៉ាន" វាប្លែក ត្រចៀកវិញតែមិនរួចទេ។ នេះហើយដែលអាត្មា តាមជំរាបមកថា ពាក្យណាមួយ សម្តីដែលយើងនិយាយទៅ វាជ្រុលហួសហើយ វាខុសហើយហ្នឹង ជាយូរឆ្នាំទៅ យើងកែវិញមិនបានទេ។ ដូចជាពាក្យ"បដិញ្ញាណ" បត្តិញ្ញាណ មេឃុំលក់គោ លក់ក្របី

រហូតមក "បត្តិញ្ញាណ" អនុញ្ញាតឲ្យកុលបុត្របួសក្នុងសាសនា ក៏ហៅថា"បត្តិញ្ញាណ" មេឃុំដែរ។ បើនិយាយតាមពាក្យហ្នឹង វាមិនមែន"ចាត់-តៈ ញាណ"។ បើសម្ដីខ្មែរ គេអាន "ចាត់-តិៈ-ញ៉ាណ" ពីព្រោះអក្សរ "តិ" វានៅពីលើអក្សរ "ដិ" វានៅពីលើ ត-ម - ត្ត ត្ត-ា ត្តា ដូចជាវិត្តមាន អញ្ចឹង គឺ "ត" និង "ម" - ត្ត ត្ត-ា ត្តា វាមិនមែន ត្ត-ា ទៅ ត-មា ទេ។ ដល់ឥឡូវបុរាណគេថា"ព័រ-ដ-មាន"ទៅហើយ បើឯងទៅអាន"ព័រ-ដ-ម៉ាន" វិញមានតែគេថា យើងព្រើល ដែលនិយាយហ្នឹងដោយ លោក ឌុំ ផវន់ សួរហ្នឹងគ្រាន់ពន្យល់ទេ មិនមែន ឲ្យថា "ព័រ-ដ-ម៉ាន" ទេតិចលោ ទៅថាអញ្ចឹងចុះ។ បើបាលី គេរៀនសព្វថ្ងៃហ្នឹង គេអាន "វាត់-តៈ-ម៉ាន" វត៌មាននេះ ជាឈ្មោះវិភត្តិអាខ្យាត។ ចំណែកការបំបែក កិរិយាស័ព្ទ ដែលបារាំងហៅថា Verbe ជាពួកជាឈ្មោះ Mode របស់ Verbe នោះផង គឺបច្ចុប្បន្ន Verbe ណាបច្ចុប្បន្ន ដូចជា ខ្ញុំទៅ ខ្ញុំធ្វើ ខ្ញុំឲ្យ អាហ្នឹងគឺបច្ចុប្បន្ន គេហៅថាវត្តមាន គឺដូចជាព័ត៌មានអញ្ចឹង។ ឥឡូវខ្ញុំធ្វើ ខ្ញុំឲ្យ អាហ្នឹងគឺ បច្ចុប្បន្នគេហៅវត្តមានគឺដូចជា ព័ត៌មាន។ ចុះហេតុអីក៏យកសារៈមកធ្វើអី គឺលោកអ្នក បង្កើតពាក្យលោកថាព័ត៌មាន ដែលមានខ្លឹមសារ មានប្រយោជន៍ Intéressant បារាំងគេថា Intéressant ពាំដំណឹងអ្វីមួយ ដែលគួរយកមកថ្លែង យកមកឲ្យអស់លោកអ្នកទាំងអស់ ឬរាល់គ្នាហ្នឹង បានជាបង្កើតបញ្ចូលពាក្យសារៈនេះមួយ ប៉ុន្តែមកដល់អ្នកអាន អាន"សា-ព័ត៌មាន"ហ្នឹង អានមិនកើតទេ អានហ្នឹងខូច ខូចសំដីមួយហើយនេះនោះ។ អាត្មា បានសរសេរមកពន្យល់លោកតាងហាងវិទ្យុ ជាច្រើនដងណាស់ ប៉ុន្តែអ្នកអាននេះឯង គេមិនសូវយកចិត្តទុកដាក់ ខ្លះថា "សារៈ-ព័រ-ដ-មាន" ខ្លះថាសារព័ត៌មាន ទៅថា "សា-ព័រ-ដ-មាន" វាបាត់ "រ" ទៅ។ វាទៅជាព័ត៌មានដែលសើរើជាថ្មីទៀតវិញ ពីព្រោះវាសាចុះសាឡើង ថាយើងដែលនិយាយសាឡើងជាថ្មីទៅមួយសា ពីរសា។ សាហ្នឹង វាគ្មាន "រ" ទេ សាស្រូវ សាអីហ្នឹង ដែលរើវាឡើងទៀតហ្នឹង គេហៅថាសាវា គេច្រូតអីអញ្ចឹង វានៅតែកញ្ច្រាំងមាននៅទឹកមានដីសើមកញ្ច្រាំងហ្នឹងវានៅស្រស់ វាដុះពីកញ្ច្រាំងហ្នឹង ឡើងទៀត ក៏ដុះភ្ញាមចេញនិនទៅទុំភ្ញាមមិនយូរទេ។ អាហ្នឹងគ្រាប់ល្អិត។ ស្រូវនឹង បាយឆ្ងាញ់ណាស់ ប៉ុន្តែពិបាកណាស់ អាហ្នឹងគេហៅស្រូវសា គេហៅសាស្រូវក៏បាន។ គេសួរថាហើយ ចុះអង្ករហ្នឹងក៏ល្អិតឆ្អិញអញ្ចឹង ថាទេអង្ករសាស្រូវសាទេ។ តាឡេងគ្រាប់ ស្រូវហ្នឹងល្អណាស់ អាហ្នឹងគេហៅថាសា ហ្នឹងគឺអត់ "រ" ទេ បើយើងអាន"សា-ព័រ-ដ-មាន"ដូចជាអញ្ចឹងដែរ គឺព័ត៌មានហ្នឹង គេរើសើឡើងជាថ្មី វាមិនមែនជាពត៌មាន មានខ្លឹម មានប្រយោជន៍នោះទេ ដូច្នេះហើយ បានជាអាត្មា ចេះតែរំលឹកថា កុំឲ្យអានខុសអញ្ចឹង។ រួចចេះតែកញ្ឆក់ប្រញាប់ ចុះប្រញាប់ទៅណាគ្រាន់តែ "រៈ" ឮតែបន្តិចចុងមាត់ប៉ុណ្ណឹង សារៈ-ព័ត៌-មាន សារៈ-ព័ត៌-មាន កុំថា "សា...រៈ-ព័ត៌-មាន"

នោះវាវែងណាស់ កុំឲ្យតែ“សា-ព័ត៌-មាន”។ សារព័ត៌មាន សារទូរលេខ សារទូស័ព្ទ សារៈប្រយោជន៍ វាឥឡូវ សា-ប្រយោជន៍ សា-ទូ-លេខ សា-ទូ-ស័ព្ទ។ ទូរៈ-លេខៈ មកពី“ទូរៈ” ប្រែថាពីចម្ងាយ “លេខៈ”ថាសរសេរ។ ការនោះគឺប្រែឲ្យត្រូវនឹងពាក្យថា Télégramme សរសេរមកពីចម្ងាយ Téléphone និយាយ ឬឱ្យបមកពីចម្ងាយ។ រួចចុះបើថា ទូ-លេខ ទូ-ស័ព្ទ តើវាមិនទៅ ជាទូដាក់លេខ ទូដាក់ស្នាបព្រាទៅហើយ វាខុសគ្នា អញ្ចឹងបានជាតោងកុំចោល កុំអាហ្នឹង ទៅប្រញឹក ទៅណា។ អក្សរគេមាន ដូចជានិយាយទៅ វាបែកទៅណាទៀត អាត្មាចំណាំ តែទូលថា ព្រះរាជនិង្ការ នូវព្រះបន្ទូល សូរសីហនាទ ព្រះបាទសម្ដេច អង្គអី... អង្គអី...គេចេញព្រះនាមទៅមិនថា សូរៈ-សីហនាទទេ សូ-សីហនាទ។ សូរៈប្រែថាក្លៀវក្លា គេមិនមែន មិនថាអង់អាចក្លៀវក្លាទេ សីហៈ-នាទៈ ថាបន្លឺ បន្ទរឡើងដូចសម្រែករាជសីហ៍។ គឺគេយកព្រះរាជតេជៈ អំណាចរបស់ករុណានោះ ទុកថាមាន តេជៈនោះ ក្តេងក្តាងខ្ទរខ្ទារអីទៅ វាដូចជាសម្រែកសត្វសីហៈ ដូចសម្រែក Lion។ រួចចុះបើ អានថា សា សូរ អាហ្នឹងក៏ដាក់ “រ”ពីមុខ ស្នូរហ្នឹងក៏ “រ” ពីមុខ ស្នូរ-សីហនាទ ហើយវាទៅជាព្ធមកពីស្នូរ។ បើអានសូរ-សីហនាទ ហើយវាទៅជាព្ធសម្លេងសីហនាទទៅវិញ រួចហើយអ្នកអានហ្នឹងមិនដឹងជាខុសទេ ទុកជាគេនិយាយប្រាប់ថាខុស ក៏ចចេសមុខរឹងនៅហ្នឹង មកអំពីប្រកាន់មានះ។ រួចមានះហ្នឹង ដូចជាអាត្មាជំរាបមុនៗ។ អស់លោកក៏បានយកទៅ រាយរ៉ាប់ក្នុងសៀវភៅទស្សនាវដ្ដី ហើយអាត្មាសុំនិយាយ ពីមានះបន្តិចទៅចុះ ទោះកើតមិនកើត បើច្បាប់យើង សាសនាយើង គេនិយាយអញ្ចឹង។ មានះបាលីគេហៅ មា-នៈ គេប្រើ មានះតាមសំស្ក្រឹត។ សំស្ក្រឹត គេអានថា ម៉ា-ណាសៈ អក្សរ “ស” វានៅពីមុខ រួច “ស” ហ្នឹងឯង។ បើចង់ផ្លាស់ទៅជាវិសជ្ជនីយទៅជារះមុខនេះ គេដាក់ “ហ” ពីមុខ បើគេសរសេរ ជាភាសាបារាំង គេដាក់ “ហ” ពីមុខ ដូចជាព្រះ ដូចជាតេជះ អញ្ចឹងព្រះគេសរសេរ Preah គេមិនដាក់ s ទេ គេអានថាព្រះ កុំឲ្យអាន...ទុកដូចជារះមុខ អក្សរ “ហ” នោះឯង ពីព្រោះ សំស្ក្រឹតគេប្រើអញ្ចឹង។ សូមជ្រាបថា ទៅដល់ សារៈ-ព័ត៌-មាន សូមចាំអញ្ចឹងចុះ គឺដំណឹង សេចក្ដីអ្វីដែលមានប្រយោជន៍ គួរចង់ដឹង គួរចង់ស្ដាប់ គេហៅ សារព័ត៌មាន។ កុំច្រលំនឹងពាក្យព័ត៌មាននេះ ព័ត៌មានហ្នឹងគេប្រែ ថាហេតុ ថាសេចក្ដី ថាដំណើរ ថារឿងដែលកំពុងតែមាន កំពុងតែប្រព្រឹត្តទៅ។ វត៌ម៉ាណៈ ថាកំពុង តែប្រព្រឹត្តទៅ ដែលលោកយោគយល់ថាយក ណ មកដាក់ថា ពណ៌ដ៏មាននោះ វាទៅជា សម្បុរទៅវិញ មិនមែនទេ យល់ហ្នឹងខុសទេ ហើយលោកថាសារប្រវត្តិ ក៏បានមិនអីទេ។ សារៈ-ប្រវ៉ាត់-តិ ក៏ប្រែថាដំណឹងដែរ សំស្ក្រឹតហៅ ប្រៈ-វ្ឫ ត្តិ ប្រវត្តិ។ យើងយក វ ជា ព ទៅជា ប្រព្រឹត្តិ “ប្រ-ព្រឹត្ត” ដែលយើងថា ប្រ-ព្រឹត្ត សព្វថ្ងៃនេះ។ បើនាមស័ព្ទ គេសរសេរ ប្រព្រឹត្តិ

សេចក្ដីប្រព្រឹត្តិ ចុះបើកិរិយាស័ព្ទ គេហៅអព្ភន្តរកិរិយា គេសរសេរប្រព្រឹត្ត ប្រវត្តិ បាលីថា ប្រវត្តិ សំស្ក្រឹតថា "ប្រ:-វ្រ-ត្តិ"។ ឥឡូវបើលោកចង់ អោយថា សារៈ-ប្រវ៉ាត់ ក៏ត្រូវដែរ។ ប៉ុន្តែគេមិន បានប្រើទៅហើយ បើយើងបង្កើតទៀតនាំឲ្យទៅជាមួយ ពីរ សូមជ្រាបប៉ុណ្ណឹង។

**សំនួរទី២** លោកនេះសួរនឹងមានប្រយោជន៍ដែរ ព្រោះលោកចេះឆ្ងល់ សមរម្យគួរដោះស្រាយ។ លោកសួរ ថាពាក្យ បៀវត្ស ឬ បៀវត្សរ៍ ប៉ុន្តែអាន "បៀ-វ៉ាត់" ដូចគ្នា រ បដិសេធចេញ ពាក្យនេះមានន័យ ប្រាកដ...មានន័យថាប្រាក់រង្វាន់ឆ្នាំ យល់ហ្នឹងត្រូវហើយ។ បុគ្គលិកណា ដែលធ្វើការជូនរាជការ ឬឯកជន ក្នុងមួយឆ្នាំៗ គេបើកប្រាក់ឲ្យម្ដង ប្រាក់នេះគេហៅថា ប្រាក់បៀវត្សរ៍។ ចុះបើបុគ្គលិកនោះធ្វើការជូនរាជការ ឬឯកជនក្នុងមួយខែក្នុងមួយខែៗ គេបើក ប្រាក់ឲ្យម្ដង ប្រាក់នេះ តើគេតែងនាំគ្នាហៅប្រាក់នេះថា ប្រាក់បៀវត្សរ៍ដែរ តើគេហៅនេះ ខុស ឬត្រូវ បើសិនជាខុស បើសិនជាអត់កើតឬទេ។ ប្រសិនបើខុស លោក **ផាន់** យល់អញ្ចឹង គេមិនដែលនិយាយ "បើសិនជា"ទេ បើសិនជា ទើបឥឡូវទេ គេថាប្រសិនបើខុស ដាក់ជា មកវាទៅជាវិកតិកត្តា ដូចអាត្មាបាននិយាយពីថ្ងៃមុន។ ប្រសិនបើជាប្រាក់ប៉ុណ្ណោះ តើអ្នកយក ឬទេ? ឥឡូវខ្ញុំជំពាក់អ្នកមួយរយរៀល ខ្ញុំសូមជូនតុមួយ កៅអីមួយដំប សុទ្ធតែឈើបេង តើបងឯងយកដែរឬទេ? ប្រសិនបើជារបស់ហ្នឹង អានេះបានវាត្រូវ "បើសិនជា" នេះគឺ អាត្មាមិនចេះទេ។ លោកត្រូវលែងឈប់ប្រើទៅហ្អី ប្រើប្រសិនបើ ប្រសិនបើ ខុសតើគួរ ហៅយ៉ាងណាទៅវិញ។ ត្រង់ហ្នឹងលោកយល់ ដូចជាត្រូវហើយ ប៉ុន្តែយើងនឹងលុបលាង ក៏វាមិនមានប្រយោជន៍អីទេ។ អាត្មាសូមពន្យល់ត្រង់នោះ មានក្នុងវចនានុក្រម ហើយដែល អាត្មាចាំ បៀ កាលណោះយើងចាយបៀ សម័យ ចាយបៀ គឺយកបៀពីក្នុងសមុទ្រហ្នឹង មកមិនដឹងជា មានប្រាង្គ មានចម្លាក់ដូចម៉េចទេ យកមកចាយជំនួសប្រាក់ ពីព្រោះបុរាណ ពីដើមក្នុងគម្ពីរខាងសាសនា ក៏មានគេហៅកហាបណៈ។ សំស្ក្រឹតគេហៅ កាឞ្ជ-បណ។ ដូចយើងហៅ ប្រាក់កហាបណៈ ដូចយើងហៅ រៀល យើងហៅរូបពី យើងហៅ បាប់ ភូមា អីចឹងយើងហៅ Piastre អីចឹង។ ប៉ុន្តែហៅកហាបណៈ កហាបណៈហ្នឹង មានឈ្មោះច្រើន យ៉ាងណាស់ មានកហាបណៈដែរ មានកហាបណៈស្ពាន់ មានកហាបណៈតួសាច់ប្រាក់ មានកហាបណៈតួសាច់មាស ដូចជាគេប្រើ ហ្វ្រង់ មានហ្វ្រង់មាស ហ្វ្រង់ប្រាក់ ដូចឥឡូវមាន Nouveau Franc, Ancien Franc។ អាហ្នឹង គឺបៀហ្នឹង គេយកមកចាយ ជំនួសប្រាក់ ជនចាយ បៀនេះ អាត្មាមិនចាំទេ មិនដឹងក្នុងរជ្ជកាលរាជ្យព្រះអង្គណាទេ ក្នុងប្រទេសយើង ក៏អស់លោក ពីដើម អ្នកហ៊ីនអ្នកសែនគ្មានប្រាក់ខែ គឺមួយឆ្នាំ ត្រូវបានរង្វាន់ម្ដង ដូចអាជ្ញាហ្លួង ដូចមេកង បើស្ម័គ្រ អាជ្ញាហ្លួង មេកង ទារពន្ធស្រូវ អាជ្ញាហ្លួងមេកងពន្ធ ទារកត់ដំណាំ

យកពន្ធពីរាស្ត្រនេះ គឺមួយឆ្នាំត្រូវបានម្តង ប៉ុន្តែហ្នឹងមិនយក មិននិយាយទេ និយាយតែពីអ្នកដែលត្រូវទទួលរង្វាន់មួយឆ្នាំបើកម្តង បានជាអ្នក បុរាណហៅ បៀវត្សរ៍ វត្ស (វ័ត-សៈ) ឬ វត្សរ៍ (វ័ត-សៈ-រៈ) ហ្នឹងប្រែថាឆ្នាំ ពីសំស្រ្កឹត ក្លាយមកខ្លះបាលីហៅសំវច្ឆរៈ សំស្ក្រឹត ហៅ វត្សរ (វ័ត-សៈ-រៈ) ឬ (វ័ត-សៈ) វត្ស ដូចពាក្យថា វស្សាអញ្ចឹងគឺឆ្នាំ។ ប្រាក់ហ្នឹងមួយឆ្នាំត្រូវបានម្តង ទើបហៅបៀវត្សរ៍ រួចយ៉ាងម៉េច បានហៅបៀ ព្រោះបៀមែន មិនមែនអីហ្នឹង។ ចុះឥឡូវវាបាយបៀ ពាក្យហ្នឹងក៏ជាប់មក យកប្រាក់យកកាក់ហ្នឹងជាជំនួសបៀ ពាក្យហ្នឹងក៏នៅជាបៀអញ្ចឹង។ ចុះឥឡូវប្រាក់ខែ ប្រាក់ថ្ងៃ ប្រាក់ខែ។ បើយើងហៅ ថាមាសិក ប៉ុន្តែមិនបង្កើតទេពាក្យហ្នឹង បានប្រយោជន៍ យ៉ាងម៉េច ថាគេមានមាសិក ចាំថាមាសិកអី បើប្រាក់ខែងាយថាសឹងងាប់។ ចុះបើប្រាក់ថ្ងៃ គេហៅ ទិនិក។ ទិនិកគឺជាប្រាក់ដែលបាន រាល់ថ្ងៃ បានថាពាក្យនេះគេប្រើ ឥឡូវហ្នឹង អ្នកទិនិកគឺមនុស្ស Journalier គេហៅ ទិនិក មកពីពាក្យទិន (ទិ - នៈ) ប្រែថាថ្ងៃ ឥកៈ តួបច្ច័យ Suffixe ចុះមក ទៅជាទិនិក។ តែបើឲ្យត្រូវគេថា(ទី-និក) តែ ិ ក នោះវានៅចុង ពាក្យវា ិ ពាក្យណា ខ្វីឲ្យទៅជាវែង។ បើថាឲ្យស្រួល គេហៅ (ទិ-និក)។ ហើយបើ មាស(មា-សៈ) នេះវាខែ ហើយ"មាស"នោះវាអក្សរវែងស្រាប់ មិនបាំបាច់ធ្វើអ្វីវាទៀតទេ ថាមាសិក បើស្រីគេថាមាសិកា។ អ្នកស៊ីប្រាក់ខែ រួចបើស៊ីប្រាក់ថ្ងៃ បើប្រុសថាទិនិក បើស្រីគេថា ទិនិកា។ យើងថាទៅជា អញ្ចឹងវានាំឲ្យពិបាកនេះគឺ បើនិយាយតាមហ្នឹងទៅវាអញ្ចឹង។ បើថាប្រាក់ឆ្នាំហ្នឹង ចាំថា អី...ស្អីទៅកុំថាបៀទៀតអាហ្នឹងវាទៅ វស្សិក វស្សិកា ឲ្យវាចំ ឬបើថានៅតែបៀវត្សរ៍ដដែលក៏ថាចុះសុំឲ្យតែលោកជ្រាបអញ្ចឹង លោកយល់។ បៀវត្សរ៍ មកពីដើម យើងបាយបៀមួយឆ្នាំគេបានប្រយោជន៍ រង្វាន់ហ្នឹងម្តងហ្នឹងយល់ហើយ!។ ប៉ុន្តែឥឡូវយើងស្រេចតែប្រើទៅចុះ ដែលលោកយល់ថា ប្រាក់រង្វាន់ឆ្នាំហ្នឹងត្រូវហើយ ប៉ុន្តែតាមពិតគេប្រើបៀរង្វាន់ឆ្នាំ ពីព្រោះកាលណោះអត់ប្រាក់ទេ គេបាយបៀក៏បាន បាយកាកល័ក្តក៏បាន។ គេយកកាកល័ក្តនោះ ធ្វើបោះត្រាផែនដី ជាសំគាល់ទៅ។ គេបាយជំនួសប្រាក់ទៅ វាដូចជា ប្រទេសកម្ពុជាយើងកាលសម័យអាណានិគម គេបោះប្រាក់កាក់ហ្នឹងតូចៗ ហ្នឹងគេថ្វូររាល់គ្នា ដែលឆាប់ខូចបំផុត។ ពួកលក់សាច់ជ្រូក យូរៗសើមគគុល។ អ្នកខ្លះ ចេះតែនិយាយ តាមអាត្មាចាំ ចាស់ៗនិយាយថាអី! អនេកពាន់ជាតិ ជាតិណាៗក៏កុំឲ្យជួប សិតអន់ឡិតនេះ។ ចុះអ្នកលក់សាច់ជ្រូកក្អែលដៃមិនដឹងប៉ុន្មានទៅ វាកខ្វក់ វារលួយអស់ទៅ រួចអាហ្នឹងស្រេចតែគេសន្មតទេ រឿងការបាយវាយ រឿងការបាយវាយ ដូចជាធនប័ត្រ សព្វដែលគេហៅធនប័ត្រ គឺជាក្រដាសប្រាក់គឺយកក្រដាសមកធ្វើប្រាក់បានដែរ ចប់ហើយ ១ទី២។

## គោលបំណងសិក្សាអត្ថបទនានាអក្សរសាស្ត្រ

ការសិក្សាអត្ថបទសម្អាសអក្សរសាស្ត្រ របស់សម្តេចសង្ឃរាជ ជួន ណាត គឺដើម្បីដកស្រង់យកនិយាមទាំងឡាយក្នុងការប្រើប្រាស់ភាសាខ្មែរ។ និយាមក្នុងការប្រើប្រាស់ភាសា នឹងបានជាជំនួយដល់ការរៀបចំក្បួនខ្នាតសំរាប់ចងក្រងវេយ្យាករណ៍ខ្មែរក្នុងពេលខាងមុខនេះ។

### ក្បួនប្រើព្យញ្ជនៈ ត និង ដ

រឿងប្រើប្រាស់ព្យញ្ជនៈ "ត" និង "ដ" នេះ សម្តេចសង្ឃរាជព្រះអង្គពន្យល់ថា :

*ពត៌មានជាពាក្យ សំរួលតាមចាស់ទុំមកដូចជា : "បិតា" (បុ-តា) ទៅ ជា (បី-ដា) មាតា អក្សរ "ត" គេអានថា "ដា" ដូចជា អធិបតិ (អៈ-ធិ-ប៉ៈ-តិ) ទៅ ជា (អៈ-ធិ-ប៉ៈ-ឌី) ព្រោះសំដីនឹង ខ្មែរយើងពេញចិត្តនឹង "ត" ទៅជា "ដ" ព្រោះហេតុហ្នឹងឯងទាំងបាលីក៏ដោយ គេឲ្យផ្លាស់អក្សរពីរហ្នឹងបាន គេហៅយក "ទន្តជៈ" និង "មុទ្ធជៈ" ឬ "ទន្តជៈ" និង "មុទ្ធជៈ" (សម្អាសន៍អក្សរសាស្ត្រ ទំ. ១)។*

ការផ្លាស់ប្តូរ ព្យញ្ជនៈ "ត" ជា "ដ" គឺសំអាងលើក្បួនភាសាវិទ្យាផ្នែកវិធីសាស្ត្របន្ទឺស្វរស័ទ្ទ (articulatory phonetics)។ ក្បួននេះ ភាសាវិទូឥណ្ឌា បានប្រើប្រាស់យ៉ាងហោចតាំងពីសម័យពុទ្ធកាលមកម្ល៉េះដោយគ្មានប្រើមន្ទីរពិសោធទេ។ ខ្មែរយើងតែងស្គាល់ភាសាវិទូឥណ្ឌា ឈ្មោះកច្ចាយនៈ ចំណែកឯបស្ចិមប្រទេស គេច្រើនស្គាល់ឈ្មោះ ភាសាវិទូប៉ានិនិ (Panini)។ វិធីសាស្ត្រផ្នែកនេះ ទើបតែនឹងត្រូវបានភាសាវិទូបស្ចិមប្រទេសអនុវត្តនៅសតវត្សរ៍មុននេះ

### ក្បួនប្រើប្រាស់និបាតស័ព្ទ "ប្រសិនបើ ប្រសិនបើជា"

សម្តេចសង្ឃរាជព្រះអង្គបានពន្យល់ថា ការនិយាយថា "បើសិនជា" មិនត្រឹមត្រូវទេ។ ព្រះអង្គស្នើអោយប្រើ "ប្រសិនបើជា" ដូចមានពន្យល់តទៅនេះ :

*ប្រសិនបើខុស លោក **ផាន់** យល់អញ្ចឹង គេមិនដែលនិយាយ បើសិនជាទេ បើសិនជាទើបឥឡូវទេ គេថាប្រសិនបើខុស ដាក់ ជា មកវាទៅ វិកតិកត្តា ដូចអាត្មាបាននិយាយពីថ្ងៃមុន ប្រសិនបើជា ប្រាក់ប៉ុណ្ណោះ តើអ្នកយកឬទេ? ឥឡូវខ្ញុំជំពាក់អ្នកមួយរយរៀល ខ្ញុំសូមជូនតុមួយ កៅអីមួយដំប សុទ្ធតែ ឈើបេង តើបងឯងយកដែរឬទេ? ប្រសិនបើជារបស់ហ្នឹង អានេះបានវាត្រូវ បើសិនជានេះគឺ អាត្មាមិនចេះទេ (សម្អាសន៍អក្សរសាស្ត្រ ទំ. ៥)។*

"ប្រសិនបើជា"និង"បើសិនជា"សម្តេចសង្ឃ ព្រះអង្គពន្យល់ថា ពីដើមគេប្រើ "ប្រសិនបើជា" ហើយទើបតែឥឡូវនេះទេ ដែលគេនិយាយថា "បើសិនជា"។ "ប្រសិនបើជា" គឺជាទម្លាប់

ចាស់ដែលធ្លាប់មានមកហើយ។ ការស្រង់យកនិយាម នៃការប្រើប្រាស់ "ប្រសិនបើ" "ប្រសិនបើជា" ដោយទម្លាក់ចោល "បើសិន" "បើសិនជា" គឺសំអាងទៅលើទម្លាប់ដែលធ្លាប់មានរួចមកហើយ។ ភារៈកិច្ចរបស់អ្នកសរសេរវេយ្យាករណ៍ខ្មែរក្នុងសម័យនេះគប្បីស្រាវជ្រាវរកធម៌ភាពនិងក្បួនភាសាវិទ្យាផ្នែកសម្ព័ន្ធ ផ្នែកន័យរបស់ចង្កោមពាក្យ ក្នុងការប្រើប្រាស់ផង ដើម្បីគាំទ្រគំនិតយោបល់ណាមួយនោះ។ ដើម្បីយល់អោយបានច្បាស់ទៀត សូមអានសេចក្តីពន្យល់ល្អិតល្អន់ អំពីការប្រើប្រាស់និបាតស័ព្ទ "ប្រសិនជា" ប្រសិនបើជា" "ប្រសិនណាបើ" "ប្រសិនបើ" ក្នុងវចនានុក្រមខ្មែរ បោះពុម្ពឆ្នាំ១៩៦៧ ទំ. ៦៦៩-៦៧០។

ក្បួនទំនាញសួរ

ពាក្យថាទំនាញសួរនេះ គឺជាពាក្យបង្កើតថ្មី ឯន័យសេចក្តី គឺពុំទាន់បានជ្រួតជ្រាប និងបានការទទួលយល់ព្រមជាទូទៅទេ ក្នុងមជ្ឈដ្ឋានអ្នកប្រើប្រាស់ភាសាខ្មែរ ពីព្រោះពាក្យនេះកើតមុនសង្គ្រាម។ នៅពេលក្រោយសង្គ្រាម គឺជាសម័យលង្វែកអក្សរសាស្ត្រ ពីព្រោះអ្នកចេះដឹងនិងអ្នកធ្លាប់ប្រើប្រាស់ភាគច្រើន ត្រូវស្លាប់ក្នុងសង្គ្រាមទៅហើយ។ ក្នុងពេលមុន ភាសាវិទូខ្មែរបានប្រើប្រាស់ពាក្យថា "សម្ងាប់បំបែរសំឡេង" (នួន, ១៩៥៤, ទំ រ)។ វចនានុក្រមក្នុងការពន្យល់ពាក្យ "មូសិកទន្ត" បានប្រើពាក្យថា "ប្រើសម្ងាប់បំបែរសំឡេងព្យញ្ជនៈ ៩តួ...និងប្រើដាក់ពីលើស្រៈ ិ ឲ្យជា ី" (វចនានុក្រមខ្មែរ, ១៩៦៧, ទំ. ៩០៣)។ សេចក្តីពន្យល់ចុងក្រោយនេះ នាំអោយខ្ញុំនឹកភ្ញាក់ដល់សញ្ញាស្រៈ " ី "។ តើយើងអាចថា វាជាការផ្សំរវាង " ិ " និង និគ្គហិត " ំ " បានដែររឺទេ? ចុះសញ្ញាស្រៈ " ី " នេះជាការផ្សំរវាង " ិ " និងសញ្ញាបន្តក់ " ់ "បានដែររឺទេ? ត្រង់នេះយើងពិបាកឆ្លើយ ពីព្រោះសញ្ញាបន្តក់ " ់ " បើតាមក្បួនខ្មែរ គឺសំរាប់ប្រើ កាត់ស័ព្ទវែងអោយទៅជាខ្លី។ ចំណែកឯស្រៈ " ី " ជាសញ្ញាស្រៈផ្សំខ្លីក្នុងក្រុម "អ" ទៅវិញ។

បញ្ហាទំនាញសួរ រឺ សម្ងាប់បំបែរសំឡេងព្យញ្ជនៈនិងស្រៈនេះ វាជារឿងតែមួយ ដូចក្នុងពាក្យថា ខ្លា និង ឃ្មេ ក្នុងរឿងអាខ្វាក់អាខ្វិន។ ភាសាបារាំងនិងអង់គ្លេស ក៏មានដែររឿងទំនាញសួរកែប្រែសូរសំលេងព្យញ្ជនៈនោះ ដោយមានចែងក្នុងក្បួនវេយ្យាករណ៍ផង (assimilation in phonetics)។ ប៉ុន្តែវាមិនមានវិសាលភាពដូចក្នុងភាសាខ្មែរទេ ពីព្រោះគេប្រើអក្សរឡាតាំងកត់ត្រាសូរសំលេងភាសារបស់គេ។ ក្បួនទំនាញសួរ រឺ វិធីសាស្ត្រអនុវត្តរឿងទំនាញសួរនេះ មានអធិប្បាយជាច្រើនកន្លែង ដោយសម្តេចព្រះសង្ឃរាជ ក្នុងនាទីសម្ភាស អក្សរសាស្ត្រ។ ក្នុងទីនេះ ខ្ញុំលើកយកតែ ឧទាហរណ៍ មួយមកបង្ហាញ :

*អាត្មាប្រែម្តងទៀតថា វត៌ម៉ាន សំស្ក្រឹត បាលី វត្តម៉ាន បើតាមហ្នឹងដែលក្លាយមកជា ពត៌មាននេះត្រូវអាន "ព័រ-ត:-ម៉ាន" ត្បិត "ត" វានៅពីលើ "ម" ជិតគ្នា "ម" វាជាអក្សរចុះក្នុងវង់សម្រាប់។ នេះនិយាយតាមខ្មែរទៅ "ម-ា" ហ្នឹងទៅជា "មា" "មា" ទៅជា "ម៉ា"(សម្ភាសន៍អក្សរសាស្ត្រ ទំ. ២)។*

សម្តេចសង្ឃរាជ ព្រះអង្គបានបន្សល់ទុក នូវនិយាមជាច្រើន ដែលវេយ្យាករណ៍វិទូ អាចរៀន សូត្រនិងដកស្រង់ធ្វើជាក្បួនខ្នាតសំរាប់រៀបចំសៀវភៅវេយ្យាករណ៍ខ្មែរ តទៅទៀត។

ប្រមូលចងក្រងនិងសិក្សា

ផែល ថោង

## ឯកសារពិគ្រោះ


នួន, ប៊. (១៩៥៤) *វចនានុក្រមខ្មែរ* ភ្នំពេញ : ការផ្សាយរបស់បណ្ណាគារប៊ុត-នាង។

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ (១៩៦៧) *វចនានុក្រមខ្មែរ* ភ្នំពេញ : វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ។


កំណត់ចំណាំ :

១- វិទ្យាស្ថានភាសាជាតិ ព្យាយាមបោះពុម្ពផ្សាយអត្ថបទនិងការសិក្សា នាទីសម្ភាសអក្សរសាស្ត្រនេះ ម្តងបន្តិចៗ រហូតដល់ចប់ ដើម្បីរក្សាស្នាព្រះហស្តសម្តេចព្រះសង្ឃរាជ។

២- ខ្ញុំសុំខន្តីអភ័យទោសអំពីសំណាក់អ្នកអាន ចំពោះការខុសឆ្គងនិងខ្វះខាត ដែលអាចកើតឡើងដោយអចេតនាក្នុងកិច្ចការនេះ។

# កំណត់ហេតុប្រជុំ

# ស្តីអំពី

# មូលដ្ឋាននៃការអភិវឌ្ឍន៍ភាសាខ្មែរ

ឆ្នាំពីរពាន់ ខែសីហា ថ្ងៃទី ដប់ពីរ ម៉ោងប្រាំបីសាមសិបនាទី នៅរាជបណ្ឌិតសភាកម្ពុជា មានបើកកិច្ចប្រជុំ "វេទិកាអក្សរសាស្ត្រ" ក្រោមការដឹកនាំរបស់ឯកឧត្តមប្រធានរាជបណ្ឌិតសភាកម្ពុជា ។ ជាកិច្ចចាប់ផ្តើម ឯកឧត្តមប្រធានរាជបណ្ឌិតសភាកម្ពុជា បានបង្ហាញពីសមាសភាពគណៈអធិបតី :

១ ឯកឧត្តមបណ្ឌិត ស៊ន សំណាង ប្រធានរាជបណ្ឌិតសភាកម្ពុជា

២ បណ្ឌិត អ៊ីវ ច័ន អនុប្រធានវិទ្យាស្ថានភាសាជាតិ

៣ ឯកឧត្តម ឆាយ គីម (សមាជិក គ.ជ.ប)

៤ បណ្ឌិត ព្រុំ ម៉ល់ ទីប្រឹក្សាវិទ្យាស្ថានភាសាជាតិ

៥ បណ្ឌិត ធែល ថោង ទីប្រឹក្សាវិទ្យាស្ថានភាសាជាតិ

របៀបវារៈនៃកិច្ចប្រជុំមានដូចតទៅ :

១ ភាសាខ្មែរក្នុងប្រព័ន្ធអប់រំសិក្សាស្រាវជ្រាវ

២ ភាសាខ្មែរក្នុងប្រព័ន្ធផ្សព្វផ្សាយ : សារពត៌មាន វិទ្យុ ទូរទស្សន៍ និងការផ្សាយពាណិជ្ជកម្ម

៣ ចំណោទបញ្ហាទាក់ទងនឹងការអភិវឌ្ឍន៍ភាសាខ្មែរ

-អក្ខរាវិរុទ្ធនិងការអាន

-គំរោងរៀបចំវចនានុក្រម

បន្ទាប់ពីប្រកាសកម្មវិធី ឯកឧត្តមប្រធានបានមានប្រសាសន៍រំលឹកពីប្រវត្តិ កកើតនៃរាជបណ្ឌិត-សភាកម្ពុជា និង សមិទ្ធផលដែលសម្រេចបានក្នុងរយៈពេលដ៏ខ្លីកន្លងមក ។

ឯកឧត្តមប្រធានក៏បានលើកឡើង ពីការផ្តល់អាទិភាពដំបូងបំផុតដល់វិទ្យាស្ថានភាសាជាតិ ដើម្បីរៀបចំសន្និសីទជាតិស្តីពីភាសានេះ ហើយឆ្នាំបន្ទាប់១ទៀត រាជបណ្ឌិតសភាកម្ពុជា និងផ្តល់អាទិភាព ដល់វិទ្យាស្ថានបួនទៀតជាបន្តបន្ទាប់ ។

ឯកឧត្តម ក៏បានលើកឡើងពីបញ្ហាភាសា និងអក្សរសាស្ត្រជាតិ ដោយបានរំលឹកពីភាសា និង អក្សរ -សាស្ត្រពីអតីតកាលដ៏រុងរឿងរបស់យើង ដែលរីកចំរើន និងធ្វើឱ្យខ្មែរមានអត្តសញ្ញាណរបស់ខ្លួនរឹងមាំបំផុត ។

ឯកឧត្តមមានប្រសាសន៍ទៀតថា ការខ្វះឯកភាពភាសា និងអក្សរសាស្ត្រ ធ្វើឱ្យក្មេង១ជំនាន់ក្រោយបែកបាក់គ្នា ។ ឯកឧត្តមក៏បានសំណូមពរក្នុងនាមរាជបណ្ឌិតសភាកម្ពុជា ឱ្យប្រមូលគំនិតល្អ១ដើម្បីដោះស្រាយបញ្ហាស្វែងរកការឯកភាពក្នុងភាសារបស់ជាតិយើង និងឱ្យមានភាពរលូន ។

ឯកឧត្តមបានលើកសំណួរថា តើយើងគួរជ្រើសរើសយកវិធីណា តាមបែបចាស់ ឬ ថ្មី ឬ ធ្វើជារបៀបសំយោគ ?

ភារកិច្ចនេះប្រគល់ជូនចំពោះអស់លោក លោកស្រី សាស្ត្រាចារ្យ អ្នកភាសា អ្នកអក្សរសាស្ត្រទាំងអស់ ដើម្បីជួយដោះស្រាយគ្នាប្រកបដោយគតិបណ្ឌិត និងធ្វើឱ្យភាសាខ្មែរយើងមានការអភិវឌ្ឍប្រកបដោយភាពរលូន ។

បន្ទាប់មកឯកឧត្តមប្រធាន សំណូមពរឱ្យសមាជិកនៃអង្គប្រជុំឡើងមានមតិ ដើម្បីស្វែងរកដំណោះស្រាយ ដ៏ល្អមួយសម្រាប់ភាសាជាតិរបស់យើង ហើយក៏សំណូមពរឱ្យ វាគ្មិនទាំងអស់បង្ហាញឈ្មោះខ្លួនឯងផងដែរ មុននឹងមានមតិ ។

✶ **លោក អ៊ុច សារូ មកពីក្រសួងមហាផ្ទៃ :**

-គ្មានយោបល់អ្វីបន្ថែមលើរបៀបវារៈ

-លោកបាននិយាយពីប្រវត្តិក្រោយឆ្នាំ ១៩៧៩ ក្នុងការបង្កើតគណៈកម្មាធិការភាសាខ្មែរ គឺស្ថិតនៅក្រោមឱវាទក្រសួងអប់រំ ។

-លោកបានសំណូមពរឱ្យ អ្នកភាសា អ្នកអក្សរសាស្ត្រទាំងអស់ គិតគូរចងក្រងបង្កើតក្បួនវេយ្យាករណ៍ ឱ្យបានត្រឹមត្រូវជាមុនសិន ។

-គោរពចំពោះអ្នកណាដែលមានវេយ្យាករណ៍ត្រឹមត្រូវ

-គ្នាតិចគោរពគ្នាច្រើន

លោកក៏បានបញ្ជាក់ពីសំណេររបស់ខ្មែរ ដែលខ្ចីពីបរទេសក្រៅពីភាសាបាលី និង សំស្ក្រឹត ត្រូវគោរពគោលការណ៍ដូចខាងក្រោម :

១- តាមសូរខ្មែរ ឧទាហរណ៍ : Machine គឺ ម៉ាស៊ីន គ្មាន ហ្ស៊ី-ហ្ស៊ីសទេ

២- តាមរូបខ្មែរ

៣- គ្មានទំនាញសូរព្យាង្គទេ ព្យាង្គមួយ គឺព្យាង្គមួយ តាមខ្មែរតែម្តង ឬយ៉ាងម៉េចថាអីចឹង

៤- គ្មានការន្ត គ្មានវិភត្តិ

លោកក៏បានសំណូមពរជាលើកទី២ ធ្វើយ៉ាងណាកុំឱ្យឈ្លោះគ្នា ត្រូវធ្វើយ៉ាងណាឱ្យមានក្បួនវេយ្យាករណ៍ ។

★ ឯកឧត្តមប្រធាន បានសំណូមពរថា ត្រូវឱ្យមានវិធានការដោះស្រាយ ។

★ ឯកឧត្តម សូ បុយឡេង :

-លោកដោះស្រាយគំនិតទី១ និង ទី២ ដើម្បីឈានទៅដោះស្រាយគំនិតទី៣

-អ្វីៗដែលលោកបានធ្វើគឺយកតាមលំអានសម្តេចសង្ឃ

-និទ្ទាការមួយគឺសំណេរ

ឯកសារសទ្ទានុក្រមខេមរយានកម្ម :

១-កំណត់ហេតុរបស់គណៈកម្មការចំរុះ

២-កំណត់ហេតុប្រជុំគណៈកម្មការវេយ្យាករណ៍

៣-កំណត់ហេតុផ្សេងៗទៀត គឺគណៈកម្មការពាក្យ

៤-កំណត់ហេតុគណៈកម្មការអនុម័តពាក្យ

គណៈកម្មការចំរុះខាងភាសាខ្មែរមានលោកតា ប៉ាង ខាត់ ជាប្រធាន

១-វិទ្យាស្ថានខ្មែរ-មន លោក ឡុច ផ្លែង

២-គណៈកម្មការវប្បធម៌

៣-គណៈកម្មការវេយ្យាករណ៍ លោក ឃួន សុខម្ភ

៤-មហាវិទ្យាល័យអក្សរសាស្ត្រមនុស្សសាស្ត្រ

៥-គណៈកម្មការខេមរយានកម្ម លោក ឡុច ផ្លែង

ឯកឧត្តមមានប្រសាសន៍ថា សទ្ទានុក្រមបានឈានមួយជំហាន មុនវចនានុក្រម យើងយល់ថា ដល់កម្រិតមួយចុងក្រោយហើយ ។

ឯកឧត្តមបន្តទៀតថា ភាសាខ្មែរមានបី :

-ពាក្យខ្មែរសុទ្ធ

-ពាក្យខ្ចីពីបាលី និង សំស្ក្រឹត

-ពាក្យខ្ចីពីបរទេស

ភាសាខ្មែរឈរលើមូលដ្ឋានពីរ :

-ពាក្យបង្កើតដើម

-ពាក្យបាលីសំស្ក្រឹត

ជាពាក្យឈរលើប្រភពសម្លេង ( ជាតិស័ព្ទពាក្យ )

ឯកឧត្តមបានលើកឡើងពីភាពមិនច្បាស់លាស់របស់ពាក្យនៅក្នុងវចនានុក្រមសម្តេចសង្ឃ ។ ឧទាហរណ៍ "លី" មាននៅក្នុងសទ្ទានុក្រមខេមរយានកម្ម ។ នៅក្នុវចនានុក្រម "ព្ទ" សូរ ព្ទ បន្ទាប់មកពាក្យនោះលោកដាក់ "លី" ។

ឯកឧត្តមបញ្ជាក់ថា សំណោរនិងសំណួរដើរមិនទាន់គ្នាទេ សំណួរវាទៅមុនសំណោរ ។

ឯកឧត្តមក៏បានលើកបញ្ហា "ណ" "ន" មកបញ្ជាក់ផងដែរ :

+ ពី "ណ" ទៅ "ន" ក្នុងករណី "ណ" នៅព្យាង្គទី ២ គឺដូរជា "ន" +

+ ត្រូវគោរពព្យាង្គដើម ព្យាង្គដើម "ណ" រក្សាដដែល

+ ការអាន : ចំពោះពាក្យខ្មែរមិនបញ្ហា តែចំពោះបាលីសំស្ក្រឹតមានបញ្ហា

+ ពាក្យមកពីបាលី មានអំណាន :

-តាមបែបខ្មែរ

-តាមបែបបាលី សំស្ក្រឹត

-តាមបែបប្រឡាយកាត់

ត្រូវយកតាមអំណានបែបខ្មែរសុទ្ធ : ឧទាហរណ៍ បទដ្ឋាន ( បះ-ទាត់-ថាន ) ត្រូវអានថា ( បត់-ឋាន ) ។

មីនា ( មី-នា ) នេះអានតាមបែបបាលីសុទ្ធ បើតាមបែបខ្មែរត្រូវអានមិនា ( មិ-នា ) ។

ដូច្នេះអក្ខរាវិរុទ្ធនិងអំណានត្រូវយកតាមវេយ្យាករណ៍បច្ចុប្បន្ន ។

★ **បណ្ឌិត ថៃល ចៅង :**

-សំណូមពរឱ្យមានបណ្ណាញសារពតិមាន ចូររួមស្តាប់ផងដើម្បីបានដឹង

-ភាសានិយាយដែលមិនមែនជាភាសាស្តង់ដារ វាចូលទៅជាភាសាស្តង់ដារទៅហើយតាមរយៈវិទ្យុ ទូរទស្សន៍ ពីព្រោះក្មេងៗនៅឯបរទេសខំរៀនភាសាខ្មែរ គឺយកតាមវិទ្យុ ទូរទស្សន៍ ដែលជាភាសាស្តង់ដារ ។

★ **ឯកឧត្តមប្រធាន** បានសំណូមពរម្តងទៀតដល់អ្នកស្រាវជ្រាវជួយយកគំនិតល្អៗមក

ដោះស្រាយព្រោះកម្លាំងទាំងពីរ ( ខាងទំនាញសូរ និងខាងអភិរក្ស ) នៅមានកម្លាំងទាំងសងខាងនៅឡើយ ។

★ **លោក លី សុវីរ :**

បញ្ហាអក្ខរាវិរុទ្ធ និងអំណាន :

លោក មិនគាំទ្រអ្នកដែលតាមវចនានុក្រមពេកទេ

លោកសំណូមពរ ធ្វើយ៉ាងម៉េចឱ្យបានឯកភាពគ្នា កុំឱ្យបែកគ្នា ។

ឧទាហរណ៍ : ស្មើ អ្នកណាក៏យល់ព្រមសរសេរដូច្នេះដែរ ។ ចុះដល់ទៅសំនើ មិនព្រម ? មាន " សំនើ " ផង " សំណើ " ផង ?

★ **បណ្ឌិត នៅ ស៊ុន :**

លោកចង់បានក្បួនរួមមួយ " វេយ្យាករណ៍ " គឺក្បួនសរសេរអក្សរ ក្បួនអាន ប្រើប្រាស់តាមរបៀបណា១ ត្រូវមាននិយាមមួយច្បាស់លាស់ ដើម្បីឯកភាពក្នុងការប្រើប្រាស់ភាសាខ្មែរ ឱ្យមានស្តង់ - ដារ ។

★ **ឯកឧត្តម អ៊ិត ប្រាង្គ :**

ឯកឧត្តមបានមានមតិថា បញ្ហាអក្សរខ្មែរមានទំនោរបី :

-អភិរក្សហួសសម័យ

-អព្យាក្រឹត ( កណ្តាល )

-អ្នកហួសជ្រុល

ឯកឧត្តមថា រាជបណ្ឌិតសភាកម្ពុជា ជាអាជ្ញាកណ្តាល ។

★ **លោក ម៉ៀច ប៊ុណ្ណ :**

លោក មានប្រសាសន៍ថា ធ្វើយ៉ាងណាឱ្យឯកភាពគ្នាកុំប្រទាញប្រទង់គ្នាម្ខាង១ កុំប្រញាប់ប្រ- ញាល់ពេក ។ បើយកគោលការណ៍វេយ្យាករណ៍ តើវេយ្យាករណ៍ទាំងពីរនេះស្របគ្នាឬអត់ ?

★ **បណ្ឌិត ខែល ខៅង :**

បញ្ហាគម្រោងធ្វើវចនានុក្រម លោកបណ្ឌិតមានប្រសាសន៍ថា

-វចនានុក្រមទាក់ទងនឹងសំណេរ និង ការអាន ត្រូវតែបង្កើត :

១-គណៈកម្មការជាតិមួយ ( ខាងភាសា ) ត្រូវប្រមូលអ្នកចេះខាងភាសា មកស្រាវជ្រាវ វេយ្យាករណ៍ទាំងចាស់ទាំងថ្មី ( ឱ្យមកជុំគ្នា ) ។

២-បង្កើតគណៈកម្មការជាតិមួយ ដើម្បីរៀបចំបោះពុម្ពចេញវចនានុក្រមខ្មែរមួយ ។

+ អនុគណៈកម្មការជាតិមាន :

-សម្តេចសង្ឃរាជាគណៈ

-អាចារ្យចាស់ទុំ

+ អនុគណៈកម្មការថ្នាក់ខេត្ត

-គ្រូមេគណៈខេត្ត

+ អនុគណៈកម្មការថ្នាក់ស្រុក

-គ្រូអនុគណៈស្រុក

+ អនុគណៈកម្មការថ្នាក់ឃុំ

-មានគ្រូសង្ក្រាជ " ចៅអធិការវត្ត "

ហើយចុងក្រោយជាផ្លូវច្បាប់ត្រូវព្រះមហាក្សត្រឡាយព្រះហស្តលើវចនានុក្រមខ្មែរនេះ ។

**✶ បណ្ឌិត សម្ដោច សែនភុច** ( មកពី យូនីស្កូ ):

លោកមានប្រសាសន៍ថា : នៅគ្រប់ប្រទេសមុននឹងថា ត្រូវធ្វើ ដូចម្តេច " ត្រូវ ហ្នឹង " គឺត្រូវមាន គោលនយោបាយមួយសិន ។

លោកថា :

-សព្វថ្ងៃនេះពិបាកឱ្យមានលក្ខណៈឯកភាព គ្នា

-នៅខាងក្រៅគេថា មន-ខ្មែរ មន-ខ្មែរមាន ១២០ ភាសា មាន១២០ពូជ នៅស្រុកខ្មែរ ហៅខ្មែរ-មន ។

ក្នុងកម្ពុជាកណ្តាលមាន មន-ខ្មែរដែរ ( រតនគិរី) ... ។

-នយោបាយនេះត្រូវឱ្យមានសកលភាវូបនីយកម្មផង ត្រូវមានឯកភាពនិងពហុភាព ។ លោកក៏បាន រៀបរាប់ពី ភាសាខ្មែរដែលថៃយកទៅប្រើ រាប់រយឆ្នាំមកហើយ ក្នុងវចនានុក្រមថៃពាក្យជាច្រើនជាពាក្យខ្មែរ បាលី សំស្ក្រឹត ចំណែកពាក្យថៃ ខ្លួនឯងតិចតួចទេ ។ ហើយពាក្យខ្មែរលាវក៏ច្រើនដែរ ។ លោកបញ្ជាក់ ទៀតថា : ភាសា មន ជួយឱ្យភូមាមានភាសា សរសេរ ភាសាខ្មែរជួយឱ្យ ថៃ និងលាវមានភាសាសរសេរ ។

★ លោក យ៉ី ធន់ :

សូមឱ្យបង្កើតការត្រួតពិនិត្យការប្រើប្រាស់ភាសាខ្មែរដែលមានភាពអនាធិបតេយ្យនៅក្នុងប្រព័ន្ធពិតមាន។

បញ្ហាពាក្យដែលជានាមយកមកប្រើជាកិរិយាស័ព្ទ ។ ឧ. ទាក់ទង ទៅជានិយាយ សូមទំនាក់ទំនង

★ បណ្ឌិត ព្រុំ ម៉ល់ :

-ស្វែងរកដំណោះស្រាយមួយកុំឱ្យទាស់គ្នាក្នុងភាសា

-ត្រូវមានគណៈកម្មាធិការបច្ចេកទេសដើម្បីពិភាក្សា

-ភាសា

-សំណេរ

-បើអ្វីជៀសមិនរួច ត្រូវរក្សាទុក បើបាលីក៏បាលីទៅ បើសំស្ក្រឹតក៏សំស្ក្រឹតទៅ ។

★ លោក ធន់ ហ៊ិច : មកពីក្រសួងការបរទេស

-បញ្ហាក្នុងភាសាខ្មែរ

-អនាធិបតេយ្យទាំងភាសាសរសេរ ទាំងភាសានិយាយ

-អ្វីដែលមានមកហើយ ត្រូវរក្សាទុក

-វេយ្យាករណ៍

★ ឯកឧត្តមបណ្ឌិត ស៊ីច សំណាង :

ឯកឧត្តមប្រធានបានមានប្រសាសន៍ថា រាជបណ្ឌិតសភាកម្ពុជាស្ថិតនៅជាកណ្ដាល ហើយរាជបណ្ឌិតសភានឹងប្រឹងប្រែងដោះស្រាយបញ្ហានេះ ដោយជំរុញឱ្យមានក្បួនច្បាប់មួយជាគោលសម្រាប់ភាសាខ្មែរ ។ ទីបញ្ចប់ ឯកឧត្តមប្រធានសំណូមពរឱ្យបណ្ដាអ្នកស្រាវជ្រាវជាតិទាំងអស់ ខិតខំប្រឹងប្រែងស្រាវជ្រាវរកក្បួនវេយ្យាករណ៍មួយដែលមានលក្ខណៈសុក្រឹត ដើម្បីបញ្ចប់វិបត្តិអក្សរសាស្ត្រ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោងដប់ពីរថ្ងៃត្រង់ ប្រកបដោយបរិយាកាសរីករាយ និងយោគយល់គ្នា ។

ភ្នំពេញ, ថ្ងៃទី១២ សីហា ឆ្នាំ២០០០

លេខាកត់ត្រា

ជូរ គារី

កំណត់ហេតុ

ប្រជុំត្រៀមសន្និសីទជាតិ ថ្ងៃទី ២៥ សីហា ឆ្នាំ២០០០

ឆ្នាំពីរពាន់ ខែសីហា ថ្ងៃទីម្ភៃប្រាំ វេលាម៉ោងប្រាំបីនិង សាមសិបនាទី នៅទីស្នាក់ការរាជបណ្ឌិតសភាកម្ពុជា មានបើកធ្វើសន្និសីទត្រៀមមួយ ក្រោមកិច្ចដឹកនាំរបស់ ឯកឧត្តម បណ្ឌិត ស៊ន សំណាង ប្រធានរាជបណ្ឌិតសភាកម្ពុជាដើម្បីឆ្ពោះទៅសន្និសីទជាតិ ថ្ងៃទី ៨-៩ ខែ កញ្ញា ឆ្នាំពីរពាន់ ។

**របៀបវារៈមានដូចខាងក្រោមៈ**

១-បូកសរុបការប្រជុំស្តីពីបញ្ហាភាសាជាតិនាថ្ងៃទី ដប់ពីរ សីហា ឆ្នាំពីរពាន់

២-បូកសរុបដំណើរការរៀបចំសន្និសីទភាសាជាតិ ថ្ងៃទីប្រាំពីរ ដល់ទីប្រាំបួន កញ្ញា ឆ្នាំពីរពាន់

៣-ពិភាក្សាបញ្ហារៀបចំរចនាសម្ព័ន្ធគណៈកម្មាធិការជាតិភាសា

៤-ការពិភាក្សាលើបញ្ហាផ្សេងៗ ( ការស្រាវជ្រាវ ឯកភាព និង អភិវឌ្ឍន៍ភាសាជាតិ)

៥-ការបូកសរុបមតិ

មតិបូកសរុបរបស់ឯកឧត្តមបណ្ឌិត ស៊ន សំណាង ប្រធានរាជបណ្ឌិតសភាកម្ពុជា

+បូកសរុបការប្រជុំនាថ្ងៃទីដប់ពីរ ខែសីហា ឆ្នាំពីរពាន់ ស្តីពីបញ្ហាភាសាជាតិ

-ការប្រជុំនាថ្ងៃទីដប់ពីរកន្លងមកនេះមានចរន្តបី ១/ ចរន្តអភិរក្សនិយម ២/ ចរន្តទំនើបនិយម ៣/ អ្នកកណ្តាលនិយម ។

-ដំណោះស្រាយចង់បានក្បួនវេយ្យាករណ៍រួមមួយ

-បង្កើតគណៈកម្មាធិការភាសាជាតិមួយ ដែលមានសមាសភាពពីគ្រប់មជ្ឈដ្ឋានប្រើប្រាស់ ។

+បូកសរុបដំណើរការរៀបចំសន្និសីទថ្ងៃទីប្រាំពីរដល់ប្រាំបួនកញ្ញា ឆ្នាំពីរពាន់ :

-សន្និសីទអន្តរជាតិស្តីពីការអភិវឌ្ឍន៍ ឯកភាពភាសាជាតិ ថ្ងៃទីប្រាំពីរ ដល់ថ្ងៃទីប្រាំបួនកញ្ញា ត្រូវបានប្តូរមកជាសន្និសីទជាតិវិញ ដោយសារយើងធ្វើទ្រង់ទ្រាយតូច ព្រោះវាគ្មិនចូលរួមមានតែជាងសាមសិបនាក់ប៉ុណ្ណោះ ។

-ចំពោះខ្លឹមសារគ្មានការប្រែប្រួល កម្មវិធីនៅដដែល ចំណែកឯចំនួនអ្នកចូលរួមនៅដដែល គឺពីររយ ចិតសិបនាក់ ។

- សន្និសីទថ្ងៃទីប្រាំពីរដល់ថ្ងៃប្រាំបួនកញ្ញាខាងមុខនេះពុំមែនជាដំណោះស្រាយបញ្ចប់បញ្ហាភាសាទេ យើងនឹងធ្វើការប្រជុំបន្តបន្ទាប់ទៀតដើម្បីរករូបមន្តរួមមួយ ដោះស្រាយបញ្ហាភាសាជាតិយើងឱ្យមានឯកភាព ។

- តាមរយៈការប្រជុំថ្ងៃទីដប់ពីរ យើងទទួលបាននូវចរន្តបី ។ ការចាប់អារម្មណ៍របស់យើងសំដៅទៅចរន្តពីរដែលមានកំលាំងស្របគ្នា កំពុងឈានទៅមុខដូចគ្នា តែមិនទាន់មានគោលដៅជួបគ្នាទៅឡើយ ។ តើបញ្ហានេះត្រូវដោះស្រាយយ៉ាងណាដើម្បីឱ្យចរន្តទាំងពីរបានជួបគ្នាត្រង់ចំណុចណាមួយ ។ ដូច្នេះហើយទើបអង្គប្រជុំសម្រេចឱ្យរាជបណ្ឌិតសភាកម្ពុជាធ្វើជាអាជ្ញាកណ្តាលដើម្បីដោះស្រាយសម្របសម្រួល ហើយរាជបណ្ឌិតសភាកម្ពុជាមិនអាចចាត់ទុកថាចរន្តមួយណាខុស មួយណាត្រូវឡើយ ព្រោះបញ្ហានេះវាកើតមានតាំងពីទសវត្សទី ៦០ មកម្ល៉េះ ហើយពុំមានការសម្របសម្រួលណាមួយឡើយ រហូតដល់ទសវត្សទី ៧០ និងទសវត្សទី ៨០ រហូតមកដល់បច្ចុប្បន្ន ។

បច្ចុប្បន្នយើងដល់ពេលដែលត្រូវលែងគិតគូរនូវមួយថ្ងៃសម្រាប់មួយថ្ងៃហើយគឺដល់ពេល គិតគូរបែបទស្សនៈវិជ្ជាវិញម្តង ។

កាលពីថ្ងៃទីដប់ពីរកន្លងមក យើងសម្រេចគ្នាថានឹងដោះស្រាយបញ្ហាតាមបែបទស្សនៈវិជ្ជាមិនប្រកាន់អ្នកអភិរក្សនិយមឬអ្នកទំនើបនិយមអ្វីទាំងអស់ ។

-ចំពោះអ្នកដែលអះអាងថាចាស់ បានល្អ តើផ្អែកទៅលើមូលដ្ឋានអ្វីខ្លះ ? មានហេតុផលអ្វីខ្លះ ? ផ្តល់ប្រយោជន៍យ៉ាងណា ?

-ចំពោះអ្នកដែលអះអាងថាថ្មីបានល្អ តើផ្អែកលើមូលដ្ឋានអ្វីខ្លះ ? មានហេតុផលអ្វីខ្លះ ? ផ្តល់ផលប្រយោជន៍យ៉ាងណា ?

-សំណូមពរឱ្យចរន្តទាំងពីរនេះដោះស្រាយផ្អែកលើមូលដ្ឋានទស្សនវិជ្ជា ។

-ចក្ខុវិស័យរួមរបស់យើងគឺធ្វើយ៉ាងណាឱ្យភាសាជាតិយើងមានការអភិវឌ្ឍរីកចម្រើនទៅមុខជានិច្ច ។

+ ចក្ខុវិស័យតំបន់អាស៊ាន

-ការខិតខំរបស់ជាតិនីមួយៗដើម្បីប្រកួតជាមួយជាតិដទៃដើម្បីការរីកចម្រើន ។

-ចៀសវាងការបែកបាក់ផ្នែកភាសាដែលជាមូលហេតុបង្អាតពេលវេលា ។

ឯកឧត្តមប្រធានក៏បានលើកចក្ខុវិស័យនៅតំបន់អាស៊ីបូព៌ា ក្នុងតំបន់ និងចក្ខុវិស័យនៅអាមេរិកផង ដែរ ។

មុននឹងបញ្ចប់មតិ ឯកឧត្តមបានបើកទូលាយដល់អ្នកភាសាទាំងឡាយដែលចង់ដាក់ប្រធានបទចូល រួម ដោយទុកពេលជូនដល់ថ្ងៃទីសាមសិប ខែប្រាំបី ឆ្នាំពីរពាន់ជាចុងក្រោយ ។ អត្ថបទពិស្តារកំណត់ ថ្ងៃទីប្រាំ ខែកញ្ញា ជាថ្ងៃផុតកំណត់ចុងក្រោយ ។

✶ បណ្ឌិត អ៊ីវ ច័ន អ្នកសម្របសម្រួល បានមានមតិពីការរៀបចំរចនាសម្ព័ន្ធគណៈកម្មាធិការភាសា ជាតិ ចំណុចឯកភាពគ្នានៅក្នុងការបង្កើតគណៈកម្មាធិការភាសាជាតិមួយ តើគួររៀបចំរបៀបណា? អ្នកមាន ជំនាញខាងភាសាគួរមានមតិរបៀបណា?

✶ ឯកឧត្តម អ៊ីវ ចុង ប្រធានវិទ្យាស្ថានជាតិគ្រប់គ្រង :

-បុព្វបុរសយើងបានបង្កើតគណៈកម្មាធិការ ឆ្នាំ ១៩៦៧ ជាគណៈកម្មាធិការអចិន្ត្រៃយ៍

-ខេមរយានកម្មបានដល់មធ្យមសិក្សា

-បន្ទាប់មកត្រៀមចូលឧត្តមសិក្សា តែត្រូវជួបសង្គ្រាម

-បញ្ហាខេមរយានកម្មបានបោះជំហានរហូតដល់ឆ្នាំ ១៩៧៥ ។

-កាងារខេមរយានកម្មនេះបានបន្តរហូតមកដល់ឥឡូវនេះ ។

-ការបង្កើតគណៈកម្មាធិការភាសាជាតិគ្មានបញ្ហាអ្វីទេ ព្រោះគណៈកម្មាធិការនេះមានរួចហើយ

-បញ្ហាចោទនៅឧត្តមសិក្សាមានលក្ខណៈធ្ងន់ធ្ងរ មិនមែនមានតែចំពោះវិទ្យាសាស្ត្រសង្គមទេ វិទ្យាសាស្ត្រសេដ្ឋកិច្ច វេជ្ជសាស្ត្រ វិទ្យាសាស្ត្របច្ចេកទេស ក៏មានបញ្ហាដែរ ក្នុងពេលស្រាវជ្រាវរកពាក្យមក ប្រើប្រាស់ ។

-នៅវិទ្យាស្ថានជាតិគ្រប់គ្រង ពីមុនយើងយកភាសាវៀតណាមមកប្រើប្រាស់ ។ កាលនោះ យើងជួបការលំបាកក្នុងការបកប្រែយកមកឱ្យសិស្សយើងរៀន ព្រោះគ្មានអ្នកជំនាញខាងភាសាជួយ ។

-ពេលភាសាអង់គ្លេសចូលមកដល់ យើងក៏ជួបបញ្ហាបកប្រែ ។ ពាក្យខ្លះខ្លី បកមកជាខ្មែរវែង នេះមិនមែនបកទេ គឺពន្យល់តែម្តង ដែលពាក្យគេខ្លីយើងបកប្រែមិនចំ គឺទាល់តែពន្យល់បានជាវាវែង ។

-ការបង្កើតគណៈកម្មាធិការភាសាជាតិនេះល្អណាស់ តែមិនគួរលុបចោលទាំងស្រុងទេ ។

-ការរៀបចំអត្ថបទជាភាសាខ្មែរល្អណាស់ គឺបកម្ខាងជាខ្មែរ ម្ខាងជាអង់គ្លេស យើងត្រូវតែដើរទៅមុខ ។ ឯការប្រើប្រាស់មុខវិជ្ជាគណនេយ្យ ក៏មានការលំបាកយ៉ាងខ្លាំងក្នុងការប្រើប្រាស់ពាក្យមិនឯកភាពគ្នា ធ្វើឱ្យសិស្សនិងសិស្សមានទំនាស់ដោយសារការប្រើប្រាស់ពាក្យមិនឯកភាពគ្នារបស់អ្នកបកប្រែ ។

-យើងគួរយកមតិរបស់ឯកឧត្តមប្រធានរាជបណ្ឌិតសភាអម្បាញ់មិញនេះ ។

-ឯកភាពភាសាធ្វើឱ្យឯកភាពជាតិកាន់តែរឹងមាំ ។

-ការបកប្រែភាសាបរទេសមកជាភាសាជាតិ ងាយស្រួលដល់ប្អូនៗជំនាន់ក្រោយស្រាវជ្រាវ ។

-មិនត្រូវប្រតិកម្មភ្លាមៗទេ ពេលឮពាក្យថ្មីត្រូវមានការពិចារណា ។

✶ ឯកឧត្តម ពៅ សាវ៉ាត សមាជិកព្រឹទ្ធសភា អនុគណៈកម្មការទី៧ តាមដានក្រសួងអប់រំ ក្រសួង ធម្មការ និងសាសនា ក្រសួងទេសចរណ៍ និងក្រសួងវប្បធម :

-ស្នើបញ្ចូលភាសាច្បាប់ចូលក្នុងគណៈកម្មាធិការភាសាជាតិ ( ឱ្យអ្នកកាន់ច្បាប់ចូលរួម )

-ការបកប្រែភាសាផ្សេងៗមកជាភាសាខ្មែរ ពិបាកយល់

-ចាប់អារម្មណ៍លើភាសាច្បាប់ មានការពិបាកក្នុងការប្រើពាក្យច្បាប់

-ការប្រើពាក្យខ្វះឯកភាពគ្នា ។ ឧ. "បទបញ្ញត្តិដែលជុំយ" ក្នុងច្បាប់ខ្វះដាក់ "បដិបញ្ញត្តិ" ។

-តាមការសង្កេត ការបកប្រែ ៩៩.៩ ភាគរយ ពឹងផ្អែកលើវចនានុក្រមខ្មែរ-អង់គ្លេស អង់គ្លេស-ខ្មែរ បារាំង-ខ្មែរ ខ្មែរ-បារាំង ។

-ខ្ញុំថាវចនានុក្រមទាំងនេះពុំមានអាជ្ញាធរភាសាជាតិណាមួយត្រួតពិនិត្យទេ ហើយគេថាបើមិនយក បានឯកសារឯណាបក ?

-ការសង្កេតរបស់ខ្ញុំ គេធ្វើច្បាប់ គេដាក់ពាក្យមកប្រើប្រាស់ច្រើនតែពាក្យណាដែលរាស្ត្រមិនយល់ ( ក្នុងច្បាប់) ពាក្យដែលរាស្ត្រយល់ម៉េចមិនស្រាវជ្រាវមកដាក់ តាមខ្ញុំយល់មកពីអ្នកដាក់ហ្នឹងមិនយល់ខ្លួនឯងដែរ ។

-សំណូមពរឱ្យលោកបណ្ឌិតសាស្ត្រាចារ្យស្រាវជ្រាវរកមេរោគស៊ីភាសាខ្មែរឱ្យឃើញ មេរោគកើតពីអ្នកអភិរក្សក្តី អ្នកទាន់សម័យក្តី នោះជាមេរោគហើយ ។អ្នកមានៈ ដែលប្រើប្រាស់ពាក្យខុសនោះ ក៏ជាមេរោគដែរ ។ គួរព្យាបាលគាត់សិន មុននឹងបញ្ចូលគាត់ទៅក្នុងគណៈកម្មាធិការភាសាជាតិ ។

-អ្នកកាន់កណ្តាលក៏ជាមេរោគដែរ

-ស្នើបញ្ចូលគណៈកម្មាធិការភាសាជាតិជាផ្លូវច្បាប់ដាច់ខាត

-សំណូមពរដាក់ភាសាច្បាប់នេះបញ្ចូលជាបន្ទាន់នៅក្នុងសន្និសីទថ្ងៃទី៧ដល់ទី៩ កញ្ញាខាងមុខនេះ

ដោយឯកឧត្តមប្រធានឯកភាពនឹងការស្នើសុំដើម្បីបញ្ចូលគណៈកម្មការច្បាប់នេះទៅក្នុងគណៈកម្មការភាសា ហើយឯកឧត្តម សន្យានឹងព្យាបាលជំងឺភាសានេះ ។

ឯកឧត្តម( ពៅ សាវ៉ាត) នឹងសុំស្នើដល់គណៈកម្មការព្រឹទ្ធសភា ដើម្បីសុំ សេចក្តីសម្រេចពីសមាជិកព្រឹទ្ធសភា ដើម្បីរូបគាត់បានមកចូលរួមក្នុងគណៈកម្មាធិការភាសាជាតិនេះ ។

★ បណ្ឌិត នៅ ស៊ុន : បញ្ហារៀបចំអង្គការលេខរបស់គណៈកម្មាធិការភាសាជាតិ

-ផ្អែកតាមតារាង ឃើញថាពុំមែនជាគណៈកម្មាធិការភាសាជាតិទេ ផ្ទុយទៅវិញជាគណៈកម្មាធិការបកប្រែភាសាប៉ុណ្ណោះ ។

-គណៈកម្មាធិការភាសាជាតិ ត្រូវកំណត់ឱ្យឯកភាពមួយ

១-គណៈកម្មាធិការភាសាជាតិត្រូវបង្កើតគណៈកម្មការអាន គណៈកម្មការពាក្យ និងគណៈកម្មការសរសេរឡើង វិញ ។

២-អំពីសមាសភាពរបស់គណៈកម្មាធិការភាសាជាតិ ត្រូវយកពីគ្រប់មជ្ឈដ្ឋាន

៣-បង្កើតគណៈកម្មាធិការនេះឱ្យជាផ្លូវច្បាប់ ជាខ្នាតតម្រូវមួយ យ៉ាងហោចណាស់ក៏ត្រឹមអនុក្រឹត្យដើម្បីឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

★ បណ្ឌិត អ៊ីវ ច័ន : ជាដំបូងយើងត្រូវបង្កើតគណៈកម្មការភាសា :

១-គណៈកម្មការអក្ខរាវិរុទ្ធ ( អ្នកជំនាញខាងពាក្យ )

២-គណៈកម្មការវេយ្យាករណ៍ ( អ្នកជំនាញខាងភាសាវិទ្យា )

★ អ្នកស្រី ត្រឹង ងា មានប្រសាសន៍ថា ភាសាខ្មែរមានការវិវត្តន៍ធំ១បីលើក :

១-បុរាណ ( លើសិលាចារឹក)

២-កណ្តាល ( ស្លឹករឹត )

៣-បច្ចុប្បន្ន ទាំងសំណេរ និងសំណូរពិសេសក្នុងច្បាប់ ប្រទាញប្រទង់គ្នានៅក្នុង កាសែត វិទ្យុ ទូរទស្សន៍ ។

-ភាសាខ្មែរសុទ្ធគ្មានពិបាកទេ អានយ៉ាងណា សរសេរយ៉ាងនោះ ។

-តែពិបាករឿងអក្សរបរទេស ពិសេសបាលី សំស្ក្រឹត នៅលាយឡំគ្នាច្រើនណាស់ មានឥទ្ធិពលយ៉ាងខ្លាំងរហូតដល់មិនដឹងថាជាភាសាបាលី សំស្ក្រឹតទេ ។

-ហើយសំណូមពរដល់ក្រសួងអប់រំ គួរបណ្តុះបណ្តាលគ្រូបង្រៀនឱ្យស្គាល់ពាក្យ បាលី សំស្ក្រឹត ឱ្យបានច្បាស់លាស់ ។

-ភាសាបាលីចូលមកខ្មែរ ខ្មែរបង្រួញសូរ យើងមិនទុកទាំងដុលទេ ទុកតែធម៌សូត្រ ខ្មែរចូលចិត្តអានព្យាង្គទោល ។

-ខ្មែររក្សាស័ព្ទជាតិ ភាសាបរទេសចូលមក ខ្មែរធ្វើខេមរនីយកម្ម ឬខ្មែរនីយកម្ម ។

-លក្ខណៈពិសេសរបស់ខ្មែរគឺបង្រួញព្យាង្គឱ្យស្រួលតាមសម្តីខ្មែរ ។

-សាសនាចូលមកខ្មែរមានបីគឺ :

១-ព្រហ្មញ្ញសាសនា ប្រើភាសាសំស្ក្រឹត

២-ពុទ្ធសាសនាមហាយាន ប្រើភាសាសំស្ក្រឹត

៣-ពុទ្ធសាសនាហីនយាន ប្រើភាសាបាលី

-ក្នុងក្រសួងអប់រំ យុវជន និងកីឡាមិនទាន់ឱ្យខុសទេ ចំពោះការសរសេរអក្សរ "ណ" និង "ន" នេះ ។ ឧ. ដំនើរ មកពី ដើរ ចុះថ្នាក់ពាក្យ [អម់ / ន] ⇨ ដំនើរ [អម់ / ន]

-តួអក្សរខ្មែរមួយចំនួនសម្រាប់កត់សូរបាលី និងសំស្ក្រឹត

-បញ្ជាក់ សូមកុំឆ្ងល់ កុំច្រឡំបញ្ហា ណ-ន នេះឱ្យសោះ ព្រោះជាបញ្ហាទំនាញសូរ និងបញ្ហាកំលាយ ។

★ លោក ធន់ ហ៊ិន មិនឯកភាពតាមក្បួនទំនាញសូរ មិនឯកភាពតាមពាក្យកម្លាយ :

-ឆ្ងល់អំពីកម្លាយពាក្យ កំដៅ - ក្តៅ ? ចុះ កំដរ ?ក្លាយមកពីណា ?

-បញ្ហាព្យាង្គរាយ ត្រូវព្យាង្គរាយឱ្យអស់កុំឱ្យមានប៉ះពាល់ដល់គេឯង

-បើទំនាញសូរត្រូវតែទំនាញសូរឱ្យអស់កុំឱ្យមានប៉ះពាល់ដល់គេឯង

-លោកខ្លះកំពុងជីកឫសបេតិកភណ្ឌរបស់ជាតិខ្មែរ

★ឯកឧត្តមប្រធានបានសម្រួលដើម្បីកុំឱ្យបរិយាកាសតានតឹងពេក ដោយបានសំណូមពរឱ្យជួយរកដំណោះស្រាយដើម្បីរកការឯកភាពវិញ ។

★បណ្ឌិត ព្រុំ ម៉ល់ : សុំយកពាក្យបច្ចេកទេសទៅពិភាក្សាក្នុងគណៈកម្មាធិការវិញ ។

★ឯកឧត្តមប្រធានសំណូមពរឱ្យអង្គប្រជុំ ពិចារណាលើការរៀបចំគណៈកម្មាធិការមួយដើម្បីដោះស្រាយលើការឯកភាពគ្នានេះ ។

-យើងមិនអាចធ្វើការខ្វែងមតិគ្នានៅពេលនេះបានទេ ។

-តើយើងត្រូវបង្កើតយន្តការនេះដោយវិធីណា? របៀបណា?

-ត្រូវប្រមូលផ្តុំបញ្ហាមួយដើម្បីរៀបចំយន្តការនេះដើម្បីឈានទៅរកការដោះស្រាយបញ្ហានេះ ។

* លោកម៉ៅ ធីហុង បានផ្តល់យោបល់ថា :

-បញ្ហាភាសាត្រូវអភិវឌ្ឍន៍

-វចនាសម្ព័ន្ធត្រូវចែកជាពីរផ្នែក :

១. រកអ្នកនយោបាយដែលមានអំណាចណាម្នាក់ជាបង្អែក

២. អ្នកបច្ចេកទេសគួរស្ថិតនៅឯករាជ្យជាចាំបាច់

-បញ្ហាវេយ្យាករណ៍ត្រូវតែមាន ប៉ុន្តែត្រូវឱ្យមានលក្ខណៈងាយស្រួលក្នុងការរៀនដោយមានមូលដ្ឋានច្បាស់លាស់ ។

-ត្រូវប្រើសាកល្បងសិនមុននឹងអនុម័តនូវពាក្យនីមួយៗ

-វេយ្យាករណ៍សុំធ្វើឱ្យមានការងាយស្រួលជាងមុន ទោះផ្អែកលើមូលដ្ឋានអ្វីក៏ដោយ ដើម្បីអ្នកប្រើប្រាស់ងាយស្រួលប្រើ ។

២-អ្នកគាំទ្រ ឬអ្នកប្រើប្រាស់

-ពាក្យបង្កើតហើយយើងដាក់ឱ្យគេប្រើ ហើយត្រូវស្តាប់មតិប្រតិកម្មវិញផង ។

៣-អ្នកផ្តល់យោបល់:

-រកប្រភពអ្នកប្រើ គេប្រើយ៉ាងម៉េច? ដោយមានទាំង កម្មករ ទាហាន កសិករ ស្រទាប់យុវជន តើគេប្រើយ៉ាងម៉េច?

សំណូមពរ : សុំឱ្យខិតលំទោនរកគ្នាទៅវិញទៅមក ដើម្បីកសាងស្នាដៃមួយឱ្យកូនចៅជំនាន់ក្រោយ ។

* លោក ស៊ឹង ខាំចាន់តារ៉ុង បានផ្តល់មតិថា:

-លោកឯកភាពលើទស្សនៈវិស័យរួមទៅលើការបើកសន្និសីទជាតិនៅថ្ងៃ ៧-៩ ខែ កញ្ញា ខាងមុខនេះ ។

-ឯកភាព គួរមានភាពឯកភាពគ្នាក្នុងបញ្ហាភាសា

-វចនាសម្ព័ន្ធ លោកឯកភាពជាមួយវាគ្មិនខាងដើម

-យើងត្រូវប្រមូល អ្នកអភិរក្ស អ្នកទំនើប អ្នកកណ្តាល ដែលមាននៅសល់សព្វថ្ងៃនេះត្រូវស្រាវ

ជ្រាវ ដើម្បីអភិវឌ្ឍន៍ ឯកភាពគ្នា ។

-ពាក្យដែលប្រើហើយពីមុនមក ( តាមសម្តេចសង្ឃ ) គួរទុកវាប្រើទៅ ឱ្យកូនខ្មែរបានស្គាល់ផង ។

-ត្រូវស្រាវជ្រាវពាក្យដែលយើងខ្វះខាតសព្វថ្ងៃ ។ ស្រាវជ្រាវ និង ឯកភាព នឹងនាំមកនូវការអភិវឌ្ឍន៍ ។

## ខេឈរសៀល

លោក ស៊ឹង ខាំចាន់តារ៉ុង បានសុំមានមតិបន្ត ដោយធ្វើសំណូមពរដូចខាងក្រោម:

១. រកចំណុចមួយជួបគ្នា ដើម្បីរក្សាភាសាជាតិយើងឱ្យ បានគង់វង្ស ។

២. កុំឱ្យធ្លាក់ដោយទៅយកភាសាគេជាយាន

៣. សូមឱ្យប្រើពាក្យតែមួយ គឺអភិវឌ្ឍន៍ភាសាជាតិ កុំប្រើពាក្យបដិវត្ត ឬ វិវត្ត

៤. គណៈកម្មាធិការភាសាជាតិត្រូវតែងតាំងដោយអនុក្រឹត្យ ឬព្រះរាជក្រឹត្យ ដែលត្រូវធ្វើការ-ងារ ដូចខាងក្រោម:

- គួរអភិវឌ្ឍភាសាខ្មែរ ( ពាក្យបច្ចេកទេស ) ដែលខ្វះខាត ឱ្យកូនខ្មែរប្រើប្រាស់ដោយសំបូរបែប ។

- គួរប្រមូលផ្តុំ ព្រឹទ្ធបុរសយើងទាំងអស់ដែលមានបទពិសោធន៍មកចូលរួម ក្នុងគណៈកម្មាធិការភាសាជាតិនេះ ។ លោកបានចោទជាសំណួរថា ក្នុងសកម្មភាពរបស់គណៈកម្មាធិការភាសាជាតិ អនុគណៈ កម្មការភាសាជាតិ តើត្រូវធ្វើអ្វីខ្លះ?

★ ឯកឧត្តមប្រធានបានឯកភាពនឹងយោបល់របស់លោកវរៈសេនីយឯកដែរ ចំពោះការប្រើប្រាស់ភាសាបរទេសគួរតែស្វែងរកមកប្រើជាភាសាខ្មែរ និង ការប្រើប្រាស់លេខខ្មែររបស់យើងវិញ ។

★ លោក សឺន សែត បានមានប្រសាសន៍ថា :ខ្មែរយើងខ្លួនឯងមិនឃើញតម្លៃភាសាជាតិរបស់ខ្លួនទេ ។ លោកបានផ្តល់មតិថា: ដើម្បីឱ្យភាសាខ្មែរមានតម្លៃ ត្រូវបង្កើតគណៈកម្មាធិការភាសាជាតិនេះ ។ លោកបានបន្តថា គួរតែមានគណៈកម្មាធិការមួយទៀតគឺ គណៈកម្មការលើកស្ទួយ លើកទឹកចិត្ត និង តស៊ូមតិក្នុងភាសាខ្មែរ ដើម្បីឱ្យភាសាខ្មែរ រីកចំរើន និងពេញនិយម ។

★ ឯកឧត្តមប្រធានបានថ្លែងអំណរគុណដល់លោក សឺន សែត ដែលបានយកចិត្តទុកដាក់ដល់ភាសាខ្មែរ ។

★ លោកបណ្ឌិត នៅ ស៊ុន : សូមជួយបន្ថែមគណៈកម្មការអំណានមួយទៀត ។

★ ឯកឧត្តមប្រធានបានថ្លែងអំណរគុណដល់បណ្ឌិតនៅ ស៊ុន និងឯកភាពតាមសំណើ ។

-បំបែកសាខាឱ្យវិលជាប្រចាំ រវាងស្ថាប័នរាជបណ្ឌិតសភាកម្ពុជា រដ្ឋសភា ព្រឹទ្ធសភា និងព្រះសង្ឃ ។

* ឯកឧត្តមប្រធានបានយល់ស្របជាមួយឯកឧត្តម ពៅ សាវ៉ាត ។

* បណ្ឌិត ស៊ុំ ឈុំប៊ុន :

-តាមសំដីលោកវ៉ាន់ ឌីកាអុន យើងមិនអាចយកឯកសារស្រាវជ្រាវរបស់ខ្លួនមួយមកឱ្យគេអនុវត្តបានទេ ។

លោកបណ្ឌិតបានលើកពីគំរូវចនាសម្ព័ន្ធរបស់គណៈកម្មាធិការជាតិភាសានៃប្រទេសមួយចំនួនមកបង្ហាញដល់អង្គសន្និសីទ ។

-លើកឡើងក្នុងករណីរួម ឬជាគោលការណ៍មួយបានហើយ ។

* បណ្ឌិត ផៃល ចៅង :

-អំពីគណៈកម្មការ

-គណៈកម្មការអានពាក្យ នៅក្នុងគណៈកម្មការវេយ្យករណ៍ហើយ ។

-គណៈកម្មការត្រូវ

ក-រួមរួមគ្នាដើម្បីបង្កើតក្បួនច្បាប់ ។

ខ-លើកឧទាហរណ៍ ទឡ្ហីករណ៍ សមភាពសមរម្យ ហេតុផល ជាជាងមនោសញ្ចេតនា ។

គ-យល់ព្រមគ្នាដោយយល់ថាមតិយើងមិនត្រូវគ្នា ។

* ឯកឧត្តមប្រធាន : ជាគោលការណ៍គឺយើងលើកឧទាហរណ៍ជាក់ស្ដែង ទឡ្ហីករណ៍ជាក់ស្ដែង ។

* លោក លី សុវីរ :

-មិនចង់ឱ្យនិយាយប៉ះអ្នកណាម្នាក់ទេ ។

-ត្រូវចេះយោគយល់គ្នា ប្រើសំដីឱ្យថ្នាក់ថ្នមគ្នាខ្លះ ។

-សំណូមពរធ្វើយ៉ាងណាកុំឱ្យឈ្លោះគ្នា ។

* ឯកឧត្តមប្រធាន បានថ្លែងអំណរគុណដល់ព្រឹទ្ធាចារ្យ លី សុវីរ ហើយក៏បានឯកភាពលើមតិដ៏ល្អនេះ ។

* លោក ហង់ ពៅ បានឱ្យយោបល់ថា :

★ លោក ធន់ ហិន ៖

-តាមការកត់សម្គាល់ ជនជាតិខ្មែរនិយាយភាសាជាតិដទៃបានច្បាស់ជាងជនជាតិគេនិយាយភាសាបរទេស ។

-ខ្មែរគួរមានមោទនភាពចំពោះភាសាជាតិយើងណាស់ ។

-កុំចង្អៀតចង្អល់ចំពោះភាសាបរទេសពេក កុំជាតិនិយមចង្អៀតចង្អល់ពេក ។

-សុំកុំលុបអញ្ញត្រស័ព្ទខ្មែរ អ្វីដែលមានពីមុនមកកុំលុបពាក្យរបស់គេឱ្យសោះ ។

-សុំតែងតាំងឥស្សរជនកំពូលជាអធិបតីក្នុងគណៈកម្មាធិការភាសាជាតិ ហើយគណៈកម្មាធិការនេះត្រូវមានភារកិច្ចធ្វើអីខ្លះ ?

★ ឯកឧត្តមប្រធាន បានមានប្រសាសន៍ថា សុំមេត្តាយកឱសថមកព្យាបាលវិបត្តិវិញ

គោលបំណងគឺរៀបចំផ្លូវឱ្យមានភាពរលោងបន្តិចសិនមុននឹងឈានទៅរកសន្និសីទជាតិខាងមុខ ។

-ចង់បានសំណូមពរមួយក្នុងការរៀបចំរចនាសម្ព័ន្ធគណៈកម្មាធិការភាសាជាតិនេះ ។

-សុំកុំនិយាយប៉ះពៀរទៅលើបុគ្គលណាមួយ អ្នកស្រាវជ្រាវណាមួយ ។

★ ឯកឧត្តម ពៅ សាវ៉ាត មានប្រសាសន៍អំពីរចនាសម្ព័ន្ធ៖

-វិទ្យាស្ថានភាសាជាតិត្រូវមើលឱ្យច្បាស់ពីតួនាទីបច្ចុប្បន្នគឺស្វែងរកឯកភាពភាសាខ្មែរ ជាអាទិភាពទីមួយ ។

-បង្កើតគណៈកម្មាធិការមួយពិនិត្យពាក្យដែលគណៈកម្មការខេមរយានកម្មបានអនុម័តពីមុនមកបានសព្វគ្រប់ហើយ ។

-បង្កើតគណៈកម្មការមួយដើម្បីពិនិត្យភាសាខ្មែរដែលមានឫសកែវពីបាលី-សំស្ក្រឹត ។

-បង្កើតគណៈកម្មការមួយត្រួតពិនិត្យភាសាខ្មែរដែលមានឫសកែវពីបារាំង-អង់គ្លេស ។

-បង្កើតគណៈកម្មការមួយត្រួតពិនិត្យភាសាខ្មែរដែលមានឫសកែវពីមន-ខ្មែរ ។

ការបង្កើតគណៈកម្មការនេះដើម្បីដោះស្រាយបញ្ហាដែលចោទឡើងថាបុរាណ សម័យ ជាដើម ។

-ចំនួនដ៏ច្រើននៃពាក្យថ្មីមានការខុសឆ្គង សូមបង្កើតគណៈកម្មាធិការមួយត្រួតពិនិត្យពាក្យទាំងនោះឡើងវិញ ។

-សុំឱ្យរាជបណ្ឌិតសភានិងវិទ្យាស្ថានភាសាជាតិពិនិត្យដាក់ឥស្សរជនដែលមានឥទ្ធិពលចូលក្នុងគណៈកម្មាធិការភាសាជាតិ ។

-ពាក្យចាស់ត្រូវរក្សាដដែល ( ពាក្យដែលមានក្នុងវចនានុក្រម ឬពាក្យពីមុនមក មិនមែនពាក្យទំនាញសួរ ) ។

-រួមគ្នាជួយអភិវឌ្ឍភាសា

* ឯកឧត្តមប្រធាន បានបង្ហាញពីវត្តមានដ៏មានកិត្តិយសរបស់លោកជំទាវ ពុំ ស៊ីចាន់ ដល់អង្គប្រជុំ រួចឯកឧត្តមប្រធានបានគោរពអញ្ជើញលោកជំទាវ ពុំ ស៊ីចាន់ ឡើងមានមតិ

* លោកជំទាវ ពុំ ស៊ីចាន់ មានប្រសាសន៍ថា :

-ភាសាជាតិយើងមានភាពរប៉ាត់រប៉ាយតាំងពីទសវត្សទី៨០មកម្ល៉េះ ។

-កម្មវិធីសិក្សាតាំងពីបឋមសិក្សាគ្មានការឯកភាពគ្នា សៀវភៅក្នុងកម្មវិធីសិក្សា សរសេរខុស

ឧ. ស្ថានីយ៍ ក្នុងសៀវភៅសរសេរ ឋានី

ស្ថិតិ ក្នុងសៀវភៅសរសេរ ឋិតិ ។ ខ្ញុំមិនយល់ថាតើ គេធ្វើនេះដោយយោលទៅលើក្មេងៗដែលវាមិនទាន់ចេះអានឬ ? ប៉ុន្តែបើតាមគរុកោសល្យ គឺខុស ។

-អក្សរ ឡ ណ ស្ទើរបាត់បង់ពីក្នុងភាសាខ្មែរ ។

-"ចំណោះ" គេសរសេរ "ចំនោះ" គឺខុសវេយ្យាករណ៍ ព្រោះ" ចំ "ន័យមួយផ្សេង "នោះ" ជាន័យមួយផ្សេងទៀត ។

-តើពាក្យ ឡេឡា គេសរសេរ លេលា ឬ ?

-អ្វីៗបើចេញពីស្ថាប័នកំពូលមក គេគោរព

-"ផែនការណ៍ " ពីណាពីណើមកមាន" ណ៍ " តែឥឡូវកាត់ " ណ៍ "ចោល នៅតែ " ផែនការ " ។

-ពាក្យថ្មីដែលគ្មានន័យបែរជានាំគ្នាបង្កើត នាំគ្នាសន្មត តែពាក្យដែលមានហើយបែរជានាំគ្នាឱ្យខុសទៅវិញ ។

-ភាសាខ្មែរ គួរតែខ្មែរអាន សរសេរ និយាយ ឱ្យបានច្បាស់ ។

សំណូមពរ : ឱ្យរាជបណ្ឌិតសភាកម្ពុជាជួយធ្វើឱ្យភាសាខ្មែរមានពន្លឺត្រចះត្រចង់ឡើងវិញ ។

* ឯកឧត្តមប្រធាន បានថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះមតិរបស់លោកជំទាវ រួចឯកឧត្តមប្រធាន បានអញ្ជើញឯកឧត្តមបណ្ឌិត ឆយ យីហ៊ាង ឡើងមានមតិ ។

* ឯកឧត្តម ឆយ យីហ៊ាង មានប្រសាសន៍ថា :

-សារាចរសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ចេញឱ្យប្រើប្រាស់ភាសាខ្មែរតាមវចនានុក្រម ។

ការសម្រេចនេះ គឺខុស ព្រោះវចនានុក្រមមានច្រើនណាស់ដែលខុសពី ជួន ណាត ហើយពាក្យបច្ចេកទេសក៏កើតមានពាក្យថ្មីៗច្រើនដែលគ្មានក្នុងវចនានុក្រម ។ ឯកឧត្តមបណ្ឌិត សំណួមពរ :

-ចូរយើងរកផ្លូវជាកណ្តាលមួយ ។

-តែបញ្ហាគឺថវិកា ។

* ឯកឧត្តមប្រធាន បានអញ្ជើញឯកឧត្តម ឈន អៀម មានមតិ

* ឯកឧត្តម ឈន អៀម :

-យើងគួររក្សា Phonème របស់យើងឱ្យបាន មិនគួរលុបចោលទេ មុននឹងលុបគួរពិចារណាឱ្យច្បាស់សិន។

-ឡ ល ណ ន មិនគួរលុប ឡ ណ ចោលទេព្រោះដើម្បីទុកកត់សូរនៃភាសាបាលី សំស្ក្រឹត និងភាសា បរទេសដទៃទៀត ។

* ឯកឧត្តមប្រធាន : យើងត្រូវសម្រុះសម្រួលគ្នា ដើម្បីឈានទៅរកឯកភាពមួយ ។

* លោក ឈុន លិះ ( គ្រូបង្រៀននៅសាលា បុរី១០០ខ្នង )

-ភាសាជាតិយើងស្រុតចុះពីមួយថ្ងៃទៅមួយថ្ងៃដោយសារ :

˙សង្គ្រាមធ្វើឱ្យភាសាជាតិចុះខ្សោយ

˙ជីវភាពរបស់គ្រូបង្រៀនខ្វះខាត

˙ប្រជាជនយើងមិនលើកតម្កើងភាសារបស់ខ្លួន

˙ក្រសួងអប់រំ កាលពីមុនមានសរសេរតាមអាន តែឥឡូវលុបកម្មវិធីសរសេរតាមអានចោល យក កម្មវិធីសិស្សមជ្ឈមណ្ឌលវិញ ។

-ពាក្យឫសជាម្តាយ ពាក្យក្លាយជាកូន

-ពាក្យ រឹង → របេង

-ព្ញ មិនអាចទៅជា ល្បី ទេ គឺ ព្ញ ទៅជាល្បី ។

-បង្កើតគណៈកម្មាធិការជាតិភាសាឡើងដើម្បីស្វែងរកឯកភាពគ្នាជាធ្លុងមួយ

-ស្នើតម្លើងប្រាក់ខែមន្ត្រីរាជការដើម្បីឱ្យស៊ីគ្រប់គ្រាន់ ។

-ប្រាក់ខែមួយខែចិញ្ចឹមឆ្អែមិនគ្រាន់ ។

* ឯកឧត្តមប្រធានបានមានប្រសាសន៍បញ្ជាក់ថា សន្និសីទត្រៀមនេះជាកម្រាលព្រំដ៏ល្អមួយសម្រាប់ឈានទៅ រកសន្និសីទជាតិថ្ងៃទី៧ - ៩ កញ្ញា ខាងមុខនេះបានជោគជ័យ ។

ឯកឧត្តមប្រធានបានប្រសិទ្ធិពរជ័យជូនដល់ព្រះតេជគុណ ឯកឧត្តម លោកជំទាវ អស់លោក បណ្ឌិត សាស្ត្រាចារ្យ អ្នកស្រាវជ្រាវភាសាជាតិទាំងអស់ ឱ្យជួបតែសេចក្ដីសុខ សេចក្ដីចម្រើន និង សុខភាពបរិបូរណ៍។

អង្គប្រជុំបានចប់សព្វគ្រប់នៅវេលាម៉ោង១៧ និង១៥នាទីក្រោមបរិយាកាសស្និទ្ធស្នាល និងយោគយល់គ្នាជាភាគរ: ។

ភ្នំពេញ. ថ្ងៃទី២៥ សីហា ឆ្នាំ ២០០០

លេខាកត់ត្រា

ជួរ តារី